**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**


# សារណាបញ្ចប់ការសិក្សា

# ប្រភេទ និងវិធីសាស្ត្រនៃការធ្វើបណ្តឹង ក្នុងរឿងក្តីព្រហ្មទណ្ឌ

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧ ដល់ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧


| | | |
|---|---|---|
| រៀបរៀងដោយ | | សាស្ត្រាចារ្យណែនាំ |
| និស្សិតឈ្មោះ: | **កញ្ញា. ទូច គន្ធា** | **លោក ហោ សុត័ណ្ណ** |
| | **លោក. អឿន ប៊ុនថៃ** | |


| | |
|---|---|
| ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** | ឆ្នាំចូលសិក្សា ២០១៣ |
| ជំនាន់ទី១៧ | ឆ្នាំសរសេរសារណា ២០១៧ |

# សេចក្តីថ្លែងអំណរគុណ

ជាបឋមនាងខ្ញុំឈ្មោះ **ទូច គន្ធា** និងខ្ញុំបាទ **អឿន ម៉ុនថៃ** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្រ្ត ជំនាន់ទី១៧ ផ្នែកនីតិសាស្រ្ត នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១៣-២០១៧។

ចំពោះគុណូបការៈដ៏សែនថ្លៃថ្លារបស់ **លោកឪពុក អ្នកម្តាយ** ដែលបានបង្កើត និងចិញ្ចឹមបីបាច់ថែរក្សារូបកូនឲ្យធំដឹងក្តី និងអប់រំទូន្មានប្រៀនប្រដៅដល់កូន រហូតមកដល់ថ្ងៃនេះ។ ចំពោះមហាទិគុណរបស់លោកទាំងទ្វេ កូនពុំអាចនឹងទៅរកអ្វីយកមកប្រៀបស្មើទៅនឹងគុណរបស់លោកទាំងពីរនោះទេ ហើយកូនក៏មិនអាចនឹងបំភ្លេចបាននូវព្រះគុណដ៏បវរនេះបានឡើយ ។ កូនសូមលើកហត្ថទាំងទ្វេសម្បូងសង្រូងដល់ទេវតាថែរក្សាលោកយើងនេះ និងដល់វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក សូមមេត្តាតាមជួយថែរក្សា និងការពារដល់រូបលោកអ្នកមានគុណទាំងពីរ ឲ្យមានសុខភាពបរិបូរណ៍ អាយុយឺនយូរ និងមានប្រាជ្ញាស្មារតីភ្លឺស្វាង ដើម្បីស្ថិតជាម្លប់ដល់កូនៗតទៅជានិច្ចនិរន្តរ៍។

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ ឯកឧត្តមបណ្ឌិត **លុយ ចន្ធា** សាកលវិទ្យាធិការ នៃសាកលវិទ្យល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ព្រមទាំងសាកលវិទ្យាធិការរងព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងលោក លោកស្រីសាស្រ្តចារ្យទាំងអស់ ដែលបានខិតខំអស់ពីកំលាំងកាយចិត្តក្នុងការបង្ហាត់បង្រៀន និងណែនាំ ព្រមទាំងធ្វើការចង្អុលបង្ហាញស្ថានភាពសង្គមជាក់ស្តែងទៀតផង។

ជាពិសេសយើងខ្ញុំសូមថ្លែងអំណរគុណចំពោះ លោកសាស្រ្តាចារ្យ **ហោ សុភ័ណ្ឌា** ដែលជាសាស្រ្តាចារ្យប្រកបដោយគតិបណ្ឌិត ដែលបានផ្តល់កិត្តិយសណែនាំ ជួយជ្រោមជ្រែង ផ្តល់គំនិតយោបល់ និងជួយកែសម្រួលរាល់កំហុសឆ្គងក្នុងការសរសេរសារណានេះ រហូតទទួលបានជោគជ័យ រួមទាំងឯកសារ ដែលលោកសាស្រ្តាចារ្យបានផ្តល់ឲ្យ គឺជាគ្រឹះក្នុងការចងក្រងសារណាមួយនេះ។

ជាទីបញ្ចប់យើងខ្ញុំទាំងពីរ សូមគោរពជូនពរដល់ **លោកឪពុក អ្នកម្តាយ ឯកឧត្តមសាកលវិទ្យាធិការ លោក លោកស្រី សាស្រ្តាចារ្យទាំងអស់** ជាពិសេសលោកសាស្រ្តាចារ្យ **ហោ សោភណ្ឌា** ដែលបានបង្ហាត់បង្រៀនដល់រូបយើងខ្ញុំ សូមឲ្យមានសុខភាពពេញបរិបូរណ៍ជួបប្រទះ តែសេចក្តីសុខសេចក្តីចម្រើន សុភមង្គល និងទទួលជោគជ័យគ្រប់ភារកិច្ចការងារ។

# អារម្ភកថា

តាមរយៈការឆ្លងកាត់ការសិក្សា ជំនាញនីតិសាស្ត្រអស់រយៈពេល៤ឆ្នាំកន្លងមកនេះបាន បង្ហាញឲ្យឃើញថា នីតិសាស្ត្រពិតជាជំនាញមួយយ៉ាងសំខាន់ដែលជាចលករសម្រាប់ជម្រុញឲ្យ សង្គមទាំងមូលទទួលបាននូវការរីកចម្រើន និងភាពក្សេមក្សាន្ត។ នីតិវិធីព្រហ្មទណ្ឌ គឺមុខវិជ្ជា ពិសេសមួយក្នុងចំណោមមុខវិជ្ជាទាំងអស់ ដែលយើងខ្ញុំបានសិក្សា ហើយពួកយើងពិតជាមាន ចំណាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការជ្រើសរើសមុខវិជ្ជាមួយនេះមកធ្វើការស្រាវជ្រាវ និងចងក្រងធ្វើជា សារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំក្រោមប្រធានបទ “**ប្រភេទ និងវិធីសាស្ត្រនៃការធ្វើបណ្តឹងនៅក្នុងរឿងក្តីព្រហ្មទណ្ឌ**” ។

ជាការពិតណាស់ សារណាមួយនេះ ត្រូវបានតាក់តែងឡើង ដោយយោងទៅតាមទ្រឹស្តីនៃ ក្រមនីតិវិធីព្រហ្មទណ្ឌមួយចំនួន ចំណែកឯមួយចំនួនទៀតគឺត្រូវបានពឹងផ្អែកទាំងស្រុងទៅលើការ អនុវត្តដោយផ្ទាល់របស់ស្ថាប័នអយ្យការ ដែលមានព្រះរាជអាជ្ញាជាតំណាងក្នុងការអនុវត្តនេះ។ ម្យ៉ាងវិញទៀត សារណាមួយនេះត្រូវបានចងក្រងឡើងក្នុងគោលបំណង កសាងទុកជាឯកសារ សម្រាប់និស្សិតទាំងឡាយ ប្រើប្រាស់ដើម្បីជាកម្មវត្ថុនៃការសិក្សាស្រាវជ្រាវ ។ ជាពិសេសវាបាន តាក់តែងឡើងយ៉ាងផ្ចិតផ្ចង់ទៅលើទម្រង់នៃបណ្តឹងព្រហ្មទណ្ឌ ក៏ដូចជាបែបបទនៃការធ្វើបណ្តឹង ព្រហ្មទណ្ឌ សម្រាប់ប្រជាពលរដ្ឋគ្រប់រូប ដើម្បីឲ្យយល់កាន់តែច្បាស់ពីវា ដោយហេតុថាប្រជាពលរដ្ឋ កម្ពុជាភាគច្រើន គឺមិនទាន់យល់ច្បាស់នូវវិធីសាស្ត្រក្នុងការធ្វើបណ្តឹង នៅពេលដែលមានបទល្មើស មួយកើតឡើង ។ ដូចនេះហើយយើងខ្ញុំបានរំពឹងទុកយ៉ាងខ្ពស់ថា សារណាមួយនេះពិតជាមានសារៈ សំខាន់យ៉ាងខ្លាំង សម្រាប់ និស្សិតគ្រប់រូប ក៏ដូចជាប្រជាពលរដ្ឋទាំងឡាយដើម្បីជាជំនួយសម្រាប់ ការប្រើប្រាស់ ក្នុងវិស័យច្បាប់ នាពេលបច្ចុប្បន្ននេះ។ ទោះបីជាយ៉ាងណាក៏ដោយ ដោយសារស្នាដៃ មួយនេះ គឺជាសមិទ្ធិផលដែលកកើតឡើងដោយការខិតខំប្រឹងប្រែងរបស់និស្សិតតែពីរនាក់គត់ នោះ ចំណុចខ្វះខាត និងកំហុសក្នុងការបកស្រាយ ក៏ដូចជាកំហុសអក្ខរាវិរុទ្ធទាំងឡាយ ច្បាស់ជានឹងកើត មានជាក់ជាមិនខាន។ ដូច្នេះហើយ រាល់ការរិះគន់ក្នុងន័យសកែលម្អ ពីសំណាក់អ្នកអានទាំងឡាយ នឹងត្រូវបានទទួលស្វាគមន៍ដោយស្មោះស្ម័គ្រ ប្រកបដោយការដឹងគុណយ៉ាងជ្រាលជ្រៅ។ ក្នុងនាម យើងខ្ញុំជាអ្នកចងក្រងសារណានេះឡើង សូមទទួលស្គាល់ថាស្នាដៃមួយនេះ ពុំមែនជាស្នាដៃមួយ ដែលពេញលេញនោះទេ ដោយហេតុថាការស្រាវជ្រាវរបស់ពួកយើងនូវមានកម្រិត រួមផ្សំជាមួយ ភាពកង្វះខាតនូវឯកសារមួយចំនួន។

ជាចុងក្រោយយើងខ្ញុំសូមឧទ្ទិស ស្នាដៃមួយនេះ ជូនដល់សិស្សនិសិ្សត ក៏ដូចជាប្រជាពលរដ្ឋគ្រប់រូប បានរីករាយជាមួយនឹងការអានរបស់ខ្លួន និងសូមជូនពរឲ្យបានសម្រេចនូវគោលដៅសិក្សា និងទទួលជោគជ័យគ្រប់ភារកិច្ចរៀងៗខ្លួន ។

# មាតិកា

ទំព័រ


**សេចក្តីផ្តើម** ............................................................ ១

**ជំពូកទី១.សញ្ញាណទូទៅនៃបណ្តឹងក្នុងរឿងក្តីព្រហ្មទណ្ឌ**

**ផ្នែកទី១. និយមន័យ និងគោលបំណង** .................................... ៥

កថាខណ្ឌទី១. និយមន័យ ................................................ ៥

កថាខណ្ឌទី២.គោលបំណង ................................................ ៥

**ផ្នែកទី២. គោលការណ៍ទូទៅនៃបណ្តឹង** .................................... ៦

កថាខណ្ឌទី១. បណ្តឹងអាជ្ញា ................................................ ៦

កថាខណ្ឌទី២. បណ្តឹងរដ្ឋប្បវេណី ........................................... ៧

**ជំពូកទី២.ប្រភេទ និងវិធីសាស្ត្រនៃការធ្វើបណ្តឹង**

**ផ្នែកទី១. ប្រភេទបណ្តឹងក្នុងរឿងក្តីព្រហ្មទណ្ឌ** ................................ ៩

កថាខណ្ឌទី១. ប្រភេទបណ្តឹងនៅដំណាក់កាលកកើតដំបូងនៃបទល្មើស .................. ៩

កថាខណ្ឌទី២. ប្រភេទនៃបណ្តឹងតវ៉ា ............................................ ៩

**ផ្នែកទី២. វិធីសាស្ត្រនៃការធ្វើបណ្តឹង** ....................................... ១០

កថាខណ្ឌទី១. វិធីសាស្ត្រនៃការធ្វើបណ្តឹងអាជ្ញា ................................ ១០

ក. ការចាប់ផ្តើមបណ្តឹងអាជ្ញា ................................................ ១០

១. ការចាប់ផ្តើមបណ្តឹងធ្វើបណ្តឹងអាជ្ញាដោយអយ្យការ .............................. ១០

២. ការចាប់ផ្តើមចលនានៃបណ្តឹងអាជ្ញាដោយជនរងគ្រោះ ............................ ១១

ខ. បែបបទនៃបណ្តឹងអាជ្ញា ................................................. ១២

១. កិច្ចបឋមនៃការធ្វើបណ្តឹងអាជ្ញា .......................................... ១២

១.១. មធ្យោបាយធ្វើបណ្តឹង ................................................. ១២

១.២. ការតម្កល់រឿងទុកឥតចាត់ការ ........................................... ១៥

១.៣. ការសម្រេចចោទប្រកាន់ ................................................ ១៧

២. ទម្រង់នៃការបន្តបណ្តឹងអាជ្ញា ..................................................... ១៧
២.១. ករណីបើកការស៊ើបសួរ ..................................................... ១៧
២.២. ករណីបញ្ជូនទៅជំនុំជម្រះផ្ទាល់ ..................................................... ១៩
២.៣. នីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ..................................................... ២១
គ. មូលហេតុនៃការរលត់បណ្តឹងអាជ្ញា ..................................................... ២៣
កថាខណ្ឌទី២. វិធីសាស្រ្តនៃការធ្វើបណ្តឹងរដ្ឋប្បវេណី..................................................... ២៥
ក. ការចាប់ផ្តើមនៃបណ្តឹងរដ្ឋប្បវេណី ..................................................... ២៥
១. ការចាប់ផ្តើមដោយជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់ ..................................................... ២៥
២. ការចាប់ផ្តើម ឬ បន្តដោយសិទ្ធិវ័ន្តនៃជនរងគ្រោះ ..................................................... ២៥
ខ. ការធ្វើបណ្តឹងរដ្ឋប្បវេណី ..................................................... ២៧
១. បណ្តឹងរដ្ឋប្បវេណី ដែលធ្វើឡើងជាមួយបណ្តឹងអាជ្ញា ..................................................... ២៧
២. បណ្តឹងរដ្ឋប្បវេណីដែលធ្វើឡើងដាច់ដោយឡែក ..................................................... ២៨
គ. មូលហេតុនៃការរលត់បណ្តឹងរដ្ឋប្បវេណី ..................................................... ២៨

## ជំពូកទី៣. ការធ្វើបណ្តឹងតវ៉ា

**ផ្នែកទី ១. បណ្តឹងតវ៉ាសាមញ្ញ** ..................................................... ៣០
កថាខណ្ឌទី ១. បណ្តឹងទាស់ ..................................................... ៣០
កថាខណ្ឌទី ២. បណ្តឹងឧទ្ធរណ៍ ..................................................... ៣១
កថាខណ្ឌទី ៣. បណ្តឹងសាទុក្ខ ..................................................... ៣៤
**ផ្នែកទី ២. បណ្តឹងតវ៉ាវិសាមញ្ញ** ..................................................... ៣៧
កថាខណ្ឌទី ១. បណ្តឹងសើរើ ..................................................... ៣៧
**សេចក្តីសន្និដ្ឋាន និង អនុសាសន៍** ..................................................... ៣៩
**គន្ថនិទ្ទេស**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ជាក់ស្តែងនៅក្នុងទំនាក់ទំនងនៃការរស់នៅរបស់មនុស្សគ្រប់រូប គឺមានគ្រប់រស់ជាតិទាំងសេចក្តីសុខ សុភមង្គល ភាពលំបាកវេទនា ទុក្ខសោកគ្រប់បែបយ៉ាង។ ស្ថានភាពទាំងអស់នេះពេលខ្លះកើតឡើងដោយធម្មជាតិ ដោយឯកឯង ហើយពេលខ្លះទៀតក៏កើតឡើងដោយសារសកម្មភាពរបស់មនុស្ស។ ដោយសារតែសង្គមមានការប្រកួតប្រជែង ដណ្តើមផលប្រយោជន៍គ្នាទៅវិញទៅមកដើម្បីបំពេញសេចក្តីតម្រូវការផ្ទាល់ខ្លួនគ្មានព្រំដែនឡើយ ដែលកត្តានេះបានធ្វើឲ្យមនុស្សហ៊ានប្រព្រឹត្តនូវអំពើដែលប្រាសចាកសីលធម៌ ហើយសង្គមមិនទទួលស្គាល់។ អំពើទាំងអស់នេះមិនត្រឹមតែធ្វើឲ្យមានការប៉ះពាល់ដល់មនុស្សគ្រប់រូបនោះទេ ប៉ុន្តែវាបានបង្កផលប៉ះពាល់ដល់សង្គមជាតិទៀតផង។ អំពើដែលឥតសណ្តាប់ធ្នាប់ គ្មានសីលធម៌ទាំងអស់នេះ អាចស្តែងចេញជាបទល្មើសជាច្រើន ដូចជាការកាប់សម្លាប់ រំលោភ លួច ឆក់ ប្លន់ អំពើហិង្សា និងអំពើផ្សេងទៀតដែលសង្គមបានថ្កោលទោស។ ដោយសារអំពើទាំងនោះហើយ សង្គមចាំបាច់ត្រូវតែបង្កើតឡើងនូវមធ្យោបាយក្នុងការ បង្ការ បង្ក្រាបនិងទប់ស្កាត់នូវអំពើទាំងនោះមិនឲ្យកើតមានឡើង។

មធ្យោបាយសំខាន់ៗ ដែលប្រទេសនានាលើសកលលោក បានបង្កើតឡើងក្នុងន័យដោះស្រាយលើបញ្ហានេះ គឺការរៀបចំតាក់តែងឡើងនូវលិខិតបទដ្ឋានគតិយុត្តិផ្សេងៗ ដើម្បីគ្រប់គ្រង និងធ្វើចំណាត់ការទៅលើអំពើគ្រោះថ្នាក់ទាំងអស់នោះ។ ជាក់ស្តែងនៅក្នុងប្រទេសកម្ពុជាក្រោយពីមានការរៀបចំបោះឆ្នោត អ៊ុន តាក់ (អង្គការសហប្រជាជាតិ) នៅក្នុងឆ្នាំ ១៩៩៣មក កម្ពុជាបានបង្កើតឲ្យមានឡើងវិញនូវរបប រាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ។ តាមរយៈច្បាប់រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ ដែលរៀបចំឡើងជាច្បាប់គ្រឹះដើម្បីរក្សារបៀបរៀបរយសង្គម ក្នុងការគោរពច្បាប់ ការការពារសិទ្ធិមនុស្ស ការអនុវត្តច្បាប់ និងដំណើរការនៅក្នុងប្រព័ន្ធតុលាការ ដោយមានកង្វល់ទាក់ទងទៅនឹងរចនាសម្ព័ន្ធច្បាប់ ប្រព័ន្ធតុលាការ និងសេចក្តីត្រូវការចាំបាច់នៃគ្រានោះ អ៊ុន តាក់ បានបង្កើតច្បាប់អនុវត្តនៅក្នុងគ្រានោះជាបណ្តោះអាសន្ន ព្រមទាំងបទបញ្ញត្តិទាំងឡាយដែលស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ សម្រាប់អនុវត្តនៅក្នុងប្រទេសកម្ពុជា នាសម័យអន្តរកាលនោះ ឬហៅកាត់ថាច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាល ។ រហូតមកដល់ឆ្នាំ២០០៧ រាជរដ្ឋាភិបាលបានបង្កើតឲ្យមាននូវក្រមនីតិវិធីព្រហ្មទណ្ឌ ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា តាមរយៈព្រះរាជក្រឹត្យ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ដែលបានអនុម័តដោយរដ្ឋសភា នៅថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០០៧។

នីតិវិធីព្រហ្មទណ្ឌគឺ សំដៅលើដំណើរការនៃការប្រព្រឹត្តទៅ នៅក្នុងការដោះស្រាយ រឿងក្តីព្រហ្មទណ្ឌ ហើយវានឹងបង្ហាញដល់អ្នកសិក្សា ឲ្យយល់ដឹងពីការអនុវត្តនីតិវិធីនិងវិធានទាំងឡាយដែលបានបកស្រាយដោយភាគីដែលបានចូលរួមនៅក្នុងដំណើរនៃកិច្ចរបស់តុលាការ។ នីតិវិធី និងវិធានទាំងនោះ មានប្រភពពីច្បាប់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ច្បាប់អន្តរជាតិដែលរួមមាន សន្ធិសញ្ញា អនុសញ្ញា និងពិធីសារផ្សេងៗទៀត។ ក្រៅពីនោះមានច្បាប់ លិខិតបទដ្ឋានគតិយុត្តិដទៃទៀតដែលសភា និងស្ថាប័ននានារបស់កម្ពុជាបានអនុម័ត។

នៅក្នុងនីតិវិធីព្រហ្មទណ្ឌ មានកំណត់យ៉ាងច្បាស់លាស់អំពីទម្រង់នៃបណ្តឹង និងបែបបទនៃការធ្វើបណ្តឹង ដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់ និងការអនុវត្តន៍ជាក់ស្តែងនៅក្នុងប្រព័ន្ធយុត្តាធិការនៅកម្ពុជា ។ ដូចនេះ វាទាមទារឲ្យភាគីពាក់ព័ន្ធទាំងអស់ត្រូវស្វែងយល់ឲ្យបានច្បាស់អំពីគោលការណ៍ និងបែបបទទាំងនោះ ។

## ២. ចំណោទបញ្ហា

គួរបញ្ជាក់ផងដែរថា កាលណាមានបទល្មើសព្រហ្មទណ្ឌមួយកើតឡើង វានាំឲ្យកើតមានបណ្តឹងនៅក្នុងរឿងក្តីព្រហ្មទណ្ឌកើតឡើងដែរ ដែលយើងឃើញថា វាអាចមានរូបភាពជាការប្តឹងឲ្យដាក់ទោសចំពោះជនល្មើស និងការប្តឹងឲ្យសងនូវព្យសនកម្មដែលបានកើតឡើង។ ដូចនេះ ៖

- តើបណ្តឹងនៅក្នុងរឿងក្តីព្រហ្មទណ្ឌមានសញ្ញាណយ៉ាងដូចម្តេច?
- តើទម្រង់នៃបណ្តឹងនៅក្នុងរឿងក្តីព្រហ្មទណ្ឌ មានប៉ុន្មានប្រភេទ?
- តើវិធីសាស្ត្រធ្វើបណ្តឹង នៅក្នុងទម្រង់នីមួយៗ ឲ្យបានត្រឹមត្រូវតាមច្បាប់កំណត់ត្រូវធ្វើឡើងយ៉ាងដូចម្តេច?
- បន្ទាប់ពីទទួលបានសេចក្តីសម្រេចលើបណ្តឹងនេះហើយ តើភាគីអាចធ្វើការប្តឹងតវ៉ាបានដែរឬទេ ក្នុងករណីដែលខ្លួនមិនសុខចិត្តនឹងសេចក្តីសម្រេចនោះ?

## ៣. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ប្រភេទ និងវិធិសាស្ត្រនៃការធ្វើបណ្តឹងក្នុងរឿងក្តីព្រហ្មទណ្ឌ នឹងបង្ហាញអំពីសញ្ញាណទូទៅនៃបណ្តឹងនៅក្នុងរឿងក្តីព្រហ្មទណ្ឌ ដែលក្នុងផ្នែកនេះ អ្នកសិក្សានឹងបានស្វែងយល់ពីប្រភេទ និងគោលការណ៍ទូទៅនៃបណ្តឹងនីមួយៗ ។ ក្រៅពីនោះប្រធានបទនេះនឹងបង្ហាញផងដែរអំពី វិធីសាស្ត្រ ឬ បែបបទនៃការចាប់ផ្តើមធ្វើបណ្តឹងមួយ ដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ដោយមិនធ្វើការបកស្រាយឈានដល់ដំណាក់កាលនីតិវិធីរបស់ចៅក្រមស៊ើបសួរ និងការជំនុំជម្រះនោះទេ ។ បន្ថែមលើនោះ ក្នុងប្រធានបទនេះ នឹងនិយាយពីផ្លូវនៃការប្តឹងតវ៉ា ទៅនឹងសេចក្តីសម្រេចរបស់តុលាការជំបូងផងដែរ ។

ការប្រើប្រាស់ឯកសារនៃការស្រាវជ្រាវចំពោះប្រធានបទនេះ គឺផ្តោតជាសំខាន់ទៅលើក្រម ព្រហ្មទណ្ឌ (ឆ្នាំ ២០០៩) ក្រមនីតិវិធីព្រហ្មទណ្ឌ (ឆ្នាំ ២០១០) និងច្បាប់ពាក់ព័ន្ធផ្សេងទៀតដែលប្រើប្រាស់ក្នុងប្រព័ន្ធតុលាការនាពេលបច្ចុប្បន្ននេះ ។

## ៤. សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវ និងចងក្រងជាឯកសារចំពោះប្រធានបទនេះ បានផ្តល់សារៈសំខាន់យ៉ាងខ្លាំង ចំពោះអ្នកសិក្សាផ្នែកនីតិព្រហ្មទណ្ឌ បុគ្គលដែលបម្រើការងារក្នុងប្រព័ន្ធតុលាការនៅកម្ពុជា និង ប្រជាពលរដ្ឋទាំងអស់ ឲ្យបានយល់ដឹងពីគោលការណ៍ទូទៅនៃបណ្តឹង និងនីតិវិធីមួយចំនួនដែល ត្រូវអនុវត្តន៍ ដើម្បីចងក្រងឯកសារទុកសម្រាប់អ្នកជំនាន់ក្រោយ និងរៀបចំបណ្តឹងមួយដាក់ទៅកាន់ តុលាការឲ្យធ្វើការដោះស្រាយ ។ នៅពេលដែលបុគ្គលទាងអស់ខាងលើ ទទួលបានចំនេះដឹងទាំង នេះ ហើយពួកគេនឹងអនុវត្តន៍បានត្រឹមត្រូវ ជាពិសេសប្រជាពលរដ្ឋនឹងទទួលបានយុត្តិធម៌ពី តុលាការ ចំពោះអំពើល្មើសដែលខ្លួនបានទទួល ។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីទទួលបានឯកសារ និងព័ត៌មានទាំងអស់ដើម្បីយកមកចងក្រងឯកសារ គឺបានឆ្លងកាត់ ការស្រាវជ្រាវដូចខាងក្រោម ៖

- ប្រើប្រាស់ឯកសារជាចម្បងមួយចំនួនដូចជា ក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ និងក្រមនីតិវិធី ព្រហ្មទណ្ឌឆ្នាំ ២០០៧ សៀវភៅមេរៀនដែលសាស្ត្រាចារ្យផ្នែកច្បាប់បានចងក្រង ។
- ការចុះស្រាវជ្រាវស្វែងរកព័ត៌មាន និងការអនុវត្តន៍ជាក់ស្តែង នៅតុលាការដំបូងរាជធានី ភ្នំពេញ ។
- ច្បាប់ពាក់ព័ន្ធផ្សេងៗទៀត ។

បន្ទាប់ពីទទួលបានឯកសារ និងព័ត៌មានទាំងអស់នេះហើយ គឺត្រូវបានយកមកពិនិត្យ និង វិភាគយ៉ាងច្បាស់លាស់ មុននឹងជ្រើសរើសមកចងក្រងជាខ្លឹមសារសម្រាប់អត្ថបទមួយនេះ ។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ខ្លឹមសារនៃប្រធានបទនេះ ត្រូវបានបែងចែកជាផ្នែកដូចខាងក្រោម ៖

- សេចក្តីផ្តើម
- ជំពូកទី ១ ស្តីពី **សញ្ញាណទូទៅនៃបណ្តឹងនៅក្នុងរឿងក្តីព្រហ្មទណ្ឌ** ៖ ផ្នែកនេះនឹងបង្ហាញពី និយមន័យ គោលបំណង និងគោលការណ៍ទូទៅនៃបណ្តឹងក្នុងប្រភេទនីមួយៗ ដោយមាន ភ្ជាប់ឧទាហរណ៍ផងដែរ ។
- ជំពូកទី ២ ស្តីពី **ប្រភេទ និងវិធីសាស្ត្រនៃការធ្វើបណ្តឹង** ៖ ដោយផ្នែកនេះ មានបង្ហាញពីនីតិវិធី

នៃការធ្វើបណ្តឹងក្នុងទម្រង់នីមួយៗ និងនីតិវិធីមួយចំនួននៃការធ្វើបណ្តឹងតវ៉ា ។

- ជំពូកទី៣ **ការធ្វើបណ្តឹងតវ៉ា** ៖ ដែលផ្នែកនេះនឹងត្រូវបកស្រាយ អំពីនីតិវិធីនៃការធ្វើបណ្តឹងតវ៉ាទៅតាមប្រភេទរបស់វានីមួយៗ ។
- **សេចក្តីសន្និដ្ឋាន រួមនឹងអនុសាសន៍** ៖ សរុបខ្លឹមសារនៃប្រធានបទ និងលើកយកបញ្ហាប្រឈមមួយចំនួននៅក្នុងប្រធានបទ រួមទាំងផ្តល់ដំណោះស្រាយផងដែរ ។

# ជំពូកទី១. សញ្ញាណទូទៅនៃបណ្តឹងក្នុងរឿងក្តីព្រហ្មទណ្ឌ

ជាទូទៅ នៅពេលដែលកើតមានអំពើអសកម្មណាមួយកើតឡើង នៅក្នុងជីវភាពរស់នៅ ដែលវាបានបំពានលើសណ្តាប់ធ្នាប់នយោបាយ សេដ្ឋកិច្ច និងរបៀបរៀបរយសង្គម និងជះឥទ្ធិពល អាក្រក់ទៅលើសិទ្ធិសេរីភាពបុគ្គល ជាហេតុនាំឲ្យរដ្ឋត្រូវប្រើប្រាស់នូវវិធានច្បាប់ និងមធ្យោបាយផ្សេងៗ ដើម្បីបង្ការ និងប្រឆាំងទៅនឹងអំពើទាំងនោះ ។ អំពើអសកម្មទាំងនោះត្រូវបានច្បាប់កំណត់ថាជាបទល្មើស ។ ដោយផ្អែកតាមច្បាប់ព្រហ្មទណ្ឌកម្ពុជា បង្ហាញថា រាល់អំពើទាំងឡាយណាដែលបានកំណត់ថាជាបទល្មើសព្រហ្មទណ្ឌ នឹងត្រូវទទួលទោសតាមច្បាប់ព្រហ្មទណ្ឌ ។ ដើម្បីធ្វើចំណាត់ការទៅលើបុគ្គលដែលបានប្រព្រឹត្តបទល្មើសនោះ ឲ្យទទួលទោសតាមច្បាប់ព្រហ្មទណ្ឌ គឺត្រូវតែមានការដាក់ពាក្យបណ្តឹង ទៅស្ថាប័នតុលាការដែលមានសមត្ថកិច្ចដោះស្រាយលើបណ្តឹងនេះ ។

## ផ្នែកទី១. និយមន័យ និងគោលបំណង

### កថាខណ្ឌទី១. និយមន័យ

ជាទូទៅ មុននឹងឈានចូលដល់ការពន្យល់អត្ថន័យ នៃពាក្យថាបណ្តឹងនៅក្នុងរឿងក្តីព្រហ្មទណ្ឌអ្នកសិក្សាគ្រប់រូបគប្បីយល់ពីអត្ថន័យ នៃពាក្យគន្លឹះជាមុនសិន។ ពាក្យថាបណ្តឹងនៅក្នុងរឿងក្តីព្រហ្មទណ្ឌ បានលេចចេញនូវពាក្យគន្លឹះពីរ គឺ **បណ្តឹង + ព្រហ្មទណ្ឌ** ដែលយោងតាមវចនានុក្រម របស់សម្តេចព្រះសង្ឃរាជ ជួន ណាត បានឲ្យនិយមន័យចំពោះ ពាក្យទាំងពីរនេះថា៖

- **បណ្តឹង** គឺជាពាក្យបណ្តឹង ឬសេចក្តីដែលប្តឹងអំពីអ្វីមួយ (ពាក្យ ឬសំបុត្រ)។
- **ព្រហ្មទណ្ឌ** គឺជាឈ្មោះច្បាប់ដែលរាជការបញ្ញត្តិ សម្រាប់ពិភាក្សា កាត់ទោស ឬពិន័យដល់មនុស្សដែលប្រព្រឹត្តល្មើស នឹងបញ្ញត្តិសម្រាប់ប្រទេស។

ដូចនេះ បណ្តឹងនៅក្នុងរឿងក្តី ព្រហ្មទណ្ឌ គឺជាពាក្យបណ្តឹង ឬសេចក្តីដែលប្តឹងទៅលើអំពើអ្វីមួយដែលច្បាប់ចាត់ទុកថាជាបទល្មើស ក្នុងគោលបំណងសម្រាប់កាត់ទោស ឬដាក់ពិន័យដល់ជនដែលបានប្រព្រឹត្តនោះ។

ដោយផ្អែកតាមការពិចារណា ទៅលើនិយមន័យខាងលើនេះ និងគោលការណ៍នៃច្បាប់ព្រហ្មទណ្ឌនាពេលបច្ចុប្បន្ន បណ្តឹងនៅក្នុងរឿងក្តីព្រហ្មទណ្ឌ គឺជាបណ្តឹងដែលធ្វើឡើងនៅពេលដែលមានបទល្មើសព្រហ្មទណ្ឌមួយកើតឡើង ទៅកាន់តុលាការផ្នែកព្រហ្មទណ្ឌ ដើម្បីធ្វើចំណាត់ការទៅលើជនដែលប្រព្រឹត្តបទល្មើសនេះ ដោយចេញជាសេចក្តីសម្រេច ។

### កថាខណ្ឌទី២.គោលបំណង

ជាការពិតណាស់ បទល្មើសព្រហ្មទណ្ឌបានបង្កមហន្តរាយ យ៉ាងធ្ងន់ធ្ងរដល់បុគ្គលព្រមទាំងសង្គមជាតិទាំងមូល ។ ដូចនេះច្បាប់បានបង្កើតគោលការណ៍ និងនីតិវិធីនៃការធ្វើបណ្តឹង ដើម្បី

បង្ការនិងទប់ស្កាត់នូវរាល់អំពើល្មើសទាំងនោះ ។ បណ្តឹងដែលបានធ្វើឡើងនៅក្នុងរឿងក្តីព្រហ្មទណ្ឌមួយ គឺមានគោលបំណងដើម្បីចាប់ខ្លួនបុគ្គលដែលបានប្រព្រឹត្តបទល្មើស យកមកផ្តន្ទាទោសទៅតាមផ្លូវច្បាប់ ព្រមទាំងផ្តល់សំណងទាំងឡាយចំពោះព្យសនកម្មដែលបានបង្កឡើងដោយអំពើនោះ។

ដោយសារបទល្មើសព្រហ្មទណ្ឌគឺ ជាអំពើដែលប៉ះពាល់ដល់សណ្តាប់ធ្នាប់ និងរបៀបរៀបរយសង្គមជា សាធារណៈយ៉ាងដូច្នេះ បុគ្គលគ្រប់រូបអាចធ្វើបណ្តឹងព្រហ្មទណ្ឌបាន ។ ចំណែកឯការផ្តន្ទាទោសដល់ជនល្មើស គឺស្ថិតក្រោមការកំណត់ដោយច្បាប់ជាធរមាន ។ ដោយឡែកសំណងចំពោះព្យសនកម្មដែលបានកើតឡើងដោយបទល្មើសនោះ គឺកើតចេញតាមរយៈការទាមទាររបស់ជនរងគ្រោះ ឬអ្នកតំណាងរបស់ជនរងគ្រោះ។ តាមរយៈនេះអាចបង្ហាញឲ្យឃើញថា នៅក្នុងរឿងក្តីព្រហ្មទណ្ឌមួយ មានការកើតឡើងនូវបណ្តឹងជាពីរទម្រង់ គឺការប្តឹងដាក់ទោសជនល្មើស និងការប្តឹងទាមទារសំណងចំពោះព្យសនកម្មរបស់ជនរងគ្រោះ។

**ផ្នែកទី២. គោលការណ៍ទូទៅនៃបណ្តឹង**

នៅពេលដែលមានបទល្មើសព្រហ្មទណ្ឌមួយកើតឡើង នាំឲ្យលេចចេញនូវបណ្តឹងពីរ គឺបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី ដែលគោលការណ៍នៃបណ្តឹងទាំងពីរនេះនឹងត្រូវ លើកយកមកបកស្រាយដូចខាងក្រោម៖

**កថាខណ្ឌទី១. បណ្តឹងអាជ្ញា**

បណ្តឹងអាជ្ញា ឬបណ្តឹងព្រហ្មទណ្ឌ គឺជាទម្រង់មួយក្នុងចំណោមបណ្តឹងពីរ ដែលធ្វើឡើងក្នុងរឿងក្តីព្រហ្មទណ្ឌ។

ដោយផ្អែកតាមបញ្ញត្តិមាត្រា១ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ថា "ក្រមនីតិវិធីព្រហ្មទណ្ឌ មានគោលបំណងកំណត់អំពីវិធានទាំងឡាយដែលត្រូវគោរព និងប្រព្រឹត្តតាមដោយហ្មត់ចត់ ដើម្បីកំណត់ឲ្យបានច្បាស់លាស់ នូវអត្ថិភាពនៃបទល្មើសណាមួយ" ។ បទបញ្ញត្តិនៃក្រមនេះត្រូវបានយកមកអនុវត្ត ចំពោះរឿងក្តីព្រហ្មទណ្ឌ កាលណាពុំមានវិធានដោយឡែកចែងដោយច្បាប់ពិសេសទេនោះ។ ដូចនេះយើងឃើញថា ដើម្បីស្វែងរកអត្ថិភាពនៃបទល្មើស ចាំបាច់ត្រូវតែមានការដាក់ពាក្យបណ្តឹងទៅតុលាការដែលមានសមត្ថកិច្ច ហើយរាល់របៀបរបបនៃការដាក់ពាក្យបណ្តឹងរួមទាំងច្បាប់ដែលត្រូវប្រើប្រាស់ និងនីតិវិធីដែលត្រូវអនុវត្តដើម្បីដោះស្រាយបណ្តឹងនោះ គឺត្រូវអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ ។

តើបណ្តឹងប្រភេទណា ជាបណ្តឹងស្វែងរកអត្ថិភាពនៃបទល្មើស ?

បណ្តឹងអាជ្ញា គឺជាបណ្តឹងដែលមានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញអោយឃើញពីពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននេះតាមច្បាប់កំណត់ [1]។ បណ្តឹងអាជ្ញា អនុវត្តទៅលើបុគ្គលគ្រប់រូប ទាំងរូបវន្តបុគ្គល នីតិបុគ្គល ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬ ស្ថានភាពឯទៀតឡើយ[2] ។ ដែលមានន័យថា បណ្តឹងនេះត្រូវបានគេអនុវត្តទៅលើគ្រប់បុគ្គលទាំងអស់ដែលបានប្រព្រឹត្តបទល្មើស ទោះបីជាបុគ្គលនោះជារូបវន្តបុគ្គល ឬនីតិបុគ្គលក៏ដោយ ហើយមិនបានប្រកាន់នូវពូជសាសន៍ ឬជាតិ កំណើត សាសនាជាដើម ឡើយ ឲ្យតែប្រព្រឹត្តបទល្មើសណាមួយដែលច្បាប់បានកំណត់។

**ឧទាហរណ៍៖** សមត្ថកិច្ចបានប្រទះឃើញសាកសពបុរសម្នាក់ នៅក្នុងគំនរសម្រាមមួយកន្លែង។ នៅពេលពិនិត្យទៅលើសាកសពរួចរាល់ហើយបានបង្ហាញឲ្យឃើញថា បុរសនោះបានស្លាប់ដោយសារការអាករ ។ បន្ទាប់ពីពិនិត្យ ទីកន្លែងនិងធ្វើកោសល្យវិច័យ លើសាកសពរួចរាល់ហើយ សមត្ថកិច្ចបានកសាងសំណុំរឿងបញ្ជូនទៅអយ្យការ។ នៅពេលដែលអយ្យការបានទទួលសំណុំរឿងនេះហើយ ក៏នាំឲ្យមានការចាប់ផ្តើមបណ្តឹងអាជ្ញាកើតឡើង។

ផ្អែកតាមគោលបំណងនៃបណ្តឹងអាជ្ញាដែលបានបញ្ជាក់ខាងលើថា ការធ្វើបណ្តឹងអាជ្ញាក្នុងករណីឧទាហរណ៍នេះមានន័យថា គឺត្រូវរកឲ្យឃើញថា តើបទល្មើសនេះកើតឡើងយ៉ាងដូចម្តេច និងស្វែងរកថាអ្នកណាជាជនល្មើសពិតប្រាកដ ដើម្បីចាប់ខ្លួនជននោះមកផ្តន្ទាទោសតាមច្បាប់។

**កថាខណ្ឌទី២. បណ្តឹងរដ្ឋប្បវេណី**

ក្រៅពីបណ្តឹងអាជ្ញា ដែលមានគោលបំណងក្នុងការរកឲ្យឃើញនូវអត្ថិភាពនៃបទល្មើស និងស្វែងរកជនល្មើសមកផ្តន្ទាទោសទៅតាមផ្លូវច្បាប់នោះ។ នៅពេលដែលបទល្មើសកើតឡើង នាំឲ្យលេចចេញផងដែរនូវ ការទាមទាររបស់ជនរងគ្រោះ ដើម្បីតបស្នងចំពោះការខូចខាតដែលបានកើតឡើងដោយសារបទល្មើស។

តើបណ្តឹងប្រភេទណា ដែលមានគោលបំណងទាមទារចំពោះការខូចខាត ដែលបង្កឡើងដោយបទល្មើស?

បណ្តឹងរដ្ឋប្បវេណី គឺជាបណ្តឹងមួយដែលមានគោលបំណងទាមទារឲ្យមានការជួសជុលការខូចខាត ដែលបណ្តាលមកពីអំពើល្មើសដែលបង្កលើជនរងគ្រោះ ហើយក្នុងគោលបំណងនេះនឹង

[1] មាត្រា២ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[2] មាត្រា៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

អាចឲ្យជនរងគ្រោះបានទទួលសំណងជំងឺចិត្តធន់ល្មមទៅនឹងព្យសនកម្ម ដែលខ្លួនបានទទួល[3]។

តាមរយៈគោលបំណងនេះបានបង្ហាញឲ្យឃើញថា ឲ្យតែមានការទាមទាររបស់ជនរងគ្រោះនោះ នាំឲ្យបណ្ដឹងរដ្ឋប្បវេណីកើតមានឡើង ដែលស្របទៅតាមបញ្ញត្តិច្បាប់ចែងផងដែរ គឺបណ្ដឹងរដ្ឋប្បវេណីត្រូវអនុវត្តដោយជនរងគ្រោះនៃបទល្មើស ។ បើទោះបីជាច្បាប់បានបញ្ញត្តិការពារផលប្រយោជន៍របស់ជនរងគ្រោះ ដោយផ្ដល់ឱកាសក្នុងការទាមទារសំណងខូចខាត ប៉ុន្តែជនរងគ្រោះមិនអាចធ្វើការទាមទារសំណងទៅតាមអំពើចិត្តនោះឡើយ ។ ជនរងគ្រោះអាចទទួលបានការជួសជុល លុះត្រាតែព្យសនកម្មត្រូវតែជាផលវិបាកផ្ទាល់នៃបទល្មើស និងជាព្យសនកម្មផ្ទាល់ខ្លួន ។ម្យ៉ាងវិញទៀត ព្យសនកម្មនោះ គឺត្រូវបានកើតឡើង និងនៅក្នុងពេលបច្ចុប្បន្នផងដែរ ។ ចំពោះទម្រង់នៃព្យសនកម្ម ដែលនឹងត្រូវទទួលបានការជួសជុល ត្រូវបានបែងចែកជាព្យសនកម្មខាងសម្ភារៈ ខាងរូបកាយ និងខាងផ្លូវចិត្ត[4] ។

ជនរងគ្រោះអាចទទួលបាននូវការជុសជុលព្យសនកម្ម ដែលបានកើតឡើងដោយជនដែលបង្កត្រូវបង់ជំងឺចិត្ត ឬសងទៅជនរងគ្រោះវិញនូវទ្រព្យសម្បត្តិ ដែលបានបាត់បង់ ឬដោយការធ្វើឲ្យដូចសភាពដើមវិញនូវទ្រព្យសម្បត្តិដែលបានបំផ្លិចបំផ្លាញ ឬធ្វើឲ្យខូចខាត[5] ។

**ឧទាហរណ៍៖ បុរស ក** បានវាយ**បុរស ខ** បណ្ដាលឲ្យបាក់ដៃខាងឆ្វេង ។ ដូចនេះ **បុរស ខ** បានដាក់ពាក្យប្ដឹង**បុរស ក** ទាមទារសំណងជំងឺចិត្ត ៥ពាន់ដុល្លារ ។

តាមរយៈឧទាហរណ៍នេះ យើងឃើញថា **បុរស ខ** បានទទួលរងព្យសនកម្មខាងផ្លូវកាយដោយបាក់ដៃខាងឆ្វេង ហើយគាត់បានដាក់ពាក្យបណ្ដឹង ក្នុងនាមជាដើមបណ្ដឹងរដ្ឋប្បវេណី ដោយទាមទារឲ្យ**បុរស ក** ជួសជុលព្យសនកម្មដែលគាត់ទទួលរង ។

[3] មាត្រា២ វាក្យខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[4] មាត្រា១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[5] មាត្រា១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

# ជំពូកទី២. ប្រភេទ និងវិធីសាស្ត្រនៃការធ្វើបណ្ដឹង

ដោយផ្អែកតាមបទបញ្ញត្តិនៃច្បាប់ រួមទាំងការអនុវត្តជាក់ស្ដែង នៅក្នុងរឿងក្ដីព្រហ្មទណ្ឌមួយ មានគពាក់ព័ន្ធទៅនឹងបណ្ដឹងជាច្រើនប្រភេទ ដូច្នេះយើងត្រូវស្វែងយល់ថាតើបណ្ដឹងនីមួយៗត្រូវធ្វើឡើងនៅដំណាក់កាលណាខ្លះ ? ហើយត្រូវអនុវត្តវិធីសាស្ត្រយ៉ាងដូចម្ដេចខ្លះក្នុងការធ្វើបណ្ដឹងទាំងនោះ ?

## ផ្នែកទី១. ប្រភេទបណ្ដឹងក្នុងរឿងក្ដីព្រហ្មទណ្ឌ

### កថាខណ្ឌទី១. ប្រភេទបណ្ដឹងនៅដំណាក់កាលកកើតដំបូងនៃបទល្មើស

ដូចដែលបានបង្ហាញនៅក្នុងគោលការណ៍ទូទៅនៃបណ្ដឹង នៅក្នុងជំពូកទី១ខាងលើ កាលណាមានបទល្មើសព្រហ្មទណ្ឌមួយកើតឡើង ត្រូវកើតចេញនូវបណ្ដឹងពីរប្រភេទ គឺបណ្ដឹងអាជ្ញា និងបណ្ដឹងរដ្ឋប្បវេណី ។

បណ្ដឹងអាជ្ញា និងបណ្ដឹងរដ្ឋប្បវេណី គឺជាបណ្ដឹងពីរផ្សេងគ្នា ដែលធ្វើឡើងដើម្បីរកឲ្យឃើញនូវភាពកើតមានពិតប្រាកដនៃបទល្មើស និងផ្ដន្ទាទោសជនល្មើសទៅតាមច្បាប់កំណត់ ព្រមទាំងទាមទារឲ្យសងចំពោះការខូចខាត ដែលបានកើតឡើងដោយសារបទល្មើសនោះ ។

ក្រៅពីបណ្ដឹងទាំងពីរប្រភេទខាងលើនេះ ច្បាប់ក៏បានកំណត់អំពីប្រភេទបណ្ដឹងតវ៉ាជាច្រើនទៀត ដែលអាចធ្វើឡើងប្រឆាំងទៅនឹងសេចក្ដីសម្រេចរបស់តុលាការ ទៅលើបណ្ដឹងទាំងពីរនេះ ។

### កថាខណ្ឌទី២. ប្រភេទនៃបណ្ដឹងតវ៉ា

កាលណាភាគីនៃបណ្ដឹង (ជនរងគ្រោះ, ជនជាប់ចោទ) មិនសុខចិត្តទៅនឹងសេចក្ដីសម្រេចរបស់តុលាការ ច្បាប់បានផ្ដល់សិទ្ធឲ្យភាគីទាំងនេះអាចធ្វើការប្ដឹងតវ៉ា ដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់ខ្លួន ។ ក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់យ៉ាងច្បាស់លាស់អំពីប្រភេទនៃបណ្ដឹងតវ៉ា និងដំណាក់កាលនៃការធ្វើបណ្ដឹងនីមួយៗ ដើម្បីឲ្យមានអានុភាពតាមផ្លូវច្បាប់ ។

បណ្ដឹងតវ៉ាដែលភាគីអាចធ្វើបាន មានដូចខាងក្រោមៈ

- បណ្ដឹងទាស់: គឺជាបណ្ដឹងដែលធ្វើឡើងប្រឆាំងទៅនឹងសាលក្រម ឬសាលដីកាកំបាំងមុខ ។
- បណ្ដឹងឧទ្ធរណ៍: គឺជាបណ្ដឹង ដែលប្ដឹងសុំឲ្យកែប្រែសេចក្ដីសម្រេចរបស់សាលាដំបូង ដែលធ្វើឡើងទៅកាន់សាលាឧទ្ធរណ៍ ។
- បណ្ដឹងសាទុក្ខ: គឺជាបណ្ដឹង ដែលប្ដឹងទៅកាន់សភាព្រហ្មទណ្ឌនៃតុលាការកំពូលប្រឆាំងនឹងសាលដីកាសភាស៊ើបសួរ ទាក់ទងនឹងរឿងបត្យាប័ន និងសាលដីកាសម្រេចជាសមត្ថកិច្ចចុងក្រោយនៃសាលាឧទ្ធរណ៍ ។

- បណ្តឹងសើរើ: គឺជាបណ្តឹងដែលធ្វើឡើងប្រឆាំង ទៅនឹងសាលក្រម និងសាលដីកាស្ថាពរហើយមានអាជ្ញាអស់ជំនុំ ។

ចំពោះនីតិវិធីមួយចំនួននៃការធ្វើបណ្តឹងតវ៉ាទាំងអស់នេះ នឹងមានបកស្រាយនៅក្នុងជំពូកទី៣ នៃអត្ថបទនេះ ។

## ផ្នែកទី២. វិធីសាស្ត្រនៃការធ្វើបណ្តឹង

វិធីសាស្ត្រនៃការធ្វើបណ្តឹងនៅក្នុង រឿងក្តីព្រហ្មទណ្ឌ នឹងបង្ហាញអំពីបែបបទនៃការចាប់ផ្តើមធ្វើបណ្តឹង លក្ខណៈនៃការធ្វើបណ្តឹងក្នុងទម្រង់ទាំងពីរ (បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី) ក៏ដូចជានីតិវិធីមួយចំនួនដែលនឹងត្រូវធ្វើ ដើម្បីឈានដល់ដំណាក់កាលនៃការជំនុំជម្រះ ។ ជាក់ស្តែងនៅក្នុងរឿងក្តីព្រហ្មទណ្ឌមួយ មានការលេចឡើងនូវបណ្តឹងពីរ គឺបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី ហើយបណ្តឹងទាំងពីរនេះ ត្រូវធ្វើឡើងតាមនីតិវិធីផ្សេងៗគ្នា ដែលច្បាប់បានកំណត់ដើម្បីឲ្យវាមានអានុភាព ។

### កថាខណ្ឌទី១. វិធីសាស្ត្រនៃការធ្វើបណ្តឹងអាជ្ញា

#### ក. ការចាប់ផ្តើមបណ្តឹងអាជ្ញា

ជាទូទៅដើម្បីឲ្យបណ្តឹងអាជ្ញាមួយអាចដំណើរការទៅបាន ឈានដល់ការជំនុំជម្រះ និងចេញជាសេចក្តីសម្រេច គឺត្រូវតែស្វែងយល់ថា តើបណ្តឹងអាជ្ញានេះចាប់ផ្តើមយ៉ាងដូចម្តេច? ហើយបុគ្គលណា ដែលមានសិទ្ធិចាប់ផ្តើមបណ្តឹងនេះបាន? យោងតាមស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិអំពីការចាប់ផ្តើមនៃបណ្តឹងអាជ្ញា ដែលបែងចែកជាពីរប្រភេទ គឺការចាប់ផ្តើមបណ្តឹងដោយអយ្យការ និងការចាប់ផ្តើមចលនាបណ្តឹងដោយជនរងគ្រោះ ដែលនឹងត្រូវបកស្រាយខាងក្រោម៖

##### ១. ការចាប់ផ្តើមបណ្តឹងធ្វើបណ្តឹងអាជ្ញាដោយអយ្យការ

ដោយផ្អែកតាមកម្មវត្ថុនៃបណ្តឹងអាជ្ញា គឺធ្វើឡើងប្រឆាំងទៅនឹងបុគ្គលគ្រប់រូបដែល បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ទាំងរូបវន្តបុគ្គល និងនីតិបុគ្គល ដើម្បីការពារផលប្រយោជន៍ជាសាធារណៈ ។ យោងតាមមាត្រា៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់ផងដែរថា "បណ្តឹងអាជ្ញាត្រូវអនុវត្តក្នុងនាមផលប្រយោជន៍ទូទៅដោយអយ្យការ" ។ អយ្យការធ្វើការចោទប្រកាន់ពីបទល្មើស និងសុំឲ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ។ តាមន័យនេះ បានបង្ហាញថា មានតែស្ថាប័នអយ្យការតែមួយគត់ដែល គឺជាអ្នកចាប់ផ្តើមបណ្តឹងអាជ្ញាដោយដើរតួនាទីជាម្ចាស់បណ្តឹង ក្នុងការការពារផលប្រយោជន៍ទូទៅ ។ អយ្យការចាប់ផ្តើមបណ្តឹងអាជ្ញា ដោយធ្វើការចោទប្រកាន់ទៅលើអ្នកប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ តាមរយៈដីកាបញ្ជូនរឿងឲ្យស៊ើបសួរ

រួចបញ្ជូនដីការនេះទៅចៅក្រមស៊ើបសួរ ដើម្បីបើកសមត្ថកិច្ចឲ្យចៅក្រមស៊ើបសួរ ដែលមានតួនាទីស៊ើបសួរស្វែងរកការពិត ។

ជាធម្មតាចំពោះរឿងក្តីព្រហ្មទណ្ឌ ដែលទើបតែចាប់ផ្តើមដំណើរការ គឺស្ថិតក្នុងសមត្ថកិច្ចសាលាដំបូងរាជធានី-ខេត្ត ។ ចំពោះស្ថាប័នអយ្យការនៅអមសាលាដំបូងនេះ គឺមានព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមសាលាដំបូង ដែលជាបុគ្គលមានសមត្ថកិច្ចក្នុងការចាប់ផ្តើមបណ្តឹងអាជ្ញា[6] ។

ចំពោះការអនុវត្តជាក់ស្តែង ការចាប់ផ្តើមបណ្តឹងអាជ្ញាដោយអយ្យការដែលមានព្រះរាជអាជ្ញាដើរតួជាម្ចាស់បណ្តឹងនេះ គឺជានីតិវិធីដែលគ្រប់តុលាការរាជធានី-ខេត្តទាំងអស់ បានយកមកអនុវត្ត ហើយដំណើរការដោយរលូន និងមានប្រសិទ្ធិភាពផងដែរ ។

## ២. ការចាប់ផ្តើមចលនានៃបណ្តឹងអាជ្ញាដោយជនរងគ្រោះ

ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម អាចដាក់ពាក្យបណ្តឹងដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ ។ ពាក្យបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមានអានុភាពប្តឹងដល់ ចៅក្រមស៊ើបសួរអំពីបណ្តឹងអាជ្ញា នៅក្នុងលក្ខខណ្ឌដែលចៅក្រមស៊ើបសួរត្រូវបញ្ជូនពាក្យបណ្តឹងនេះទៅព្រះរាជអាជ្ញា ដើម្បីធ្វើការត្រួតពិនិត្យ និងអនុវត្តតាមនីតិវិធីដែលមានចែងនៅក្នុងមាត្រា ១៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ហើយបន្ទាប់មកជនរងគ្រោះដែលប្តឹងនៅក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីនេះ ក៏ត្រូវបង់ប្រាក់តម្កល់ទុកស្របតាមនីតិវិធីនៃមាត្រា១៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ[7] ។

នៅក្នុងករណីដែលបុគ្គលបានប្រកាសថាខ្លួនជាអ្នករងគ្រោះនៃបទល្មើស អាចមានសិទ្ធិដាក់ពាក្យបណ្តឹងបានតាមរយៈការដាក់ពាក្យបណ្តឹងនៅចំពោះមុខមន្រ្តីនគរបាលយុត្តិធម៌ ឬអាចដាក់ពាក្យបណ្តឹងដោយផ្ទាល់ ទៅស្ថាប័នតុលាការដែលមានសមត្ថកិច្ចដោះស្រាយ និងជំនុំជម្រះ ។ ប៉ុន្តែករណីដែលបណ្តឹងដែលបានដាក់នោះគ្មានចំលើយ ឬត្រូវបានព្រះរាជអាជ្ញាតម្កល់ទុកឥតចាត់ការនោះជនរងគ្រោះក៏នៅតែមានសិទ្ធិប្តឹង ទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ទៅតាមនីតិវិធីដូចមានចែងនៅក្នុងមាត្រា៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ[8] ។

ដោយឡែកការចាប់ផ្តើមចលនានៃបណ្តឹងអាជ្ញាដោយជនរងគ្រោះ ដែលនៅក្នុងការអនុវត្តជាក់ស្តែង គេសង្កេតឃើញមិនទាន់មានការអនុវត្តនៅឡើយទេ ដោយសារតែគ្រប់បណ្តឹងអាជ្ញាទាំង

---

[6] មាត្រា២៨ ចំណុចទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[7] មាត្រា៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[8] មាត្រា៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

អស់ គឺព្រះរាជអាជ្ញាជាម្ចាស់នៃបណ្តឹង។ ដូចនេះព្រះរាជអាជ្ញាមិនអាចអសកម្ម ចំពោះភារកិច្ចរបស់ខ្លួន ដែលនាំឲ្យជនរងគ្រោះប្តឹងទៅកាន់ចៅក្រមស៊ើបសួរ រួចទើបចៅក្រមស៊ើបសួរបញ្ជូនត្រឡប់មកឲ្យខ្លួនវិញនោះទេ ។

**ខ. បែបបទនៃបណ្តឹងអាជ្ញា**

ការចាប់ផ្តើមនិងការធ្វើឲ្យមានដំណើរការ នៃបណ្តឹងអាជ្ញាមួយ គឺធ្វើឡើងដោយស្ថាប័នអយ្យការ ដែលមានព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ។ ដើម្បីឲ្យបណ្តឹងអាជ្ញាមួយ អាចឈានដល់ដំណាក់កាលនៃការស៊ើបសួរ និងជំនុំជម្រះ ព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារង ត្រូវអនុវត្តនីតិវិធីជាច្រើន ក្នុងការបង្កើតឡើងនូវបណ្តឹងតាមរយៈការចោទប្រកាន់របស់ខ្លួន ។

**១. កិច្ចបឋមនៃការធ្វើបណ្តឹងអាជ្ញា**

**១.១. មធ្យោបាយធ្វើបណ្តឹង**

បណ្តឹងអាជ្ញា ឬ ហៅថាបណ្តឹងព្រហ្មទណ្ឌ អាចធ្វើមកកាន់ស្ថាប័នអយ្យការបានតាមមធ្យោបាយ ពីរប្រភេទគឺៈ

- **តាមច្រកមន្ត្រីនគរបាលយុត្តិធម៌**

តាមមធ្យោបាយនេះ គឺប្រជាពលរដ្ឋដាក់ពាក្យបណ្តឹង ឬប្តឹងផ្ទាល់មាត់ដល់អង្គភាពមន្ត្រីនគរបាលយុត្តិធម៌ ឬមន្ត្រីនគរបាលយុត្តិធម៌ ដែលប្រទះឃើញបទល្មើសព្រហ្មទណ្ឌនៅកន្លែងណាមួយដោយខ្លួនឯង ។ មាត្រា៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ជាក់ផងដែរថា មន្ត្រីនគរបាលយុត្តិធម៌ទទួលបណ្តឹងទាមទារ ឬបរិហាហើយត្រូវពិនិត្យបទល្មើសទាំងឡាយ ។ គ្រប់បណ្តឹងដែលទទួលដោយមន្ត្រីនគរបាលយុត្តិធម៌នោះ តម្រូវឲ្យធ្វើកំណត់ហេតុ ដោយត្រូវស្រង់ដោយត្រឹមត្រូវនូវសេចក្តីរាយការណ៍របស់អ្នកប្តឹង[9] ។ គ្រប់ពេលដែលមានការដាក់ពាក្យបណ្តឹង មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះបញ្ជីបណ្តឹង ដែលមានក្នុងអង្គភាពរបស់ខ្លួន[10] ។ មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបណ្តឹងនោះត្រូវតែចាប់ផ្តើមភ្លាមៗ ដោយធ្វើការស៊ើបអង្កេត និងសុំសេចក្តីណែនាំពី ព្រះរាជអាជ្ញា ឬក៍បញ្ជូនកំណត់ហេតុស្តីពីការដាក់ពាក្យបណ្តឹងនោះ ទៅព្រះរាជអាជ្ញាដើម្បីចាត់ការតាមច្បាប់[11] ។

- **បណ្តឹងផ្ទាល់របស់ប្រជាពលរដ្ឋមកកាន់តុលាការ**

ក្នុងករណីនេះភាគច្រើនគេសង្កេតឃើញនៅក្នុងការអនុវត្តជាក់ស្តែង ដោយប្រជាពលរដ្ឋបានយកពាក្យបណ្តឹងមកដាក់ដោយផ្ទាល់នៅសាលាដំបូង រាជធានី-ខេត្ត ។ លេខាធិការដ្ឋាននៃ

[9] មាត្រា៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[10] មាត្រា៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[11] មាត្រា៧៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

សាលាដំបូង ជាអង្គភាពដែលមានភារកិច្ចទទួលបណ្តឹងនោះ ដោយធ្វើការពិនិត្យ និងបង្គាប់ឲ្យកែតម្រូវប្រសិនបើបណ្តឹងមានភាពខ្វះចន្លោះណាមួយ ។ នៅពេលដែលយកពាក្យបណ្តឹងមកដាក់នៅតុលាការ ប្រជាពលរដ្ឋត្រូវបង់ប្រាក់ពន្ធលើពាក្យបណ្តឹងទៅតាមច្បាប់កំណត់ផងដែរ ។ បន្ទាប់ពីមន្ត្រីលេខាធិការដ្ឋានពិនិត្យលើពាក្យបណ្តឹងឃើញថាត្រឹមត្រូវហើយ បណ្តឹងនេះត្រូវបញ្ជូនទៅកាន់ព្រះរាជអាជ្ញាដើម្បីចាត់ចែងបណ្តឹងនេះជាបន្ត ។

- **ស្វែងយល់អំពីការសរសេរពាក្យបណ្តឹង**

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ មិនបានចែងអំពីធាតុផ្សំ នៃការសរសេរពាក្យបណ្តឹងផ្នែកព្រហ្មទណ្ឌទេ ប៉ុន្តែយើងក៏អាចស្វែងយល់ខ្លះៗនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី(មាត្រា ៧៥ កថាខណ្ឌទី២) និងការអនុវត្តជាក់ស្តែងផងដែរ ។ ក្នុងករណីដែលប្រជាពលរដ្ឋមានបំណងសរសេរពាក្យបណ្តឹង ដាក់ទៅកាន់អង្គភាពនគរបាលយុត្តិធម៌ ឬ ទៅកាន់តុលាការផ្ទាល់ គឺគប្បីដឹងអំពីចំណុចមួយចំនួនដែលត្រូវតែមានក្នុងពាក្យបណ្តឹងរបស់ខ្លួនដូចជា ៖

១. អត្តសញ្ញាណរបស់អ្នកប្តឹង ឬ អ្នកតំណាងដោយអាណត្តិ ក្នុងករណីម្ចាស់បណ្តឹងគ្មានសមត្ថភាពធ្វើសកម្មភាពបណ្តឹងតាមច្បាប់ ។

២. អត្តសញ្ញាណរបស់ភាគីដែលចង់ប្តឹង ដែលសម្គាល់នូវបុគ្គលទាំងឡាយ រួមទាំងរូបវន្តបុគ្គល និងនីតិបុគ្គល ។ ក្នុងករណីដែលយើងប្តឹងនោះគ្មានសមត្ថភាពគ្រប់គ្រាន់ក្នុងនីតិវិធីនៃបណ្តឹងទេ យើងត្រូវសរសេរនូវឈ្មោះ និងអាស័យដ្ឋានរបស់អ្នកតំណាងស្របច្បាប់របស់បុគ្គលនោះផងដែរ ដើម្បីតុលាការងាយស្រួលក្នុងការកោះហៅ ។ ដោយឡែក ក្នុងករណីដែលម្ចាស់បណ្តឹងមិនបានស្គាល់អត្តសញ្ញាណរបស់ជនដែលខ្លួនចង់ប្តឹងនោះបាន ប៉ុន្តែម្ចាស់បណ្តឹងក៏ត្រូវសរសេរពាក្យបណ្តឹងនោះដើម្បីប្តឹងអញ្ញាតជន (ជនមិនស្គាល់អត្តសញ្ញាណ) បានផងដែរ ។

៣. គោលបំណងនៃការប្តឹងទាមទារ ៖ បើទោះបីជារឿងនោះជារឿងព្រហ្មទណ្ឌក៏ដោយ ប៉ុន្តែកាលណាជនគ្រោះជាអ្នកសរសេរពាក្យបណ្តឹងគឺបានសេចក្តីថា មានភ្ជាប់នូវការទាមទារដូចនេះត្រូវតែមានបញ្ជាក់ពីគោលបំណងនៃការទាមទារនៅក្នុងបណ្តឹង ។ ម្ចាស់បណ្តឹងអាចសរសេរបទចោទតាមការយល់ឃើញរបស់ខ្លួនបាន ប៉ុន្តែការសម្រេចចោទប្រកាន់ជាផ្លូវការ គឺការចោទប្រកាន់ដោយដីការបស់ព្រះរាជអាជ្ញា គឺជាការសម្រេចចោទប្រកាន់ដោយឆន្ទានុសិទ្ធិរបស់ម្ចាស់បណ្តឹងអាជ្ញា ។

៤. រឿងហេតុបញ្ជាក់អំពីការប្តឹងទាមទារ ៖ ក្នុងរឿងក្តីព្រហ្មទណ្ឌ រឿងហេតុដែលបានកើតឡើង គឺជាព្រឹត្តិការណ៍ដ៏សំខាន់មួយ ដែលម្ចាស់បណ្តឹង ត្រូវធ្វើការបរិយាយយ៉ាងលម្អិតក្នុងពាក្យបណ្តឹងរបស់ខ្លួន ដើម្បីមានមូលដ្ឋានច្បាស់គ្រប់គ្រាន់អាចឈានទៅដល់ការចោទប្រកាន់តាម

ផ្លូវច្បាប់ដោយព្រះរាជអាជ្ញា ។ អង្គហេតុដែលត្រូវបានធ្វើការរៀបរាប់នៅក្នុងពាក្យបណ្តឹងនេះ មិនប្រាកដថាជារឿងហេតុដែលបានកើតឡើងជាក់ស្តែងទេ ពេលខ្លះអាចត្រូវបានគេបង្កើតឡើង ដូច្នេះហើយ ក្នុងនាមជាមន្ត្រីនគរបាលយុត្តិធម៌ ត្រូវមានករណីយកិច្ចស្រាវជ្រាវ និងធ្វើការស៊ើបអង្កេតដើម្បីបញ្ជាក់ឲ្យឃើញនូវការពិតដែលបានកើតឡើងជាក់ស្តែងក្នុងករណីនីមួយៗ ។ ផ្ទុយទៅវិញប្រសិនបើម្ចាស់បណ្តឹង បានក្លែងអង្គហេតុណាមួយដែលមិនបានកើតឡើងទេ តែខ្លួនបានធ្វើការអះអាងថាជាការពិតនោះ កាលណាមន្ត្រីនគរបាយុត្តិធម៌ធ្វើការស៊ើបអង្កេតឃើញថា រឿងហេតុនោះពិតជាមិនបានកើតឡើង ពោលគឺបានកើតឡើងដោយសារម្ចាស់បណ្តឹងជាអ្នកប្រឌិតឡើងនោះ ករណីនេះម្ចាស់បណ្តឹងនឹងត្រូវទទួលការពិន័យតាមការកំណត់របស់ច្បាប់ ។

គួរបញ្ជាក់ផងដែរថា ពាក្យសំដី ឬចំណុច ដែលអ្នកសរសេរពាក្យបណ្តឹងបានបញ្ជាក់នោះ មន្ត្រីនគរបាលយុត្តិធម៌ ឬ ព្រះរាជអាជ្ញា មិនទាន់អាចសន្និដ្ឋានបានថា ជារឿងពិតដែលបានកើតឡើងនោះទេ ។ វាគ្រាន់តែជាព័ត៌មានដែលបានធ្វើការបង្ហាញពីភាគីតែម្ខាងប៉ុណ្ណោះ ប៉ុន្តែព័ត៌មានដែលបានធ្វើការបង្ហាញជូននោះ នឹងក្លាយទៅជាការពិតបានលុះត្រាតែព័ត៌មានទាំងនោះ ត្រូវបានឆ្លងកាត់ការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ឬ តាមរយៈការស៊ើបសួរដែលធ្វើឡើងដោយចៅក្រមស៊ើបសួរ ទើបវាអាចក្លាយជាព័ត៌មានពិតប្រាកដបាន ។

តាមគោលការណ៍នៃមធ្យោបាយធ្វើបណ្តឹងខាងលើនេះ បានសេចក្តីថា ព្រះរាជអាជ្ញាទទួលនូវពាក្យបណ្តឹង និងពាក្យបណ្តឹងបរិហាផ្សេងៗ ដែលទាក់ទងទៅនឹងរឿងបទល្មើសព្រហ្មទណ្ឌមួយដែលបានកើតឡើង ដែលត្រូវទទួលដោយផ្ទាល់ពីសំណាក់ជនរងគ្រោះ ព្រមទាំងបុគ្គលដទៃផ្សេងទៀតក្រៅពីជនរងគ្រោះ។

ជាគោលការណ៍ក្រោយពីទទួលនូវព័ត៌មាន ទាក់ទងទៅនឹងបទល្មើសព្រហ្មទណ្ឌណាមួយនោះ នៅពេលធ្វើចំណាត់ការលើសំណុំរឿងដែលទទួលបាននោះ ព្រះរាជអាជ្ញាបើកការស៊ើបអង្កេតបឋម ឬបង្គាប់ឲ្យមន្ត្រីនគរបាលយុត្តធម៌ធ្វើការស្រាវជ្រាវបន្ថែម គឺសំដៅដល់ការប្រមូលព័ត៌មានបំភ្លឺបន្ថែមទៀត ដើម្បីអាចធ្វើជាមូលដ្ឋានដ៏សំខាន់មួយ សម្រាប់ធ្វើការវាយតម្លៃព្រមទាំងធ្វើការថ្លឹងថ្លែងដោយកំណត់ចំណាំនៅលើសំណុំរឿងនោះឲ្យបានត្រឹមត្រូវ និងច្បាស់លាស់មុននឹងព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ។

ផ្អែកតាមស្មារតីមាត្រា ៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានបង្ហាញអំពីការធ្វើចំណាត់ការរបស់ព្រះរាជាអាជ្ញាលើពាក្យបណ្តឹងទាំងឡាយ ដែលខ្លួនបានទទួលដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក ។ បន្ទាប់ពីថ្លឹងថ្លែងរួចហើយ ព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់

ការ ឬធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ដោយឆ្លងកាត់ការស៊ើបអង្កេតបឋម ឬ បង្គាប់ឲ្យធ្វើការស្រាវជ្រាវបន្ថែម ។ ដោយឡែកក្នុងករណីបទល្មើសធ្ងន់ធ្ងរ ព្រះរាជអាជ្ញារាយការណ៍ជូនអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដែលត្រូវរាយការណ៍បន្តជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ តាមគោលការណ៍នេះមានន័យថា ការធ្វើចំណាត់ការលើបណ្ដឹងរបស់ព្រះរាជអាជ្ញា អាចលេចចេញជាទម្រង់នៃការសម្រេចចោទប្រកាន់ ឬ តម្កល់រឿងទុកឥតចាត់ការ ។

## ១.២. ការតម្កល់រឿងទុកឥតចាត់ការ

មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការមានច្រើន ប៉ុន្តែមិនបានធ្វើការកំណត់យ៉ាងជាក់លាក់ និងច្បាស់លាស់ដោយច្បាប់ទេ តែយើងអាចផ្អែកទៅលើស្មារតី នៃក្រមនីតិវិធីព្រហ្មទណ្ឌបាន ។ ខាងក្រោមនេះគឺជាមូលហេតុមួយចំនួន នៃការតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញាដែលមានដូចជា៖

- ការមិនអាចកំណត់បាននូវអត្តសញ្ញាណរបស់ចារី ឬពុំមានបន្ទុកគ្រប់គ្រាន់ដើម្បីបង្ហាញពីពិរុទ្ធភាពរបស់ចារី ហើយការស្រាវជ្រាវបន្ថែមដោយមន្ត្រីនគរបាលយុត្តិធម៌ហាក់ដូចជាមិនទទួលបានផល ឬគ្មានប្រយោជន៍ដើម្បីទទួលបាននូវធាតុផ្សំផ្សេងៗទៀត ដែលជាមូលហេតុចម្បងការចោទប្រកាន់ ។
- អំពើដែលបង្ហាញមកនោះ មិនបង្កើតជាបទល្មើសព្រហ្មទណ្ឌ ។
- បទល្មើសមិនមានលក្ខណៈគ្រប់គ្រាន់ ដូចជាថាធាតុផ្សំនៃសំណុំរឿង មិនអនុញ្ញាតឲ្យកំណត់ធាតុផ្សំនៃបទល្មើស ឬមូលហេតុមកពីការមិនទទួលខុសត្រូវព្រហ្មទណ្ឌ (អនីតិជនក្រោមអាយុ១៨ឆ្នាំ ការបញ្ជារបស់ច្បាប់ ឬអាជ្ញាធរ ធម្មានុរូប ការការពារស្របច្បាប់ និងស្ថានភាពស្របច្បាប់) ។
- ការរលត់នូវបណ្ដឹងអាជ្ញាជាដើម ។

ជាចុងក្រោយ និងជាចំណុចបង្ហាញពីគោលការណ៍កាលានុវត្តភាព នៃការចោទប្រកាន់ គឺការតម្កល់រឿងទុកឥតចាត់ការ ទោះបីជាបទល្មើសនោះ អ្នកដែលបានប្រព្រឹត្តបទល្មើស ត្រូវបានស្គាល់មុខក៏ដោយ ប៉ុន្តែព្រះរាជអាជ្ញាយល់ឃើញថាការតម្កល់រឿងទុកឥតចាត់ការនេះមានលក្ខណៈត្រឹមត្រូវតាមកាលៈទេសៈ ដើម្បីជាផលប្រយោជន៍ទូទៅ ព្រោះព្យសនកម្មដែលបានកើតឡើងដោយសារបទល្មើសនោះមានតម្លៃតិចតួចពេក ឬហេតុផលមួយទៀតដូចជា ភាពរឹករវដល់សណ្ដាប់ធ្នាប់សាធារណៈគឺមានលក្ខណៈមិនធ្ងន់ធ្ងរ ឬជនល្មើសបានប្រព្រឹត្តបទល្មើសជាលើកដំបូង ដែលទំហំនៃព្យសនកម្មមានទ្រង់ទ្រាយតិចតួច ឬជនល្មើសបានជុសជុលនូវការខូចខាតឲ្យជនរងគ្រោះបានរួចរាល់ហើយជាដើម ។

យោងតាមមាត្រា៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថា "កាលណាបណ្តឹងមួយត្រូវបានតម្កល់ទុកឥតចាត់ការ ព្រះរាជអាជ្ញាត្រូវជូនដំណឹងដល់អ្នកប្តឹងអំពីសេចក្តីសម្រេចរបស់ខ្លួន នៅក្នុងរយៈពេលយ៉ាងខ្លីបំផុត ហើយយ៉ាងយូរបំផុតរយៈពេលពីរខែ គិតពីថ្ងៃចុះពាក្យបណ្តឹង នៅក្នុងបញ្ជីបណ្តឹងនេះ គឺមាននៅតុលាការជាន់ដំបូងនីមួយៗ ដែលត្រូវបានបង្កើតឲ្យមានបញ្ជីអយ្យការមួយសម្រាប់ចុះបណ្តឹងដែលបានប្តឹងដោយផ្ទាល់ដល់ព្រះរាជអាជ្ញា ឬដែលបញ្ជូនមកតាមរយៈមន្ត្រីនគរបាលយុត្តិធម៌" ។

គ្រប់បណ្តឹងទាំងអស់ត្រូវតែចុះក្នុងបញ្ជីដោយមានខ្លឹមសារដូចជា:

- អត្តសញ្ញាណរបស់អ្នកប្តឹង
- កាលបរិច្ឆេទដែលអយ្យការបានទទួលពាក្យបណ្តឹង
- ប្រភពនៃបណ្តឹង: បណ្តឹងផ្ញើរមកដោយផ្ទាល់ចំពោះព្រះរាជអាជ្ញា ឬក៏បញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌។
- ប្រភេទនៃរឿងហេតុដែលអ្នកប្តឹងបានរាយការណ៍
- ចំណាត់ការលើពាក្យបណ្តឹង: ការសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌណាមួយ។

បញ្ជីនៃបណ្តឹងត្រូវកាន់កាប់ដោយលេខាធិការរបស់អយ្យការ ក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា ។ បញ្ជីអាចត្រូវបានបើកមើលដោយអាជ្ញាធរតុលាការទាំងអស់ ជាអាទិ៍អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍[12] ។

យោងតាមគោលការណ៍កាលានុវត្តភាពនៃបណ្តឹងអាជ្ញា បានអនុញ្ញាតឲ្យព្រះរាជអាជ្ញាអាចតម្កល់រឿងទុកឥតចាត់ការបាន ទោះបីជាអំពើដែលបានប្តឹង ឬបរិហារមកនោះជាបទល្មើសព្រហ្មទណ្ឌក៏ដោយប្រសិនបើព្រះរាជអាជ្ញា យល់ឃើញថាអំពើនោះមិនមានភាពរីករាលដល់សង្គម ឬប៉ះពាល់ដល់សណ្តាប់ធ្នាប់ធ្ងន់ធ្ងរ ឬការប្រព្រឹត្តក្នុងកាលៈទេសៈពិសេសណាមួយ ដែលគួរឲ្យអនុគ្រោះបាន ។

ជម្រើសមិនចោទប្រកាន់នេះ បានស្តែងចេញតាមរយៈសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ ដែលផ្អែកទៅលើការវាយតម្លៃរបស់ព្រះរាជអាជ្ញាតែមួយគត់ ។ ម្យ៉ាងទៀត ទោះបីជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចមានសិទ្ធិធ្វើអធិបញ្ញា ដើម្បីឲ្យព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ពីបទ

[12] មាត្រា៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ល្មើសព្រហ្មទណ្ឌណាមួយដែលខ្លួនបានដឹងក៏ដោយ ប៉ុន្តែរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ គឺមិនអាចធ្វើអធិបញ្ជាឲ្យព្រះរាជអាជ្ញាតម្កល់រឿងទុកឥតចាត់ការបានឡើយ[13] ។

### ១.៣. ការសម្រេចចោទប្រកាន់

ក្នុងករណីដែលព្រះរាជាអាជ្ញា បានពិចារណាទៅលើសំណុំរឿងដែលបានបញ្ជូនមកខ្លួន ហើយឃើញថាមានលក្ខណៈគ្រប់គ្រាន់ និងអាចបន្តចំណាត់ការលើបណ្ដឹងនោះបាន ព្រះរាជាអាជ្ញានឹងធ្វើការសម្រេចចោទប្រកាន់ ។ ផ្អែកតាមការអនុវត្តន៍គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ព្រះរាជអាជ្ញាមានជម្រើសមធ្យោបាយនៃការចោទប្រកាន់ អាស្រ័យទៅលើស្ថានភាពនៃសំណុំរឿង នីតិវិធីដែលរួចរាល់ អាចបញ្ជូនទៅតុលាការជំនុំជម្រះ ឬ ផ្ទុយទៅវិញ តម្រូវឲ្យមានការស៊ើបសួរទូលំទូលាយ ពេលគឺអាចប្ដឹងទៅយុត្តាធិការស៊ើបសួរ ឬ យុត្តាធិការជំនុំជម្រះ ។ កាលណាព្រះរាជអាជ្ញា សម្រេចធ្វើការចោទប្រកាន់ នោះនាំឲ្យកើតឡើងនូវនីតិវិធីបន្តនៃការធ្វើបណ្ដឹងនោះ ។

## ២. ទម្រង់នៃការបន្តបណ្ដឹងអាជ្ញា

តាមការបញ្ជាក់ខាងលើបានបង្ហាញថា ព្រះរាជអាជ្ញាសម្រេចធ្វើការចោទប្រកាន់ និងអនុវត្តនីតិវិធីនីមួយៗ អាស្រ័យទៅតាមលក្ខខណ្ឌ និងស្ថានភាពជាក់ស្ដែងផ្សេងនៃសំណុំរឿង។ ដូច្នេះបន្ទាប់ពីគិតពិចារណារួចរាល់ ព្រះរាជអាជ្ញានឹងសម្រេចជ្រើសរើសផ្លូវមួយណា ដើម្បីធ្វើការចោទប្រកាន់។ ការសម្រេចធ្វើការចោទប្រកាន់នេះ បានសេចក្ដីថាព្រះរាជអាជ្ញាបានចាប់ផ្ដើមដើរតួជាម្ចាស់បណ្ដឹងអាជ្ញានៅក្នុងសំណុំរឿងមួយនោះ ។

ផ្អែកតាមមាត្រា ៨៣នៃក្រមនីតិវិធីព្រហ្មទណ្ឌបានបង្ហាញថា ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌអាចធ្វើបានតាមមធ្យោបាយដូចខាងក្រោម៖

- ការបើកការស៊ើបសួរៈ គឺជាការប្ដឹងទៅយុត្តាធិការស៊ើបសួរ ដើម្បីស្វែងរកព័ត៌មានបន្ថែមទាក់ទងនិងសំណុំរឿង
- ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ
- តាមនីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ។

គួរកត់សម្គាល់ថា នីតិវិធីពីរខាងក្រោមនេះ គឺប្ដឹងទៅយុត្តាធិការជំនុំជម្រះ ដោយមិនចាំបាច់ឆ្លងកាត់នូវការស៊ើបសួរនោះទេ ។

### ២.១. ករណីបើកការស៊ើបសួរ

ជាទូទៅ នៅពេលដែលទទួលបានសំណុំរឿងពីមន្ត្រីនគរបាលយុត្តិធម៌ ឬ ពីមន្ត្រីលេខាធិការដ្ឋាន ព្រះរាជអាជ្ញាធ្វើការពិចារណាវាយតម្លៃអំពីស្ថានភាពសំណុំរឿង ដើម្បីសម្រេចថា តើត្រូវការ

[13] មាត្រា២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ស្រាវជ្រាវស្វែងរកភស្តុតាងបន្ថែមដែរ ឬទេ ? ការវាយតម្លៃស្ថានភាពសំណុំរឿង នីតិវិធីអាចធ្វើឲ្យព្រះរាជអាជ្ញាយល់ពីភាពចាំបាច់ក្នុងការស្រាវជ្រាវបន្ថែម ដើម្បីទទួលបានភស្តុតាងដែលអនុញ្ញាតឲ្យអនុវត្តបណ្តឹងអាជ្ញាដោយសមហេតុផល ។ ក្នុងទស្សនវិស័យនេះ ព្រះរាជអាជ្ញាមានផ្លូវពីរ គឺបន្តការស៊ើបអង្កេត និងធ្វើបណ្តឹងទៅចៅក្រមស៊ើបសួរ។ ការប្តឹងទៅយុត្តាធិការស៊ើបសួរ ត្រូវធ្វើឡើងតាមរយៈដីកាសេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។

ជាគោលការណ៍ក្នុងករណីបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ ។ ការស៊ើបសួរត្រូវបានបើកតាមរយៈដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ដែលត្រូវប្តឹងទៅចៅក្រមស៊ើបសួរ ។ ចំពោះការស៊ើបសួរត្រូវបើកប្រឆាំងលើបុគ្គលម្នាក់ ឬច្រើននាក់ដោយមានចង្អុលប្រាប់ឈ្មោះ ឬប្រឆាំងទៅលើអញ្ញាតជន [14]។

ការបើកការស៊ើបសួរមានលក្ខណៈដាច់ខាត ក្នុងករណីដែលបទល្មើសនឹងអាចធ្វើការចោទប្រកាន់នោះ មានបទល្មើសមួយជាចម្បង ជាបទឧក្រិដ្ឋ ប៉ុន្តែការបើកការស៊ើបសួរមមានលក្ខណៈមិនដាច់ខាតនោះទេ ចំពោះបទល្មើសដែលនឹងអាចចោទប្រកាន់ ជាបទល្មើសមជ្ឈិម ឬបទលហុ[15] ។ ក្នុងចុងក្រោយនេះ ស្ថាប័នអយ្យការធ្វើការបើកស៊ើបសួរ អាស្រ័យទៅលើស្ថានភាពសំណុំរឿងនីតិវិធីជាអាទិ៍ នៅពេលដែលបុគ្គល ដែលជាប់ពាក់ព័ន្ធមិនបានកំណត់ពីអត្តសញ្ញាណ និងមិនអាចកំណត់បានក្នុងពេលបច្ចុប្បន្ន ។

ម្យ៉ាងទៀតព្រះរាជអាជ្ញា ក៏អាចសម្រេចបើកការស៊ើបសួរផងដែរ កាលបើយល់ឃើញថាភស្តុតាងដែលប្រមូលបានមិនគ្រប់គ្រាន់ ដើម្បីប្តឹងទៅយុត្តាធិការជំនុំជម្រះបាន ហើយភស្តុតាងដែលខ្វះខាតនោះមិនអាចប្រមូលបានដោយការស៊ើបអង្កេតបឋម ប៉ុន្តែអាចប្រមូលមកបានលុត្រាតែប្រើអំណាចដោយបង្ខំ ឬបទល្មើសមជ្ឈឹមដែលត្រូវពិគ្រោះនោះ មានលក្ខណៈស្មុគស្មាញ សាំញ៉ាំដែលតម្រូវឲ្យមានការស្រាវជ្រាវយូរ និងប្រកបដោយភាពពិបាក ។

**គួរបញ្ជាក់ថា៖** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ អាចធ្វើឡើងប្រឆាំងនឹងបុគ្គលដែលស្គាល់ឈ្មោះ និងបុគ្គលមិនស្គាល់ឈ្មោះ (អញ្ញាតជន) ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ គឺជាលិខិតបើកឲ្យមានបណ្តឹងអាជ្ញា ដែលព្រះរាជអាជ្ញាប្តឹងទៅចៅក្រមស៊ើបសួរ ដោយសុំឲ្យស៊ើបសួរលើរឿងរ៉ាវមួយជាកំណត់ ដែលអាចត្រូវផ្តន្ទាទោសព្រហ្មទណ្ឌ ។ ហេតុនេះហើយទើបដីកាសន្និដ្ឋាននេះ ទាមទារឲ្យគោរពយ៉ាងដាច់ខាតនូវលក្ខខណ្ឌមួយចំនួន ជាអាទិ៍៖ ត្រូវមានបញ្ជាក់នូវសេចក្តី

[14] មាត្រា៤៤ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[15] មាត្រា១២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

សង្ខេបអង្គហេតុ, ឈ្មោះបទល្មើស, ចង្អុលបង្ហាញនូវបទបញ្ញត្តិ ដែលត្រូវពិគ្រោះ និងផ្តន្ទាទោស និងជាយថាហេតុ ឈ្មោះរបស់បុគ្គលដែលរងការស៊ើបសួរ ព្រមជាមួយគ្នានោះ ដីកានេះត្រូវចុះកាលបរិច្ឆេទ និងហត្ថលេខា ។ ការចុះកាលបរិច្ឆេទ មានគុណប្រយោជន៍ដើម្បីធ្វើការផ្ទៀងផ្ទាត់ថាបណ្តឹងអាជ្ញាមិនទាន់ផុតរលត់អាជ្ញាយុកាល ហើយចៅក្រមស៊ើបសួរមិនបានធ្វើការស៊ើបសួរ មុនពេលទទួលបណ្តឹង ។ រីឯការចុះហត្ថលេខារបស់ចៅក្រម ដែលបានចេញសេចក្តីសម្រេចឲ្យបើកការស៊ើបសួរនេះដើម្បីបញ្ជាក់ពីឆន្ទៈរបស់អង្គអយ្យការក្នុងការចោទប្រកាន់ ។ បើពុំគោរពតាមលក្ខខណ្ឌទាំងប្រាំខាងលើនេះទេ ជាហេតុនាំឲ្យមោឃកម្មនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះ[16] ។ ចំពោះក្រមនីតិវិធីនៃការស៊ើបសួរ ត្រូវអនុលោមតាមបញ្ញត្តិដែលមានចែង ក្នុងគន្ថីទី៤នៃក្រមនីតិវិធីព្រហ្មទណ្ឌផងដែរ ។

## ២.២. ករណីបញ្ជូនទៅជំនុំជម្រះផ្ទាល់

ក្នុងករណីដែលព្រះរាជអាជ្ញាបានពិនិត្យឃើញថា សំណុំរឿងដែលបានបញ្ជូនមកមានលក្ខណៈគ្រប់គ្រាន់ហើយ ព្រះរាជអាជ្ញាមិនចាំបាច់ទាមទារបើកការស៊ើបសួររកភស្តុតាងបន្ថែមទេ នោះព្រះរាជអាជ្ញាសម្រេចចំណាត់ការទៅលើសំណុំរឿងនេះ ដោយបញ្ជូនទៅជំនុំជម្រះផ្ទាល់តែម្តង ដោយមិនឆ្លងកាត់នីតិវិធីស៊ើបសួរនោះទេ ។ ស្ថានភាពនៃសំណុំរឿងនីតិវិធីនេះ ត្រូវបានសន្មត់ជាដំបូងថា គេបានសង្ស័យទៅលើបុគ្គលម្នាក់ ឬច្រើននាក់ដែលបានកំណត់អត្តសញ្ញាណ ហើយត្រូវបានចោទពីបទល្មើសមួយ ឬច្រើន ដែលបទល្មើសទាំងនោះជាបទល្មើសមជ្ឈិម ឬបទលហុ ។ ការប្តឹងទៅយុត្តាធិការជំនុំជម្រះ ព្រះរាជអាជ្ញាអាចសម្រេចឲ្យបុគ្គលដែលពាក់ព័ន្ធមកបង្ហាញខ្លួននៅចំពោះមុខ ដើម្បីធ្វើការចោទប្រកាន់ភ្លាមៗ តាមរយៈមធ្យោបាយពីរ គឺការចូលបង្ហាញខ្លួនភ្លាម ឬដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ប៉ុន្តែវិធាននៃនីតិវិធីបែបនេះ មិនត្រូវបានអនុវត្តចំពោះបទឧក្រិដ្ឋនោះទេ ។

វិធីចំណាត់ការបែបនេះ អនុញ្ញាតឲ្យព្រះរាជអាជ្ញាប្តឹងដោយផ្ទាល់ទៅយុត្តាធិការជំនុំជម្រះ និងបង្គាប់ឲ្យជនជាប់ចោទបង្ហាញខ្លួននៅមុខសាលាដំបូង ។ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់នេះអាចអនុវត្តចំពោះគ្រប់បទល្មើសមជ្ឈិម និងបទលហុ តាមរយៈដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ដោយដីកានេះត្រូវចុះនូវអត្តសញ្ញាណជនជាប់ចោទ សេចក្តីសង្ខេបអង្គហេតុ និងអត្ថបទច្បាប់ដែលបានកំណត់និបង្ក្រាបបទល្មើសព្រមទាំងចង្អុលបង្ហាញ ប្រាប់ពីមន្ទីរតុលាការដែលទទួលបណ្តឹង ទីកន្លែង កាល

[16] មាត្រា៤៤ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

បរិច្ឆេទ និងពេលវេលានៃសវនាការ ។ ជាចុងក្រោយនៃដីកានេះត្រូវបញ្ជាក់ឲ្យបានច្បាស់ថា ជនជាប់ចោទអាចសុំជំនួយពីមេធាវីអមខ្លួនបាន[17] ។

ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជាបញ្ជាដល់ជនជាប់ចោទឲ្យចូលបង្ហាញខ្លួននៅតុលាការជាន់ដំបូងដែលសម្រេចពីរឿងក្ដីព្រហ្មទណ្ឌ[18] ។

យោងតាមមាត្រា២៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានបញ្ញត្តិអំពីការកំណត់កាលបរិច្ឆេទនៃសវនាការ ដែលត្រូវកំណត់ដោយប្រធានតុលាការ (លើកលែងតែនីតិវិធីបង្ហាញខ្លួនភ្លាម) ។ នៅក្នុងករណីដែលតុលាការ បានទទួលបណ្ដឹងដែលបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬដោយដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬដោយសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ ។ ប្រធានតុលាការត្រូវតែគិតគូរតាមរយៈពេលដែលមានចែងក្នុងមាត្រា៤៥៧ និង មាត្រា៤៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីកំណត់កាលបរិច្ឆេទបើកសវនាការ ។

រយៈពេលដែលត្រូវគោរព រវាងការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ដល់ជនជាប់ចោទ និងថ្ងៃកំណត់ឲ្យបង្ហាញខ្លួននៅមុខតុលាការត្រូវកំណត់ដូចតទៅ៖

- ១៥ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃទីស្នាក់ការតុលាការដំបូង
- ២០ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងមួយផ្សេងទៀតក្នុងដែនដីជាតិ
- ២ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែនព្រះរាជាណាចក្រកម្ពុជា
- ៣ខែ ប្រសិនបើជនជាប់ចោទរស់នៅទីកន្លែងដទៃផ្សេងទៀត[19] ។

ចិរវេលាខាងលើត្រូវតែគោរពបើពុំដូច្នោះ នឹងនាំឲ្យមានមោឃភាពនៃនីតិវិធីនៃការកោះហៅលើកលែងតែ ជនជាប់ចោទយល់ព្រមចូលមកបង្ហាញខ្លួនដោយស្ម័គ្រចិត្ត ។

ការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ដល់ជនជាប់ចោទ អាចធ្វើឡើងដោយព្រះរាជអាជ្ញា ឬអាជ្ញាសាលា ឬមេឃុំ-ចៅសង្កាត់ ឬអនុប្រធាន បើសិនជាជនជាប់ចោទបដិសេធមិនទទួលដីកា ។ ជាចុងក្រោយការប្រគល់ដីកាអាចធ្វើឡើងដោយក្រឡាបញ្ជីតាមផ្លូវរដ្ឋបាល ដោយប្រធានពន្ធនាគារ ឬអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ហើយវិធីនៃការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ដល់ជនជាប់ចោទមានបញ្ញត្តិក្នុងមាត្រា ៤៥៨ និងបន្តបន្ទាប់ ពោលគឺ គន្ថីទី៧ មាតិកាទី១ នៃក្រមនីតិវិធីព្រហ្មណ្ឌ ។

---

[17] មាត្រា៤៦ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[18] មាត្រា៤៦ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[19] មាត្រា៤៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ចំពោះភាគីដែលត្រូវកោះហៅក្នុងករណីបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដែលក្នុងនោះការកោះហៅត្រូវធ្វើឡើងដោយព្រះរាជអាជ្ញា ឲ្យចូលរួមសវនាការនូវ៖ ជនរងគ្រោះ, សាក្សី, អ្នកបកប្រែ (បើចាំបាច់), អ្នកទទួលខុសត្រូវរដ្ឋប្បវេណី តាមព័ត៌មានដែលផ្តល់ដោយជនជាប់ចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី[20] ។

ដោយឡែកនីតិវិធីនៃការកោះហៅភាគី នៅក្នុងករណីកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ក៏ត្រូវបានអនុវត្តដូចបានចែងក្នុង គន្លឹទី៧ មាតិកាទី១នៃក្រមនីតិវិធីព្រហ្មទណ្ឌផងដែរ។

## ២.៣. នីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម

នីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម គឺជាចំណាត់ការមួយក្នុងចំណោមចំណាត់ការផ្សេងទៀតដែលព្រះរាជអាជ្ញាសម្រេចធ្វើផ្អែកទៅតាមស្ថានភាពនៃសំណុំរឿង ដើម្បីធ្វើឲ្យបណ្តឹងនោះដំណើរការឈានទៅរកការជំនុំជម្រះ ។ វិធីចំណាត់ការបែបនេះ អនុញ្ញាតឲ្យព្រះរាជអាជ្ញាបង្គាប់ជនជាប់ចោទចូលបង្ហាញខ្លួនភ្លាមៗនៅមុខសាលាដំបូង បន្ទាប់ពីការបញ្ចប់ការឃាត់ខ្លួន ប៉ុន្តែវិធីនេះមិនត្រូវបានយកទៅអនុវត្តលើបទល្មើសលហុ និងបទល្មើសមជ្ឈឹមដែលប្រព្រឹត្តិដោយអនីតិជននោះទេ ។ លើសពីនេះវិធាននេះអាចអនុវត្តបានលុះត្រា តែគោរពលក្ខខណ្ឌមួយចំនួនពោលគឺ ប្រភេទចំណាត់ការសំណុំរឿងបែបនេះអាចប្រព្រឹត្តិទៅបានតែក្នុងករណីបទឧក្រិដ្ឋជាក់ស្តែង ឬបទមជ្ឈឹមជាក់ស្តែង ដែលមានទណ្ឌកម្មនៃទោសដាក់ពន្ធនាគារ ដែលត្រូវសម្រេចដោយតុលាការយ៉ាងតិច ១ឆ្នាំ និងយ៉ាងច្រើន៥ឆ្នាំ (យ៉ាងតិច ១ឆ្នាំ និងយ៉ាងច្រើន៥ឆ្នាំ គឺសំដៅលើអតិបរិមានៃទោសដែលមានបញ្ញត្តិក្នុងច្បាប់: **ជាឧទាហរណ៍** មាត្រា៤១ ចំនុចទី២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល បានចែងថា ការបង្ករបួសដោយគ្មានពិការភាពត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ចាប់ពី ២ខែ ទៅ១ឆ្នាំ) ហើយសំណុំរឿងនីតិវិធីត្រូវតែស្ថិតក្នុងស្ថានភាព ដែលអាចបញ្ជូនទៅសាលាវិនិច្ឆ័យបាន មានន័យថាបន្ទុកដែលប្រមូលបានសមល្មមអាចនឹងជំនុំជម្រះបាន[21] ។

នៅពេលបញ្ចប់ការឃាត់ខ្លួន បុគ្គលដែលត្រូវបានឃាត់ខ្លួនត្រូវបញ្ជូនដោយកងកម្លាំងការពារដើម្បីឲ្យ ចូលបង្ហាញខ្លួននៅចំពោះមុខព្រះរាជអាជ្ញា[22] ។ បន្ទាប់ពីទទួលបានកំណត់ហេតុ និងខ្លួនបុគ្គលឃាត់ខ្លួនពីមន្ត្រីនគរបាលយុត្តិធម៌ កាលបើសម្រេចប្រើនីតិវិធីបង្គាប់ឲ្យបង្ហាញខ្លួនភ្លាម ព្រះរាជអាជ្ញាត្រូវ៖

- ពិនិត្យ ឬសាកសួរអំពីអត្តសញ្ញាណបុគ្គលដែលគេបញ្ជូនមកឲ្យខ្លួន

[20] មាត្រា២៩៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[21] មាត្រា៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[22] មាត្រា១០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

- ឲ្យដំណឹងដល់ជននោះអំពីរឿងរ៉ាវដែលចោទប្រកាន់ និងឈ្មោះបទល្មើសព្រមទាំងអត្ថបទច្បាប់ដែលបានកំណត់ និងបង្ក្រាបបទល្មើស ។
- ទទួលស្តាប់យកចំលើយរបស់សាមីជន ប្រសិនបើជននោះចង់និយាយ ដោយប្រាប់ជននោះថា ក្រោមវិធានបង្ការបែបនេះជននេះនឹងត្រូវជំនុំជម្រះនៅក្នុងថ្ងៃនោះតែម្តងដោយសាលាដំបូង ហើយមានសិទ្ធិទទួលជំនួយពីមេធាវីតាមការជ្រើសរើសរបស់ខ្លួន ឬតាមការចាត់តាំងឡើងដោយអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី បន្ទាប់ពីបានទទួលការជ្រើសរើស ឬចាត់តាំងរួចហើយមេធាវីត្រូវបានទទួលដំណឹងភ្លាម ហើយមានសិទ្ធិអាច ពិនិត្យសំណុំរឿង និងទំនាក់ទំនងជាមួយជនជាប់ចោទបាន។
- ធ្វើកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលខ្លួនភ្លាម ។ ការឲ្យដំណឹងអំពីការបង្ការ ដែលធ្វើឡើងដោយកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម គឺជាដីកាកោះប្រគល់ឲ្យជនត្រូវចោទ ហើយដែលក្នុងខណៈនោះ ជនត្រូវចោទត្រូវបានទទួលឈ្មោះថាជាជនជាប់ចោទ ។

ទម្រង់ការទាំងនេះត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ បើពុំនោះទេនីតិវិធីត្រូវទុកជាមោឃៈ។

ជនជាប់ចោទត្រូវបង្ខាំងទុកដោយកកម្លាំងការពារ រហូតដល់ពេលសាមីខ្លួនចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ ដែលត្រូវបើកសវនាការនៅក្នុងថ្ងៃនោះតែម្តង។

សាលាដំបូងដែលទទួលបណ្តឹងតាមកំណត់ហេតុ ត្រូវធ្វើការផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជនជាប់ចោទដំបូងគេបង្អស់ និងធ្វើរបាយការណ៍សង្ខេបរឿងរ៉ាវដែលបានចោទប្រកាន់ ជាពិសេសត្រូវប្រាប់ដល់ជននោះអំពីរយៈពេលដែលមានដើម្បីរៀបចំខ្លួន ។ ការទាមទារបែបនេះបានបង្ហាញឲ្យឃើញច្បាស់ ដោយសារជនជាប់ចោទពុំមានរយៈពេល ដើម្បីរៀបចំខ្លួនចាប់តាំងពីពេលទទួលដំណឹងអំពីការបង្ការ ។ ប្រសិនបើជនជាប់ចោទត្រូវការរយៈពេលដើម្បីរៀបចំការពារខ្លួន ឬតុលាការយល់ឃើញថា រឿងក្តីនោះមិនអាចជំនុំជម្រះបានទេ នោះសំណុំរឿងនោះត្រូវលើទៅសវនាការពេលក្រោយ ។ សវនាការនេះត្រូវបើកក្នុងចិរវេលា មិនអាចលើសពី ២(ពីរ) សប្តាហ៍បានឡើយ ។ ក្នុងរយៈពេលដែលរងចាំការបង្ហាញខ្លួន តុលាការត្រូវសម្រេចគួរឃុំខ្លួនជនជាប់ចោទដោយសាលក្រម ដែលមានបញ្ជាក់ពីសំអាងហេតុ និងយោងអំពីមូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន ដោយអនុលោមតាមមាត្រា ២០៥នៃក្រមនីតិវិធីព្រហ្មទណ្ឌ ជាបណ្តោះអាសន្នរហូតដល់ពេលសវនាការ ។ បន្ទាប់មកតុលាការត្រូវចេញដីកាសម្រេចបង្គាប់ឲ្យឃុំខ្លួនយោងតាមអំណាចសាលក្រម ។

កាលបើរយៈពេលពីរសប្តាហ៍ ដោយគិតពីថ្ងៃចូលបង្ហាញខ្លួននៅមុខតុលាការកន្លងផុតទៅ សាលក្រមលើអង្គសេចក្តីមិនទាន់បានប្រកាស នោះការឃុំខ្លួនបណ្តោះអាសន្នត្រូវតែបញ្ឈប់ដោយពេញច្បាប់ ។

គួរបញ្ជាក់ផងដែរថា ការអនុវត្តវិធាននៃនីតិវិធីបង្ហាញខ្លួនភ្លាមរបស់ព្រះរាជអាជ្ញា មិនមានអានុភាពកម្រិតឲ្យសាលាដំបូងត្រូវតែប្រតិបត្តិនោះទេ ។ ផ្ទុយទៅវិញ តុលាការមានសេរីភាពវាយតម្លៃលើស្ថានភាពនៃសំណុំរឿងនីតិវិធី និងអាចសន្និដ្ឋានជាយថាហេតុ កាលបើលក្ខខណ្ឌនៃមាត្រា ៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌមិនបានបំពេញទេ ឬក៏រឿងក្តីនេះ មានភាពស្មុំញ៉ាំតម្រូវជាចាំបាច់ឲ្យធ្វើការស្រាវជ្រាវ ឲ្យបានជ្រាលជ្រៅបន្ថែម ។ តុលាការត្រូវបញ្ជូនរឿងនោះទៅព្រះរាជអាជ្ញា ដើម្បីបើកការស៊ើបសួរ ។ ជនត្រូវចោទត្រូវតែនាំទៅបង្ហាញខ្លួននៅថ្ងៃនោះតែម្តងនៅចំពោះមុខចៅក្រមស៊ើបសួរ បើពុំដូច្នោះទេ ជនត្រូវចោទត្រូវតែដោះលែងឲ្យមានសេរីភាពដោយឯកឯង[23] ។

ក្នុងនោះផងដែរចំពោះ ភាគីដែលត្រូវកោះហៅនៅក្នុងករណីចូលបង្ហាញខ្លួនភ្លាម ដែលក្នុងនោះការកោះហៅត្រូវធ្វើឡើងដោយព្រះរាជអាជ្ញា ឲ្យចូលរួមសវនាការនូវ ជនរងគ្រោះ, សាក្សី, អ្នកបកប្រែ (បើចាំបាច់) និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីតាមព័ត៌មានដែលផ្តល់ដោយជនជាប់ចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី[24] ។

វិធីនៃការកោះហៅភាគីនៅក្នុងករណីចូលបង្ហាញខ្លួនភ្លាម ត្រូវអនុវត្តដូចដែលបានចែងក្នុងគន្ថីទី៧ មាតិកាទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ប៉ុន្តែក្នុងករណីបន្ទាន់ ព្រះរាជអាជ្ញាអាចកោះហៅជនរងគ្រោះ, សាក្សី, អ្នកបកប្រែ, និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី តាមគ្រប់មធ្យោបាយទោះបីដោយផ្ទាល់មាត់ក៏ដោយ ។

### គ. មូលហេតុនៃការរលត់បណ្តឹងអាជ្ញា

បើទោះបីជាបុគ្គលគ្រប់រូបមានសិទ្ធិអាចធ្វើបណ្តឹងអាជ្ញាបានក៏ពិតមែន ប៉ុន្តែមិនមែនពួកគេសុទ្ធតែអាចប្តឹងបានគ្រប់កាលៈទេសៈ ឬ គ្រប់ពេលនោះទេ ច្បាប់បានកំណត់អំពីស្ថានភាពខ្លះរួមទាំងរយៈពេលដែល បណ្តឹងអាជ្ញាមិនអាចធ្វើទៅបាន ។

បណ្តឹងអាជ្ញាត្រូវបានរលត់ដោយមូលហេតុ ដែលមានចែងក្នុងមាត្រា៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌដូចខាងក្រោម៖

- មរណភាពនៃជនល្មើស : ជនដែលប្រព្រឹត្តត្រូវបានស្លាប់។

[23] មាត្រា២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[24] មាត្រា២៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

- ការផុតអាជ្ញាយុកាល : ការផុតអាជ្ញាយុកាលនេះ គឺសំដៅដល់អាជ្ញាយុកាលនៃបទល្មើស ដែលមានកំណត់នៅក្នុងមាត្រា ១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលបានចែងពីថិរវេលានៃអាជ្ញាយុកាលនៃបណ្ដឹងអាជ្ញាថា:
    - ១៥ឆ្នាំ ចំពោះបទឧក្រិដ្ឋ
    - ៥ឆ្នាំ ចំពោះបទមជ្ឈឹម
    - ១ឆ្នាំ ចំពោះបទលហុ[25] ។

ចំពោះបទល្មើសមួយចំនួនដែលមានចែងក្នុងមាត្រា៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គឺមានបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម ដែលបទឧក្រិដ្ឋទាំងបីនេះ មិនអាចផុតអាជ្ញាយុកាលទេ មានន័យថាមិនមានកំណត់អាជ្ញាយុកាលនៃការប្ដឹងទេ[26] ។

- ការលើកលែងទោសជាទូទៅ គឺត្រូវបានធ្វើឡើងដោយព្រះមហាក្សត្រ ដោយមានការស្នើសុំពីក្រសួងយុត្តិធម៌ ។
- និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ ។
- អាជ្ញាអស់ជំនុំ ជាគោលការណ៍នេះមានន័យថា ជនណាដែលត្រូវបានតុលាការសម្រេចឲ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនត្រូវបានតុលាការធ្វើការចោទប្រកាន់ទៀតឡើយ ចំពោះអំពើដដែលនោះ ទោះបីជាស្ថិតក្រោមការកំណត់ឈ្មោះបទល្មើសផ្សេងៗក៏ដោយ[27] ។

ក្រៅពីមូលហេតុនៃការរលត់បណ្ដឹងអាជ្ញាខាងលើនេះ ក៏មានមូលហេតុផ្សេងទៀតនៃការរលត់បណ្ដឹងអាជ្ញានេះ ដែលកាលណាច្បាប់ដោយឡែកបានចែងដោយជាក់លាក់ នោះបណ្ដឹងអាជ្ញាក៏អាចផុតរលត់បានដែរ:

- ដោយការសម្របសម្រួលជាមួយរដ្ឋ ។
- ដោយការដកពាក្យបណ្ដឹង នៅក្នុងករណីដែលពាក្យប្ដឹងនេះជាលក្ខខណ្ឌចាំបាច់ នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ ។
- ដោយការបង់ប្រាក់ពិន័យសរុប ឬប្រាក់ពិន័យសម្របសម្រួល[28] ។

---

[25] មាត្រា១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[26] មាត្រា៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[27] មាត្រា១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[28] មាត្រា៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

កាលណាបណ្តឹងអាជ្ញាត្រូវបានរលត់ តាមរយៈមូលហេតុខាងលើហើយនោះ ការចោទប្រកាន់ខាងបទល្មើសព្រហ្មទណ្ឌ ក៏មិនអាចចាប់ផ្តើមបានទៀតទេ គឺត្រូវតែបញ្ឈប់ ។

## កថាខណ្ឌទី២. វិធីសាស្ត្រនៃការធ្វើបណ្តឹងរដ្ឋប្បវេណី

### ក. ការចាប់ផ្តើមនៃបណ្តឹងរដ្ឋប្បវេណី

ច្បាប់បានបង្កើតគោលការណ៍ក្នុងការធ្វើបណ្តឹងរដ្ឋប្បវេណីឡើង គឺដើម្បីឲ្យជនរងគ្រោះមានសិទ្ធិទាមទារនូវប្រាក់សំណង ចំពោះការខូចខាតជាក់ស្តែងដែលខ្លួនបានទទួល តាមរយៈទង្វើដែលជនល្មើសប្រព្រឹត្តមកលើខ្លួននោះ ។ ដូចនេះយើងឃើញថាបុគ្គលដែលចាប់ផ្តើមបណ្តឹងរដ្ឋប្បវេណី គឺបានផ្តោតសំខាន់ទៅលើជនរងគ្រោះផ្ទាល់ ។ ក្រៅពីនេះ យោងតាមគោលការណ៍នៃក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ អំពីសិទ្ធិរបស់បុគ្គល ឬស្ថាប័នមួយចំនួន ដែលអាចតំណាងឲ្យជនរងគ្រោះក្នុងការចាប់ផ្តើមបណ្តឹងនេះបានផងដែរ ។

### ១. ការចាប់ផ្តើមដោយជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់

ជាទូទៅ បុគ្គលគ្រប់រូបដែលប្រកាសថា ខ្លួនជាអ្នករងគ្រោះនៃបទល្មើស អាចដាក់ពាក្យប្តឹងបាន ។ ដែលបណ្តឹងនេះ ជាពាក្យបណ្តឹងសាមញ្ញ គ្មានអានុភាពនាំឲ្យធ្វើការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌទេ ។ ស្របតាមមាត្រា ១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ថា "បណ្តឹងរដ្ឋប្បវេណី អាចត្រូវធ្វើឡើងក្នុងនាមជនរងគ្រោះបាន ដោយអ្នកតំណាងស្របច្បាប់របស់ខ្លួន កាលណាជនរងគ្រោះនេះជាអនីតិជន ឬជានីតិជនស្ថិតក្រោមរបបច្បាប់ការពារ" ។ តាមគោលការណ៍នេះ បង្ហាញថាជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់ នៃបទល្មើសឧក្រិដ្ឋ ឬ មជ្ឈិម អាចដាក់ពាក្យបណ្តឹងដោយការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរដោយប្តឹងទៅលើបុគ្គលម្នាក់ ឬ ច្រើននាក់ ។ គួរបញ្ជាក់ផងដែរថា នីតិជនដែលស្ថិតក្រោមរបបច្បាប់ការពារ ដែលបានបញ្ញត្តិខាងលើនេះ គឺសំដៅចំពោះជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ និងជនដែលស្ថិតក្រោមហិតូបត្ថម្ភ ។ តាមរយៈនេះបង្ហាញថា សូម្បីតែជនដែលមិនមានសមត្ថភាពក្នុងការធ្វើបណ្តឹងបានដោយខ្លួនឯង តែក៏អាចទទួលបាននូវការតំណាងដើម្បីទាមទារសំណងចំពោះការខូចខាតដែលបានកើតឡើងមកលើខ្លួនបានដែរ ។ ក្រៅពីជនរងគ្រោះខ្លួនឯង ឬ អ្នកតំណាងស្របច្បាប់ តើជនណាទៀតដែលអាចផ្តើមធ្វើបណ្តឹងរដ្ឋប្បវេណីបាន ?

### ២. ការចាប់ផ្តើម ឬ បន្តដោយសិទ្ធិវ័ន្តនៃជនរងគ្រោះ

សិទ្ធិវ័ន្តសំដៅចំពោះអ្នកបន្តសិទ្ធិ ឬ ជាទាយាទរបស់ជនរងគ្រោះ ។ បណ្តឹងរដ្ឋប្បវេណី ដែលចាប់ផ្តើមឡើងដោយជនរងគ្រោះ គឺចំពោះតែក្នុងលក្ខខណ្ឌដែលជនរងគ្រោះនៅរស់តែប៉ុណ្ណោះ ដោយឡែក

ករណីដែលជនរងគ្រោះទទួលមរណភាព បណ្តឹងរដ្ឋប្បវេណីអាចត្រូវបានផ្តើម ឬ បន្តបានដោយសិទ្ធិវន្ត[29] ។ ចំណុចនេះ អាចស្ថិតនៅក្នុងលក្ខខណ្ឌ ដែលជនរងគ្រោះបានស្លាប់ភ្លាមៗបន្ទាប់ពី ជនល្មើសបានប្រព្រឹត្តបទល្មើស ដូចនេះសិទ្ធិវន្តត្រូវដើរតួរជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងចាប់ផ្តើមបណ្តឹងនេះតែម្តង ។ មួយវិញទៀត នីតិវិធីនៃបណ្តឹងកំពុងតែដំណើរការ ស្របពេលនោះជនរងគ្រោះបានទទួលមរណភាព ដូចនេះសិទ្ធិវន្តត្រូវក្លាយជាដើមបណ្តឹងបណ្តឹងរដ្ឋប្បវេណី និងចូលរួមបន្តនីតិវិធីនៃបណ្តឹងនោះ ។

**អង្គភាព ឬ ស្ថាប័នផ្សេងទៀត**

ក្រៅពីបុគ្គលទាំងអស់ដែលបានកំណត់ខាងលើ ច្បាប់បានកំណត់អំពីស្ថាប័ន ឬ អង្គភាពមួយចំនួនទៀតដែលអាចធ្វើសកម្មភាពបណ្តឹងរដ្ឋប្បវេណីជំនួសជនរងគ្រោះបាន រួមមានដូចខាងក្រោម ៖

- សមាគមប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាខាងផ្លូវភេទ អំពើហិង្សាក្នុងគ្រួសារ ឬអំពើហិង្សាប្រឆាំងនឹងកុមារ តែត្រូវបានគោរពនូវលក្ខខណ្ឌមួយគឺគ្រប់សមាគមដែលបានប្រកាសដោយត្រឹមត្រូវយ៉ាងតិចបំផុតតាំងពី ៣(បី)ឆ្នាំ មុនពេលបរិច្ឆេទនៃបទល្មើស ហើយដែលកម្មវត្ថុនៃលក្ខន្តិកៈរបស់ខ្លួន រួមមានការតស៊ូប្រឆាំង នឹងអំពើហិង្សាខាងផ្លូវភេទឬអំពើហិង្សាក្នុងគ្រួសារ ឬអំពើហិង្សាប្រឆាំងនឹងកុមារនោះ អាចប្រើប្រាស់សិទ្ធិដែទទួលស្គាល់ដល់ដើមបណ្តឹងរដ្ឋប្បវេណី ចំពោះប្រភេទបទល្មើស ១. ការបៀតបៀនដោយចេតនាអាយុជីវិត ២. ការបៀតបៀនដល់បូរណភាពនៃបុគ្គល ៣. ការបៀតបៀនខាងផ្លូវភេទ ។
- សមាគមប្រយុទ្ធប្រឆាំងនឹងការចាប់ពង្រត់ ការជួយដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ សមាគមដែលមានលក្ខណៈបែបនេះត្រូវប្រកាសដោយត្រឹមត្រូវ យ៉ាងតិចតាំងពី ០៣ (បី) ឆ្នាំមុនកាលបរិច្ឆទនៃបទល្មើស ហើយកម្មវត្ថុនៃលក្ខន្តិកៈរួមមានការតស៊ូប្រឆាំងនឹងការចាប់ពង្រត់ ឬការជួញដូរមនុស្ស និងការធ្វើអាជីវកម្មខាងផ្លូវភេទ អាចប្រើប្រាស់សិទ្ធិដែលទទួលបានដោយដើមបណ្តឹងរដ្ឋប្បវេណី ចំពោះបទល្មើសដែលបញ្ញត្តិដោយច្បាប់ដែលពាក់ព័ន្ធនឹងការប្រឆាំងការចាប់ពង្រត់ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ។
- សមាគមប្រយុទ្ធប្រឆាំងនិងការប្រកាន់ពូជសាសន៍ និងការរើសអើងត្រូវបានប្រកាសដោយត្រឹមត្រូវយ៉ាងតិច០៣ (បី)ឆ្នាំមុនពេលបរិច្ឆេទនៃបទល្មើស ហើយកម្មវត្ថុនៃ

[29] មាត្រា១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

លក្ខន្តិក:រួមមានការតស៊ូប្រឆាំងនឹងការប្រកាន់ពូជសាសន៍ និងឧបត្ថម្ភដល់ជនរងគ្រោះនៃការរើសអើងស្តីពីដើមកំណើត ជាតិពន្ធុ ពូជសាសន៍ សាសនា អាចប្រើប្រាស់សិទ្ធិដែលទទួលស្គាល់ដល់ដើមបណ្តឹងរដ្ឋប្បវេណី ចំពោះបទល្មើសដូចដែលបានកំណត់ កាលណាបទល្មើសនេះត្រូវបានប្រព្រឹត្តដោយមូលហេតុដើមកំណើតជាតិនៃបុគ្គលម្នាក់ឬដោយមូលហេតុថា បុគ្គលនោះជាសមាជិកពិតប្រាកដ ឬដោយស្មាននៃជាតិពន្ធុ ពូជសាសន៍ ឬសាសនាមួយជាកំណត់ នូវការរើសអើង ការបៀតបៀនដោយចេតនា ដល់អាយុជីវិត ឬដល់បូរណភាពបុគ្គល កាប់បំផ្លាញ និងការធ្វើឲ្យខូចខាត[30] ។

**ខ. ការធ្វើបណ្តឹងរដ្ឋប្បវេណី**

ជាទូទៅ នៅពេលដែលមានបទល្មើសព្រហ្មទណ្ឌមួយកើតឡើង គឺតែងតែមានការទាមទារសំណងការខូចខាតពីសំណាក់ជនរងគ្រោះ ដូចនេះបណ្តឹងរដ្ឋប្បវេណីគឺត្រូវធ្វើឡើងជាមួយនឹងបណ្តឹងព្រហ្មទណ្ឌដែរ ។ ប៉ុន្តែ ក្នុងករណីខ្លះបណ្តឹងរដ្ឋប្បវេណី ក៏អាចធ្វើដាច់ដោយឡែកពីបណ្តឹងព្រហ្មទណ្ឌផងដែរ ។

**១. បណ្តឹងរដ្ឋប្បវេណី ដែលធ្វើឡើងជាមួយបណ្តឹងអាជ្ញា**

ផ្អែកតាមគោលការណ៍ច្បាប់ រួមទាំងការអនុវត្តជាក់ស្តែងផងដែរ បណ្តឹងរដ្ឋប្បវេណីត្រូវធ្វើឡើងដំណាលគ្នាជាមួយនឹងបណ្តឹងព្រហ្មទណ្ឌ នៅចំពោះមុខសាលាជម្រះក្តីព្រហ្មទណ្ឌ [31]។ ក្នុងលក្ខខណ្ឌដែលបណ្តឹងរដ្ឋប្បវេណី ធ្វើឡើងជាមួយបណ្តឹងព្រហ្មទណ្ឌ វាមិនទាមទារទម្រង់លាយល័ក្ខអក្សរច្បាស់លាស់នោះទេ ដោយដើមបណ្តឹងរដ្ឋប្បវេណី គ្រាន់តែបង្ហាញឆន្ទ:របស់ខ្លួនក្នុងការទាមទារនូវសំណង តាមរយ:ការសាកសួររបស់នគរបាលយុត្តិធម៌ ឬ ព្រះរាជអាជ្ញាជាការគ្រប់គ្រាន់ ។ ផ្អែកតាមការអនុវត្តន៍ជាក់ស្តែង នៅពេលដែលមានបទល្មើសព្រហ្មទណ្ឌមួយកើតឡើង ហើយត្រូវបានប្តឹងទៅមន្ត្រីនគរបាលយុត្តិធម៌ ឬ ប្តឹងផ្ទាល់ទៅកាន់តុលាការ នោះមន្ត្រីនគរបាលយុត្តិធម៌ ឬ ព្រះរាជអាជ្ញា នឹងកោះហៅជនរងគ្រោះមកសាកសួរបញ្ជាក់អំពីឆន្ទ: នៃការប្តឹងទាមទារសំណងរដ្ឋប្បវេណី ថាតើចង់ប្តឹងឬទេ ឬ តើនឹងទាមទារសំណងយ៉ាងដូចម្តេច ? រាល់ការបញ្ជាក់អំពីការទាមទាររបស់ជនរងគ្រោះ នឹងត្រូវបានសរសេរចូលក្នុងពាក្យបណ្តឹង ជាមួយនឹងការប្តឹងផ្នែកព្រហ្មទណ្ឌ ។ គួរបញ្ជាក់ផងដែរថា នីតិវិធីនៃការធ្វើបណ្តឹងរដ្ឋប្បវេណី ដែលធ្វើឡើងដំណាលគ្នាជាមួយនឹងបណ្តឹងព្រហ្មទណ្ឌនេះ មិនចាំបាច់ស្របតាមនីតិវិធីស្មុគស្មាញនៃវិធាន

[30] មាត្រា ១៧ ដល់ ១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[31] មាត្រា២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

រដ្ឋប្បវេណីនោះទេ គ្រប់នីតិវិធីនៃការដោះស្រាយលើបណ្តឹងនេះ នឹងដំណើរការទៅដំណាលគ្នាជាមួយនឹងនីតិវិធីដោះស្រាយបណ្តឹងព្រហ្មទណ្ឌ ដោយចៅក្រមជាអ្នកកំណត់អំពីការអនុវត្តន៍ នីតិវិធីដោះស្រាយសំណងរដ្ឋប្បវេណី ដែលជនរងគ្រោះបានទាមទារ នៅអំឡុងពេលសវនាការ ។

នីតិវិធីខាងលើនេះ ត្រូវបានតុលាការរាជធានី-ខេត្តទាំងអស់បានយកមកអនុវត្តជាក់ស្តែង វាបានផ្តល់នូវភាពងាយស្រួល ដោយចំណាយពេលវេលាតិចក្នុងដំណើរការដោះស្រាយ នីតិវិធីមិនសូវស្មុគស្មាញ មិនចាំបាច់ចំណាយក្នុងការបង់ពន្ធលើបណ្តឹង និងមានប្រសិទ្ធិភាពផងដែរ ។ តើបណ្តឹងរដ្ឋប្បវេណី អាចធ្វើដាច់ដោយឡែកពីបណ្តឹងព្រហ្មទណ្ឌបានដែររឺទេ ?

**២. បណ្តឹងរដ្ឋប្បវេណីដែលធ្វើឡើងដាច់ដោយឡែក**

បណ្តឹងរដ្ឋប្បវេណី អាចធ្វើឡើងស្របតាមវិធាននៃនីតិវិធីរដ្ឋប្បវេណី ដែលនីតិវិធីនេះត្រូវដំណើរការដាច់ដោយឡែកពី នីតិវិធីនៃការធ្វើបណ្តឹងព្រហ្មទណ្ឌ ។ នីតិវិធីដាច់ដោយឡែកនេះ គឺបណ្តឹងរដ្ឋប្បវេណី ត្រូវធ្វើនៅចំពោះមុខសាលាជម្រះក្តីរដ្ឋប្បវេណី ដែលនៅក្នុងករណីនេះ បណ្តឹងរដ្ឋប្បវេណីអាចត្រូវបានព្យួរសិន ដរាបណាមិនទាន់មាន សេចក្តីសម្រេចជាស្ថាពរមួយត្រូវបានប្រកាស លើបណ្តឹងអាជ្ញា ។ បានន័យថា ជនរងគ្រោះត្រូវរង់ចាំរហូតដល់តុលាការចេញសាលក្រមស្ថាពរ អំពីបណ្តឹងព្រហ្មទណ្ឌសិន ទើបអាចទទួលបានដំណើរការដោះស្រាយបណ្តឹងរដ្ឋប្បវេណីពីតុលាការបាន ។ បណ្តឹងរដ្ឋប្បវេណីដែលធ្វើឡើងតាមនីតិវិធីនេះ ត្រូវធ្វើជាទម្រង់លាយល័ក្ខអក្សរមួយដាច់ដោយឡែក និងត្រូវភ្ជាប់មកជាមួយនូវឯកសារជាសំអាងផ្សេងៗជាច្រើនទៀតដើម្បីគាំទ្រការទាមទារ ។

ចំពោះនីតិវិធីខាងលើនេះ នៅក្នុងការអនុវត្តន៍ជាក់ស្តែង គេសង្កេតឃើញមិនទាន់មានតុលាការរាជធានី-ខេត្តណាមួយយកមកអនុវត្តន៍នោះទេ ព្រោះវាមានផលលំបាកជាងការអនុវត្តន៍នីតិវិធីធ្វើបណ្តឹងរដ្ឋប្បវេណីជាមួយគ្នានឹងបណ្តឹងអាជ្ញា ដោយត្រូវចំណាយពេលរង់ចាំរហូតដល់ចេញសាលក្រមស្ថាពរ ហើយដើមបណ្តឹងរដ្ឋប្បវេណីត្រូវចំណាយប្រាក់បង់ពន្ធពាក្យបណ្តឹង នៅពេលដែលយកពាក្យបណ្តឹងទៅដាក់នៅតុលាការ ។

**គ. មូលហេតុនៃការរលត់បណ្តឹងរដ្ឋប្បវេណី**

ជាក់ស្តែងនៅពេលដែលមានបណ្តឹងរដ្ឋប្បវេណីមួយបានធ្វើឡើងដោយជនរងគ្រោះ ឬអ្នកតំណាងរបស់ជនរងគ្រោះ នោះតុលាការនឹងចាប់ផ្តើមដំណើរការនីតិវិធីលើបណ្តឹងមួយនោះ។ ទន្ទឹមនឹងការដំណើរការនីតិវិធីនេះ ក៏មានមូលហេតុមួយចំនួនដែលបណ្តាលឲ្យបណ្តឹងរដ្ឋប្បវេណីរលត់ផងដែរ ដែលមូលហេតុទាំងអស់នេះមានដូចតទៅ៖

- ការលះបង់របស់ជនរងគ្រោះ និងការដកពាក្យបណ្តឹងរបស់ជនរងគ្រោះ : ជនរងគ្រោះអាចលះបង់មិនធ្វើបណ្តឹងទាមទារសំណង ឬដកពាក្យបណ្តឹងរបស់ខ្លួន។ ការលះបង់មិនប្តឹង និងដកពាក្យបណ្តឹងរបស់ជនរងគ្រោះ មិនអាចបញ្ឈប់ ឬព្យួរការអនុវត្តនៃបណ្តឹងអាជ្ញាបានទេ លើកលែងបញ្ញត្តិចំណុចទី២ នៃមាត្រា ៨ (មូលហេតុផ្សេងទៀតនៃការរលត់បណ្តឹងអាជ្ញា) នៃក្រមនេះ[32] ។
- អាជ្ញាយុកាលនៃបណ្តឹងរដ្ឋប្បវេណី: បណ្តឹងរដ្ឋប្បវេណីត្រូវផុតអាជ្ញាយុកាលតាមវិធាននៃក្រមរដ្ឋប្បវេណី ។ ប៉ុន្តែបណ្តឹងរដ្ឋប្បវេណីនេះ មិនអាចធ្វើបានទៀតទេនៅមុខតុលាការព្រហ្មទណ្ឌ ក្រោយពីផុតថិរវេលានៃអាជ្ញាយុកាលរបស់បណ្តឹងអាជ្ញា[33]។

[32] មាត្រា២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[33] មាត្រា២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

# ជំពូកទី៣. ការធ្វើបណ្តឹងតវ៉ា

នៅពេលដែលដំណើរការនីតិវិធីនៃការធ្វើបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី ចប់សព្វគ្រប់ហើយ និងឈានដល់ដំណាក់កាលតុលាការចេញសេចក្តីសម្រេច ជនរងគ្រោះ ឬ ជនជាប់ចោទធ្វើការពិចារណាទៅលើសេចក្តីសម្រេចនោះ ថាតើសមស្រប និងអាចទទួលយកបានដែរឬទេ ។ ក្នុងករណីដែលភាគីណាមួយមិនសុខចិត្តនឹងសេចក្តីសម្រេចនោះទេ ច្បាប់បានកំណត់អំពីសិទ្ធិនៃការធ្វើបណ្តឹងតវ៉ា ក្នុងគោលបំណងការពារនូវផលប្រយោជន៍របស់ភាគីផងដែរ ។

## ផ្នែកទី ១. បណ្តឹងតវ៉ាសាមញ្ញ

### កថាខណ្ឌទី ១. បណ្តឹងទាស់

បណ្តឹងទាស់ គឺជាប្រភេទបណ្តឹងតវ៉ាមួយ ដែលផ្តល់សិទ្ធិឲ្យពិរុទ្ធជនអាចបណ្តឹងទាស់នឹងសាលក្រម ដែលប្រកាសដោយកំបាំងមុខខ្លួនបាន មានន័យថា នៅអំឡុងពេលសវនាការពិរុទ្ធជនមិនមានវត្តមាននៅទីនោះ ឬប្រសិនបើគ្មានភស្តុតាងបង្ហាញឲ្យឃើញថាសាមីខ្លួនដឹងពីដីកាបញ្ជូនទៅជំនុំជម្រះ ឬ បានដឹងអំពីការកោះហៅនោះទេ ពិរុទ្ធជនអាចធ្វើបណ្តឹងទាស់បាន ។ មិនត្រឹមតែសាលក្រមកំបាំងមុខនោះទេ បណ្តឹងទាស់ក៏អាចធ្វើបានចំពោះសាលដីកាកំបាំងមុខផងដែរ[34] ដោយនីតិវិធីនៃបណ្តឹងទាស់ចំពោះសាលដីកាកំបាំងមុខ គឺដូចគ្នាទៅនឹងនីតិវិធីនៃបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ ខុសគ្នាចំពោះតែសមត្ថកិច្ចតុលាការប៉ុណ្ណោះ ( បណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ តុលាការដំបូងមានសមត្ថកិច្ច ចំណែកបណ្តឹងទាស់ចំពោះសាលដីកាកំបាំងមុខ តុលាការឧទ្ធរណ៍មានសមត្ថកិច្ច ) ។

ពិរុទ្ធជនដែលមានបំណងប្តឹងទាស់ត្រូវគោរពទៅតាមពេលវេលាដែលច្បាប់បានកំណត់ គឺ ១៥ថ្ងៃ ដោយផ្តើមគិតពីថ្ងៃជូនដំណឹងអំពីសាលក្រមកំបាំងមុខ ករណីសាលក្រមត្រូវបានប្រគល់ឲ្យពិរុទ្ធជនដោយផ្ទាល់ដៃ ឬ ពីថ្ងៃដែលពិរុទ្ធជននេះបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម ករណីសាលក្រមនេះ មិនបានប្រគល់ឲ្យពិរុទ្ធជនដោយផ្ទាល់ដៃនោះទេ[35] ។

បណ្តឹងទាស់ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ នៅការិយាល័យក្រឡាបញ្ជី នៃតុលាការដែលប្រកាសសាលក្រម ឬនៅចំពោះមុខព្រះរាជអាជ្ញា អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ឬនៅចំពោះមុខប្រធានពន្ធនាគារ ឬនៅមណ្ឌលឃុំខ្លួន តែត្រូវបញ្ជូនបណ្តឹងទាស់នោះភ្លាមទៅក្រឡាបញ្ជី

[34] មាត្រា៤០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[35] មាត្រា៣៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

នៃតុលាការដែលបានប្រកាសសាលក្រម ។ ពិរុទ្ធជនអាចត្រូវបានតំណាងដោយមេធាវីចំពោះពិរុទ្ធជនជាអនីតិជន អាចត្រូវបានតំណាងដោយឪពុក ម្តាយ ឬអាណាព្យាបាល។ ការជំនុំជម្រះទៅលើបណ្តឹងទាស់នេះ គឺត្រូវធ្វើនៅតុលាការដដែល មានន័យថាជាតុលាការដែលបានចេញសាលក្រមកំបាំងមុខ ។ ចំពោះការសម្រេចសេចក្តីឡើងវិញនៃបណ្តឹងទាស់នេះ ត្រូវអនុលោមតាមមាត្រា ៣៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បណ្តឹងទាស់ មានអានុភាពធ្វើឡើងប្រឆាំងទៅលើសាលក្រមទាំងមូល សាលក្រមនោះត្រូវទុកជាអសារបង់ និងព្យួរការអនុវត្តសេចក្តីសម្រេចនោះ ប៉ុន្តែដីកាបង្គាប់ឲ្យចាប់ខ្លួននៅតែមានអនុភាព[36] ។

ដើមបណ្តឹងរដ្ឋប្បវេណី ក៏អាចប្តឹងទាស់នឹងសាលក្រម ដែលសម្រេចដោយកំបាំងមុខបានដែរ។ បណ្តឹងទាស់នេះ ត្រូវកំណត់ទៅលើសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីនៃសាលក្រមតែប៉ុណ្ណោះ[37]។ ដោយរយៈពេលនៃការប្តឹងទាស់របស់ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវអនុលោមតាមមាត្រា ៣៧២នៃក្រមនីតិធីព្រហ្មទណ្ឌ ។ កាលណាបណ្តឹងទាស់ធ្វើឡើងប្រឆាំងនឹងសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី មានតែសេចក្តីសម្រេចផ្នែកនេះ ដែលត្រូវទុកជាអសារបង់ ។ ការអនុវត្តសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីនេះត្រូវព្យួរ។

**កថាខណ្ឌទី ២. បណ្តឹងឧទ្ធរណ៍**

បណ្តឹងឧទ្ធរណ៍ គឺជាផ្លូវតវ៉ាឲ្យកែប្រែសេចក្តីសម្រេចសាលាដំបូង ធ្វើឡើងទៅកាន់សាលាឧទ្ធរណ៍[38] ។ ចំពោះបុគ្គលដែលអាចធ្វើបណ្តឹងឧទ្ធរណ៍បានមានដូចជា:

- ព្រះរាជអាជ្ញានៃតុលាការជាន់ដំបូង និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
- ពិរុទ្ធជន
- ដើមបណ្តឹងរដ្ឋប្បវេណី ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី
- អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី[39] ។

បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ត្រូវធ្វើឡើងនៅការិយាល័យក្រឡាបញ្ជី នៃតុលាការដែលបានប្រកាសសាលក្រម។ ពិរុទ្ធជនអាចត្រូវតំណាងដោយមេធាវី តែមេធាវិត្រូវតែមានលិខិតប្រគល់សិទ្ធិឲ្យធ្វើបណ្តឹងឧទ្ធរណ៍។

[36] មាត្រា៣៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[37] មាត្រា៣៦៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[38] មាត្រា៣៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[39] មាត្រា៣៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ចំពោះពិរុទ្ធជនដែលជាអនីតិជន អាចតំណាងដោយឲ្យឪពុកម្តាយ ឬអ្នកអាណាព្យាបាល ដែលក្នុងករណីនេះអ្នកតំណាងមិនចាំបាច់មានលិខិតប្រគល់សិទ្ធិនោះទេ។ ចំពោះដើម្បីបណ្តឹងរដ្ឋប្បវេណី ដែលប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី អាចធ្វើតាមរយៈអ្នកតំណាងរបស់ខ្លួនបានដែរ ដូចដែលមានចែងក្នុងមាត្រា ៣៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដោយត្រូវមានលិខិតប្រគល់សិទ្ធិ ។ ពាក្យបណ្តឹងឧទ្ធរណ៍ ត្រូវបានក្រឡាបញ្ជីចុះក្នុងបញ្ជីពិសេស ដោយមានចុះហត្ថលេខារបស់ភាគីដែលពាក់ព័ន្ធ ។

ពិរុទ្ធជនដែលជាប់ឃុំខ្លួន អាចសំដែងឆន្ទៈរបស់ខ្លួនក្នុងការធ្វើបណ្តឹងឧទ្ធរណ៍នៅចំពោះមុខប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ។ ពិរុទ្ធជនដែលបំពេញពាក្យបណ្តឹងឧទ្ធរណ៍ត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា ឬផ្តិតស្រាមដៃ ។ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ត្រូវចុះបណ្តឹងឧទ្ធរណ៍លើបញ្ជីពិសេស ពិរុទ្ធជនត្រូវចុះហត្ថលេខា ឬផ្តិតមេដៃលើរឹមនៃបញ្ជី រួចប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ត្រូវបញ្ជូនបណ្តឹងឧទ្ធរណ៍ក្នុងរយៈពេលយ៉ាងខ្លីបំផុត ទៅក្រឡាបញ្ជីនៃតុលាការដែលត្រូវចុះនិទ្ទេស អំពីពាក្យបណ្តឹងឧទ្ធរណ៍នេះនៅលើបញ្ជីបណ្តឹងឧទ្ធរណ៍នៃតុលាការ[40] ។

បណ្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា ត្រូវធ្វើតាមពាក្យបណ្តឹងនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងពីអគ្គព្រះរាជអាជ្ញាហើយ ក្រឡាបញ្ជីត្រូវចុះលិខិតបណ្តឹងឧទ្ធរណ៍នៅលើបញ្ជីពិសេស[41] ។

រយៈពេលនៃការធ្វើបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញានៃតុលាការជាន់ដំបូង មានរយៈពេល ១ (មួយ) ខែ និងចំពោះអគ្គព្រះរាជអាជ្ញា ត្រូវតែធ្វើក្នុងរយៈពេល៣ (បី) ខែ រយៈពេលនេះគឺត្រូវគិតចាប់ពីថ្ងៃប្រកាសសាលក្រម[42] ។

ចំណែកពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ត្រូវតែធ្វើក្នុងរយៈពេល១ (មួយ) ខែក្នុងករណីសាលក្រមចំពោះមុខ ដែលគិតចាប់ពីថ្ងៃប្រកាសសាលក្រម ។ កាលណាសាលក្រមចាត់ទុកចំពោះមុខរយៈពេលក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ គិតចាប់ពីថ្ងៃទទួលបានដំណឹងសាលក្រម[43] ។ ក្នុងករណីភាគីណាមួយបានប្តឹងឧទ្ធរណ៍ខាងលើ ភាគីដទៃទៀតមាន

[40] មាត្រា៣៧៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[41] មាត្រា៣៧៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[42] មាត្រា៣៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[43] មាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

រយៈពេលបន្ថែម ៧ (ប្រាំពីរ) ថ្ងៃ ដើម្បីធ្វើបណ្តឹងឧទ្ធរណ៍ឧប្បត្តិហេតុ ដែលរយៈពេលបន្ថែមគិតចាប់ពីការផុតរយៈពេលធម្មតា[44] ។

ដោយឡែកក្នុងរឿងឃុំខ្លួន ការធ្វើបណ្តឹងឧទ្ធរណ៍ត្រូវធ្វើដោយព្រះរាជអាជ្ញាក្នុងរយៈពេល ៤៨ (សែសិបប្រាំបី) ម៉ោង និងដោយពិរុទ្ធជនក្នុងរយៈពេល ៥ (ប្រាំ) ដោយផ្តើមគិតពីថ្ងៃដែលតុលាការសម្រេចការឃុំខ្លួន[45] ។

កាលណាតុលាការចេញសាលក្រមចាត់របៀប បណ្តឹងឧទ្ធរណ៍អាចត្រូវទទួលភ្លាម ប្រសិនបើសាលក្រមនេះបញ្ចប់នីតិវិធី។ ក្នុងករណីផ្ទុយពីនេះ សាលក្រមចាត់របៀបនឹងអាចត្រូវដាក់ជូនសាលាឧទ្ធរណ៍ពិនិត្យបាន លុះត្រាតែធ្វើព្រមគ្នាជាមួយសាលក្រមលើអង្គសេចក្តី[46] ។

បណ្តឹងឧទ្ធរណ៍គឺមិនត្រូវបានលុបចោលនីតិវិធីមុននោះទេ វាគ្រាន់តែតវ៉ាលើនីតិវិធីនេះ ដើម្បីឲ្យមានការជំនុំជម្រះម្តងទៀត នូវចំណុចអង្គហេតុ និងអង្គច្បាប់ ដែលតុលាការថ្នាក់ដំបូងបានសម្រេចរួចមកហើយ។ យោងតាមខ្លឹមសារនៃមាត្រា ៤០១នៃក្រមនីតិវិធីព្រហ្មទណ្ឌបានបង្ហាញថា សាលាឧទ្ធរណ៍ទទួលបានសិទ្ធិពិនិត្យសាជាថ្មី នូវមធ្យោបាយដែលបន្ថែមលើពាក្យសុំ ដែលបានធ្វើរួចមកហើយនៅមុខតុលាការជាន់ដំបូង ប៉ុន្តែមិនអនុញ្ញាតឲ្យសាលាឧទ្ធរណ៍ទទួលពាក្យសុំថ្មីដែលតុលាការជាន់ដំបូងមិនបានទទួល ទោះបីជាបណ្តឹងអាជ្ញា (ការផ្តន្ទាទោសចំពោះបទល្មើសថ្មីដែលលើកឡើងពេលពិភាក្សាដេញដោល ក្នុងសវនាការសាលាឧទ្ធរណ៍ ឬការលើកឡើងបុគ្គលផ្សេងទៀត ក្រៅពីបុគ្គលដែលបានផ្តន្ទាទោសនៅសាលាដំបូង) ឬដើមបណ្តឹងរដ្ឋប្បវេណី (ការទទួលយកការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីថ្មី)។ ក្នុងករណីបណ្តឹងឧទ្ធរណ៍ លើសាលក្រមចាត់ទុកថាចំពោះមុខ បុគ្គលពាក់ព័ន្ធ អាចលើកមធ្យោបាយខាងលើនេះចំពោះមុខសាលាឧទ្ធរណ៍បាន។ នីតិវិធីនៅចំពោះមុខសាលាឧទ្ធរណ៍ ដើម្បីដោះស្រាយបណ្តឹងនេះ តុលាការត្រូវអនុវត្តស្របតាមបទបញ្ញត្តិមាត្រា ៣៨៦ ដល់មាត្រា ៣៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

ចំពោះអានុភាពនៃបណ្តឹងឧទ្ធរណ៍ គឺ ការអនុវត្តសាលក្រមត្រូវបង្អង់សិនក្នុងរយៈពេលបណ្តឹងឧទ្ធរណ៍ លើកលែងតែទាក់ទងនឹងការឃុំខ្លួនរបស់ជនជាប់ចោទ ឬចុងចោទ។ ការឃុំខ្លួនអាចរក្សាទុកក្នុងរយៈពេលប្តឹងឧទ្ធរណ៍ វាអាចរក្សាទុកដល់ពេលសាលាឧទ្ធរណ៍ធ្វើសេចក្តីសម្រេច ។

[44] មាត្រា៣៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[45] មាត្រា៣៨៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[46] មាត្រា៣៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ប៉ុន្តែក្នុងករណីតុលាការដំបូងសម្រេចឲ្យរួចខ្លួន ឬ ប្រសិនបើរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ស្មើនឹងរយៈពេលនៃទោសជាប់ពន្ធនាគារ ព្រះរាជអាជ្ញាអាចយល់ព្រមដោះលែងជនជាប់ចោទឲ្យមានសេរីភាព មុនពេលផុតកំណត់រយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍[47] ។ សាលាឧទ្ធរណ៍មានអំណាចពេញបរិបូរណ៍ ដោយអាចបដិសេធសាលក្រមដែលសម្រេចឲ្យរួចខ្លួន ឬអាចសម្រេចដាក់ទម្ងន់ទោសដែលបានប្រកាសឡើងដោយតុលាការជាន់ដំបូង ទៅលើជនជាប់ចោទ[48] ។ ដោយឡែក ប្រសិនបើសាលាឧទ្ធរណ៍ទទួលបានតែបណ្តឹងរបស់ជនជាប់ចោទ សាលាឧទ្ធរណ៍មិនអាចចេញសេចក្តីសម្រេចបន្ថែមទម្ងន់ទោសនោះទេ សាលាឧទ្ធរណ៍អាចត្រឹមតែយល់ស្រប និងកែប្រែសេចក្តីសម្រេចរបស់តុលាការជាន់ដំបូង ក្នុងន័យអនុគ្រោះដល់ជនជាប់ចោទតែប៉ុណ្ណោះ[49] ។ សាលាឧទ្ធរណ៍អាចសម្រេចចេញដីកាបង្គាប់ឲ្យឃុំខ្លួន ឬដីកាបង្គាប់ឲ្យចាប់ខ្លួនស្របតាមនីតិវិធីដែលចែងក្នុងមាត្រា ៣០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ដោយឡែក បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចធ្វើបានតែលើផលប្រយោជន៍ផ្នែករដ្ឋប្បវេណីតែប៉ុណ្ណោះ[50] ។ សាលាឧទ្ធរណ៍អាចសម្រេចមិនទទួលយកបណ្តឹងឧទ្ធរណ៍ក្នុងករណីយល់ឃើញថាបណ្តឹងនេះធ្វើឡើងហួសពេលកំណត់ ឬធ្វើនៅក្នុងលក្ខខណ្ឌមិនត្រឹមត្រូវ[51] ។ ក្នុងករណីផ្សេងទៀត សាលាឧទ្ធរណ៍អាចបដិសេធសាលក្រម ហើយអាចសម្រេចឲ្យជនជាប់ចោទរួចខ្លួនបាន កាលណារកឃើញថា ជនជាប់ចោទគ្មានពិរុទ្ធភាព ឬអំពើនេះមិនមែនជាបទល្មើសទេ[52] ។

**កថាខណ្ឌទី ៣. បណ្តឹងសាទុក្ខ**

បណ្តឹងសាទុក្ខ ជាប្រភេទបណ្តឹងតវ៉ាមួយដែលប្តឹងទៅកាន់សភាព្រហ្មទណ្ឌនៃតុលាការកំពូល ប្រឆាំងនឹងសាលដីកាសភាស៊ើបសួរ រឿងបត្យាប័ន ព្រមទាំងសាលដីកាសម្រេចជាសមត្ថកិច្ចចុងក្រោយដោយសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ។ ប៉ុន្តែវិធីតវ៉ានេះ មិនអាចធ្វើបានទេ ចំពោះសាលដីកានៃសភាស៊ើបសួរ ដែលបង្គាប់ឲ្យបញ្ជូនជនជាប់ចោទទៅតុលាការជំនុំជម្រះ[53] ។

[47] មាត្រា៣៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[48] មាត្រា៤០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[49] មាត្រា៣៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[50] មាត្រា៤០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[51] មាត្រា៤០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[52] មាត្រា៤០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[53] មាត្រា៤១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

យោងតាមមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បណ្តឹងសាទុក្ខអាចធ្វើបានដោយមូលហេតុដូចខាងក្រោម ៖

- សមាសភាពមិនស្របច្បាប់នៃតុលាការ
- អសមត្ថភាពនៃតុលាការ
- ការរំលោភអំណាច
- ការបំពានច្បាប់ ឬការអនុវត្តខុសច្បាប់
- ការបំពាន ឬភ្លេចទម្រង់ការ ដែលច្បាប់បញ្ញត្តិថាត្រូវទុកជាមោឃៈ
- ការមិនបានសម្រេចលើពាក្យប្តឹងសុំរបស់អយ្យការ ឬភាគី កាលណាពាក្យប្តឹងសុំនេះធ្វើជាលាយលក្ខណ៍អក្សរ និងមានន័យយ៉ាងច្បាស់លាស់
- ការបំភ្លៃអង្គហេតុ
- គ្មានសំអាងហេតុ
- ការផ្ទុយគ្នារវាងសំអាងហេតុ និងសេចក្តីសម្រេច ។

ចំពោះបុគ្គលដែលធ្វើបណ្តឹងសាទុក្ខនោះបាន មានដូចជា អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ជនជាប់ចោទ ឬពិរុទ្ធជន បុគ្គលដែលត្រូវទាមទារក្នុងករណីនៃនីតិវិធីបត្យាប័ន ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី[54] ។ បុគ្គលដែលមានបំណងធ្វើបណ្តឹងសាទុក្ខ ត្រូវគោរពទៅតាមរយៈពេលដែលច្បាប់កំណត់ដូចតទៅ ៖

- ១ ខែ ចំពោះសាលដីការបស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍
- ១៥ ថ្ងៃ ចំពោះសាលដីការបស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍
- ៥ ថ្ងៃ ចំពោះមតិសភាស៊ើបសួរដែលបញ្ចេញក្នុងរឿងបត្យាប័ន ។

ចិរវេលានេះ ត្រូវគិតចាប់ពីថ្ងៃប្រកាសសាលដីកាចំពោះមុខ ការឲ្យដំណឹងពីសាលដីកាចាត់ទុកជាចំពោះមុខ និងបន្ទាប់ពីផុតរយៈពេលប្តឹងទាស់ចំពោះសាលដីកាកំបាំងមុខ[55] ។ បណ្តឹងសាទុក្ខត្រូវប្រកាសក្រោមទម្រង់ដែលមានកំណត់ក្នុងមាត្រា ៤២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ហើយបណ្តឹងនេះត្រូវចុះហត្ថលេខា ដោយភាគីពាក់ព័ន្ធដែលមានបញ្ជាក់ក្នុងមាត្រា ៤២៣ នៃក្រមនេះផងដែរ ។

[54] មាត្រា៤១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[55] មាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

នៅពេលសំណុំរឿងបានបញ្ជូនទៅតុលាការកំពូល ដោយក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ភាគីអាចចាត់តាំងមេធាវីយ៉ាងយូរបំផុតរហូតដល់មុនថ្ងៃបើកសវនាការ ១(មួយ) ថ្ងៃ[56] ។

នៅពេលដែលទទួលបានដំណឹងពីក្រឡាបញ្ជីពីការចុះបញ្ជីនៃបណ្តឹងសាទុក្ខ អ្នកប្តឹងមានថេរវេលា ១០ថ្ងៃ ដើម្បីប្រគល់សារណា ដែលបង្ហាញពីមធ្យាបាយគាំទ្រការតវ៉ា ។ ដូចនេះ ភាគីដទៃទៀតមានថិរវេលា ២០ថ្ងៃ ដើម្បីឆ្លើយតបទៅនឹងសារណារបស់អ្នកប្តឹងសាទុក្ខ ។ ផុតថេរវេលានេះ ចៅក្រមរាយការណ៍ ដែលចាត់តាំងដោយប្រធានតុលាការប្រគល់របាយការណ៍របស់ខ្លួនដែលលមាននីតិវិធី និងរឿងហេតុ ចំណុចច្បាប់ដែលគូភាគីបានលើក និងដោះស្រាយដែលចៅក្រមរាយការណ៍ស្នើសុំ ។ របាយការណ៍ទាំងអស់ត្រូវបញ្ជូនទៅអគ្គព្រះរាជអាជ្ញាតុលាការកំពូល ដើម្បីធ្វើសេចក្តីសន្និដ្ឋាន ។ នីតិវិធីធ្វើរបាយការណ៍ ការជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការ និងនីតិវិធីពិភាក្សាដេញដោលរបស់តុលាការកំពូលមានបញ្ញត្តិចាប់ពីមាត្រា ៤២៩ រហូតដល់មាត្រា ៤៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

ក្នុងអំឡុងពេលនៃការធ្វើបណ្តឹងសាទុក្ខ មានអានុភាពបង្អង់ការអនុវត្តសាលដីកាសិន ។ បណ្តឹងសាទុក្ខមានអានុភាពព្យួរ ការអនុវត្តសេចក្តីសម្រេចដែលត្រូវតវ៉ានេះ ត្រូវតែបង្អង់ ក្នុងខណៈដែលតុលាការកំពូលមិនទាន់បានសម្រេច លើកលែងតែទាក់ទងទៅនឹងការឃុំខ្លួន ។ ប៉ុន្តែផ្ទុយពីបណ្តឹងឧទ្ធរណ៍ ជនជាប់ចោទដែលរួចខ្លួនត្រូវដោះលែងឲ្យមានសេរីភាព[57] ។

បណ្តឹងសាទុក្ខអាចត្រូវបានបដិសេធ នោះសេចក្តីសម្រេចដែលត្រូវបានគេតវ៉ាទទួលបានអាជ្ញាអស់ជំនុំ ។ បើតុលាការកំពូលបដិសេធសេចក្តីសម្រេច តុលាការកំពូលបញ្ជូនរឿង និងគូភាគីទៅមុខសាលាឧទ្ធរណ៍មួយផ្សេងទៀត ពីសាលាឧទ្ធរណ៍ដែលបានចេញសេចក្តីសម្រេចដែលត្រូវគេតវ៉ានោះ ឬនៅមុខសាលាឧទ្ធរណ៍ដដែល ប៉ុន្តែសមាសភាពចៅក្រមជំនុំជម្រះថ្មី[58] ។

កាលណាអំពើដែលចោទប្រកាន់មិនមែនជាបទល្មើស តុលាការកំពូលប្រកាសបដិសេធសាលដីកាសាលឧទ្ធរណ៍ដោយគ្មានបញ្ជូនសំណុំរឿងទៅវិញ[59] ។

កាលណាតុលាការកំពូលយល់ឃើញថា អំពើដែលចោទប្រកាន់នោះជាបទល្មើសផ្សេង អំពីបទល្មើសនៅក្នុងសេចក្តីសម្រេចដែលគេតវ៉ា នោះត្រូវព្យួរទោសដូចគ្នា ដោយតុលាការកំពូលមិនចាំបាច់ប្រកាសបដិសេធ ហើយអាចកែប្រែឈ្មោះអំពើដែលចោទប្រកាន់នោះជាបទល្មើសថ្មី ដោយ

[56] មាត្រា៤២៥-៤២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[57] មាត្រា៤៣៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[58] មាត្រា៤៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[59] មាត្រា៤៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

រក្សាទុកនូវទោសដែលបានប្រកាស និងសេចក្តីសម្រេចទាក់ទងខាងរដ្ឋប្បវេណី។ តែបើតុលាការកំពូលយល់ឃើញថាអពើដែលចោទប្រកាន់នោះ ជាបទល្មើសផ្សេងពីបទល្មើសនៅក្នុងសេចក្តីសម្រេចដែលគេប្តឹងតវ៉ា និងផ្តន្ទាទោសខុសគ្នា តុលាការកំពូលបដិសេធសាលដីកា និងបង្គាប់ឲ្យបញ្ជូនរឿងទៅសាលាឧទ្ធរណ៍ដែលមានសមត្ថកិច្ច[60] ។ បើតុលាការដែលទទួលសំណុំរឿងបញ្ជូនមកនោះមិនព្រមកែប្រែនូវសាលដីការបស់ខ្លួន និងប្រសិនបើមធ្យោបាយដដែលត្រូវបង្ហាញនៅពេលបណ្តឹងសាទុក្ខលើកទីពីរ តុលាការកំពូលដែកបើកការជំនុះជម្រះ ចេញអង្គសម្រេចទាំងអង្គហេតុ និងអង្គច្បាប់តាមរយៈសាលដីកាស្ថាពរ[61] ។

## ផ្នែកទី ២. បណ្តឹងតវ៉ាវិសាមញ្ញ

### កថាខណ្ឌទី ១. បណ្តឹងសើរើ

បណ្តឹងសើរើ គឺជាផ្លូវតវ៉ាមួយប្រឆាំងនឹងសាលក្រម និងសាលដីកាដែលស្ថាពរ ហើយមានអាជ្ញាអស់ជំនុំ។ មានតែសភាពេញអង្គនៃតុលាការកំពូលតែមួយគត់ ដែលមានសមត្ថកិច្ចដោះស្រាយលើបណ្តឹងសើរើ[62] ។

បណ្តឹងសើរើរឿងក្តីអាចធ្វើបានតែនៅក្នុងករណីដូចតទៅៈ

- កាលណាក្រោយពីផ្តន្ទាទោស ពីបទមនុស្សឃាត មានលេចចេញនូវតម្រុយយ៉ាងគ្រប់គ្រាន់ដែលអនុញ្ញាតឲ្យគិតថាជនរងគ្រោះនោះ នៅរស់រានមានជីវិត។
- កាលណាជនជាប់ចោទពីរនាក់ត្រូវបានផ្តន្ទាទោស ចំពោះបទល្មើសដដែលនេះដោយការផ្តន្ទាទោសទាំងពីរមិនចុះសម្រុងគ្នា។
- កាលណាសាក្សីមួយត្រូវបានផ្តន្ទាទោសពីបទល្មើស ធ្វើសាក្សីក្លែងប្រឆាំងនឹងជនជាប់ចោទ។
- កាលណាមានអង្គហេតុថ្មី ឬលិខិត ឬភស្តុតាងថ្មីដែលនាំឲ្យគេសង្ស័យលើពិរុទ្ធភាពនៃទណ្ឌិត[63] ។

បុគ្គលដែលមានសិទ្ធិអាចប្តឹងសើរើរឿងក្តីមានដូចតទៅៈ

- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។
- ទណ្ឌិត ឬអ្នកតំណាងស្របច្បាប់ ប្រសិនបើទណ្ឌិតនោះជាអសមត្ថជន ។

[60] មាត្រា៤៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[61] មាត្រា៤៤២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[62] មាត្រា៤៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[63] មាត្រា៤៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

- សហព័ទ្ធ ឪពុក ម្ដាយ កូន និងជាទូទៅ ជនណាដែលមានផលប្រយោជន៍ខាងសម្ភារៈ ឬខាងផ្លូវចិត្តក្នុងការលុបបំបាត់ទណ្ឌកម្មនេះ ក្នុងករណីដែលទណ្ឌិតទទួលមរណភាព ឬបាត់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មុននឹងទៅប្ដឹងតុលាការកំពូល អាចសុំដល់អគ្គព្រះរាជអាជ្ញា ដែលមានសមត្ថកិច្ចខាងដែនដីឲ្យធ្វើការស្រាវជ្រាវបន្ថែម[64] ។

ដើមបណ្ដឹងមានរយៈពេល៣០ថ្ងៃ ដើម្បីពាក្យបណ្ដឹងសើរើ ដែលរយៈបេលនេះអាចពន្យាបានដោយប្រធានតុលាការកំពូល ។ អគ្គព្រះរាជអាជ្ញាអាចធ្វើដីកាសន្និដ្ឋាន ជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ៣០ថ្ងៃបន្ទាប់ពីទទួលសំណុំរឿង[65] ។

តុលាការកំពូលបើកការជំនុំជម្រះជាសភាពេញអង្គ និងសម្រេចលើអង្គហេតុ និងអង្គច្បាប់ដោយសាលដីកាស្ថាពរបន្ទាប់ពីទទួលបានសំណុំរឿងពីសភាព្រហ្មទណ្ឌ[66]។ ប្រធានតុលាការកំពូលធ្វើការកំណត់កាលបរិច្ឆេទពីសវនាការ និងជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការ និងសាធារណភាពនៃកិច្ចពិភាក្សាដេញដោល ទៅតាមនីតិវិធីដូចមានកំណត់ក្នុងមាត្រា ៤៥១នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

ចំពោះករណីចាំបាច់ តុលាការកំពូលបង្គាប់ឲ្យធ្វើការស្រាវជ្រាវបន្ថែម ។ ចៅក្រមដែលទទួលបន្ទុកស្រាវជ្រាវមានអំណាចដូចចៅក្រមស៊ើបសួរ លើកលែងតែការឃុំខ្លួនបណ្ដោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការ[67] ។

បណ្ដឹងសើរើមានអានុភាព ឲ្យសភាព្រហ្មទណ្ឌនៃតុលាការកំពូលអាចសម្រេចព្យួរការអនុវត្តទោសបាន ប្រសិនបើមានមូលហេតុច្បាស់លាស់ [68] ។ ក្រៅពីនេះតុលាការកំពូលជំនុំជម្រះជាសភាពេញអង្គ អាចបង្គាប់ឲ្យផ្អាកការអនុវត្តទណ្ឌកម្មបានគ្រប់ពេលវេលា ។ ការសម្រេចរបស់តុលាការកំពូលត្រូវមានសំអាងហេតុ[69] ។ ការអនុគ្រោះទោស និងការលើកលែងទោសមិនមែនជាឧបសគ្គដល់ការប្ដឹងសើរើនោះទេ[70] ។

---

[64] មាត្រា៤៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[65] មាត្រា៤៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[66] មាត្រា៤៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[67] មាត្រា៤៥២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[68] មាត្រា៤៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[69] មាត្រា៤៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[70] មាត្រា៤៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

# សេចក្ដីសន្និដ្ឋាន និង អនុសាសន៍

## ១. សេចក្ដីសន្និដ្ឋាន

ជារួមនៅពេលកើតមាននូវបទល្មើសព្រហ្មទណ្ឌមួយកើតឡើង គឺតែងតែនាំឲ្យមានបណ្ដឹងកើតមានទៅកាន់តុលាការដែលមានសមត្ថកិច្ចដោះស្រាយ ក្នុងគោលដៅស្វែងរកជនល្មើសមកផ្ដន្ទាទោសតាមច្បាប់ និងស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ ។ ផ្អែកតាមគោលការណ៍ច្បាប់ នៅក្នុងរឿងក្ដីព្រហ្មទណ្ឌមួយ គឺមានលេចឡើងនូវបណ្ដឹងពីរ គឺបណ្ដឹងអាជ្ញា (បណ្ដឹងព្រហ្មទណ្ឌ) និងបណ្ដឹងរដ្ឋប្បវេណី ដែលបណ្ដឹងទាំងពីរនេះកើតឡើងក្នុងគោលបំណងផ្សេងគ្នា និងអនុវត្តនូវនីតិវិធីដោះស្រាយខុសពីគ្នាផងដែរ ។ ក្រោយពីដំណើរការនីតិវិធីដោះស្រាយរួចរាល់ តុលាការចេញនូវសេចក្ដីសម្រេច ប៉ុន្តែច្បាប់បានផ្ដល់សិទ្ធិឲ្យបុគ្គលដែលពាក់ព័ន្ធ និងបុគ្គលដែលមានផលប្រយោជន៍ក្នុងដំណើរការដោះស្រាយបណ្ដឹងអាចប្ដឹងតវ៉ាចំពោះសេចក្ដីសម្រេចនោះបាន ដោយត្រូវគោរពទៅតាមនីតិវិធីនៃបណ្ដឹងតវ៉ា ។

ចំពោះបណ្ដឹងអាជ្ញាត្រូវបានធ្វើឡើងក្នុងគោលបំណង ស្វែងរកឲ្យឃើញនូវភាពកើតមានយ៉ាងពិតប្រាកដនៃបទល្មើស និងចាប់ខ្លួនជនល្មើស មកផ្ដន្ទាទោសតាមច្បាប់ ។ បណ្ដឹងអាជ្ញាធ្វើឡើងក្នុងគោលដៅរក្សារបៀបរៀបរយក្នុងសង្គម និងផលប្រយោជន៍ជាសាធារណៈ ដូចនេះតួអង្គដែលជាម្ចាស់បណ្ដឹងអាជ្ញា គឺជាស្ថាប័នអយ្យការដែលមានព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ជាអ្នកតំណាងឲ្យសង្គមក្នុងការអនុវត្តច្បាប់ ។ ប៉ុន្តែបណ្ដឹងអាជ្ញាក៏អាចដាក់ឲ្យមានចលនាដោយជនរងគ្រោះ បានតាមរយៈការប្ដឹងដល់ចៅក្រមស៊ើបសួរក្នុងនាមជាដើមបណ្ដឹងរដ្ឋប្បវេណី ។ លើសពីនេះនៅក្នុងការអនុវត្តជាក់ស្ដែងមិនសូវកើតមាននោះទេ។ ដោយឡែកព្រះរាជអាជ្ញាចាប់ផ្ដើមធ្វើបណ្ដឹងអាជ្ញា តាមរយៈ ការសម្រេចការចោទប្រកាន់របស់ខ្លួន បន្ទាប់ពីថ្លឹងថ្លែងលើពាក្យបណ្ដឹង ដែលទទួលបានពីមន្ត្រីនគរបាលយុត្តិធម៌ ឬបណ្ដឹងផ្ទាល់របស់ប្រជាពលរដ្ឋមកកាន់តុលាការ។ ក្នុងករណីផ្សេងទៀតព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការ កាលបើព្រះរាជអាជ្ញាវាយតម្លៃលើសំណុំរឿង ហើយយល់ឃើញថាមិនមានលទ្ធភាពក្នុងការចោទប្រកាន់ ។ បណ្ដឹងអាជ្ញាមិនអាចធ្វើទៅបានទេ កាលណាវាត្រូវបានរលត់ដោយមូលហេតុដែលច្បាប់បានកំណត់ ។ គួរបញ្ជាក់ផងដែរថា ក្នុងករណីដែលព្រះរាជអាជ្ញាសម្រេចធ្វើការចោទប្រកាន់ ព្រះរាជអាជ្ញាត្រូវពិនិត្យទៅលើស្ថានភាពនៃសំណុំរឿង និងធ្វើការជ្រើសរើសនីតិវិធីមួយណាមកអនុវត្ត ដើម្បីរៀបចំជាទម្រង់បណ្ដឹងច្បាស់លាស់ណាមួយ ឈានទៅដល់ការជំនុំជម្រះ ។ ជម្រើសនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា

អាចជាការបញ្ជូនដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ទៅចៅក្រមស៊ើបសួរដើម្បីស្រាវជ្រាវបន្ថែម ទៅលើសំណុំរឿង ឬការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ដោយមិនចាំបាច់ឆ្លងកាត់ការស៊ើបសួរនោះទេ ដោយសារសំណុំរឿងមានលក្ខណៈគ្រប់គ្រាន់ហើយ ប៉ុន្តែការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ មិនអាចធ្វើបានចំពោះបទឧក្រិដ្ឋទេ។ ចំណែកឯជម្រើសមួយទៀត គឺព្រះរាជអាជ្ញាបង្គាប់ជនជាប់ចោទចូលបង្ហាញខ្លួនភ្លាម នៅចំពោះមុខសាលាដំបូង ស្របតាមនីតិវិធីដែលមានចែងក្នុងច្បាប់។

ដោយឡែកចំពោះបណ្តឹងរដ្ឋប្បវេណី គឺជាបណ្តឹងមួយដែលមានជនរងគ្រោះជាភាគីនៃដើមបណ្តឹង ដែលប្តឹងទាមទារសំណងចំពោះការខូចខាតដែលខ្លួនបានទទួលពីបទល្មើសព្រហ្មទណ្ឌ ។ ច្បាប់បានកំណត់ឲ្យជនរងគ្រោះមានសិទ្ធិទាមទារសំណងពីអំពើដែលល្មើសច្បាប់ ប៉ុន្តែសំណងត្រូវតែមានលក្ខណៈសមល្មមទៅនឹងព្យសនកម្មដែលជនរងគ្រោះបានទទួល ដែលរួមមានព្យសនកម្មលើផ្លូវកាយ ផ្លូវចិត្ត និងសម្ភារៈ ។ ក្រៅពីជនរងគ្រោះផ្ទាល់ដែលដើរតួជាដើមបណ្តឹងរដ្ឋប្បវេណី ក៏នៅមានបុគ្គលផ្សេងទៀតដែលអាចធ្វើជាដើមបណ្តឹងជំនួសជនរងគ្រោះបាន ដូចជាអ្នកតំណាងស្របច្បាប់ សិទ្ធិវន្ត ឬអង្គភាពផ្សេងទៀតដែលច្បាប់បានកំណត់ ។ ចំពោះនីតិវិធីនៃការធ្វើបណ្តឹងរដ្ឋប្បវេណី នៅក្នុងរឿងក្តីព្រហ្មទណ្ឌ ជាទូទៅគឺអាចធ្វើឡើងក្នុងពេលដំណាលគ្នាជាមួយបណ្តឹងព្រហ្មទណ្ឌ ។ នីតិវិធីនេះត្រូវបានតុលាការគ្រប់ខេត្ត-ក្រុង តែងតែយកមកអនុវត្តដោយសារមិនមានលក្ខណៈស្មុគស្មាញ និងមានប្រសិទ្ធិភាពផងដែរ ។ ករណីផ្សេងទៀតបណ្តឹងរដ្ឋប្បវេណី ក៏អាចធ្វើបានដោយឡែកពីបណ្តឹងព្រហ្មទណ្ឌផងដែរ ដោយក្នុងករណីនេះតម្រូវឲ្យភាគីដែលពាក់ព័ន្ធ និងតុលាការត្រូវរង់ចាំដល់ចេញសាលក្រមស្ថាពរចំពោះបណ្តឹងអាជ្ញាជាមុនសិន ។ បណ្តឹងរដ្ឋប្បវេណីមិនអាចធ្វើបាននោះទេ កាលណាវាផុតរលត់ដោយមូលហេតុ ដែលច្បាប់បានបញ្ញត្តិ ។

ផ្អែកតាមគោលការណ៍ដែលក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ពាក់ព័ន្ធផ្សេងទៀត បានបញ្ញត្តិពីនីតិវិធីនៃការធ្វើបណ្តឹងតវ៉ា ក្នុងករណីដែលមិនសុខចិត្តទៅនឹងសេចក្តីសម្រេច របស់តុលាការដំបូង។ បណ្តឹងតវ៉ាមានច្រើនប្រភេទទៅតាមលំដាប់ថ្នាក់តុលាការនីមួយៗ ដែលមានសមត្ថកិច្ចដោះស្រាយបណ្តឹងតវ៉ា ដែលក្នុងនោះរួមមាន បណ្តឹងទាស់ដែលធ្វើឡើងប្រឆាំងទៅនឹងសាលក្រមកំបាំងមុខ ឬសាលដីការកំបាំងមុខ ទៅកាន់តុលាការសាមី ។ បណ្តឹងឧទ្ធរណ៍ធ្វើឡើងប្រឆាំង នឹងសាលក្រមរបស់សាលាដំបូង ទៅកាន់សាលាឧទ្ធរណ៍ ។ ប្រភេទនៃបណ្តឹងតវ៉ាមួយទៀត គឺបណ្តឹងសាទុក្ខដែលធ្វើឡើងប្រឆាំងនឹងសាលដីកាសាលឧទ្ធរណ៍ ទៅកាន់តុលាការជាន់ខ្ពស់ គឺតុលាការកំពូល ។ ចុងក្រោយគឺបណ្តឹងសើរើ គឺជាប្រភេទបណ្តឹងវិសាមញ្ញមួយ ដែលធ្វើឡើងនៅពេលដែលសាលក្រម ឬសាលដីកាចូលជាស្ថាពរ និងមានអាជ្ញាអស់ជំនុំ ដោយមានតែតុលាការកំពូលតែមួយគត់ដែលមានសមត្ថកិច្ចដោះស្រាយបណ្តឹងសើរើរឿងក្តីមួយនេះបាន ។

ដូចនេះផ្អែកតាមខ្លឹមសារដែលបានលើកឡើងនៅក្នុងប្រធានបទនេះ បានបង្ហាញឲ្យយើងឃើញថាច្បាប់ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់យ៉ាងច្បាស់ពីប្រភេទនៃបណ្តឹងដែលធ្វើឡើង នៅពេលដែលមានបទល្មើសព្រហ្មទណ្ឌមួយកើតឡើង ដោយបានលម្អិតបន្ថែមនូវនីតិវិធីដែលតុលាការត្រូវអនុវត្តដើម្បីឲ្យដំណើរការដោះស្រាយប្រព្រឹត្តទៅ ដោយភាពត្រឹមត្រូវ យុត្តិធម៌ និងប្រកបដោយប្រសិទ្ធិភាពផងដែរ ។

## ២. អនុសាសន៍

បើយើងក្រឡេកមើលទៅក្នុងសង្គមជាក់ស្តែង នាពេលបច្ចុប្បន្ននេះ ការអនុវត្តស្របតាមនីតិវិធីដែលបានកំណត់ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ និងលិខិតបទដ្ឋានគតិយុត្តិនានាដែលពាក់ព័ន្ធទៅនឹងប្រព័ន្ធតុលាការ គឺនៅមានភាពខ្វះចន្លោះខ្លះៗនៅឡើយ ។ ជាក់ស្តែងនៅពេលដែលកសាងសំណុំរឿង មន្ត្រីនគរបាលខ្លះមិនបាន ស៊ើបអង្កេតឲ្យបានដិតដល់ ដែលធ្វើឲ្យសំណុំរឿងមានមិនគ្រប់គ្រាន់ ឬអាចខុសពីការពិតទាំងស្រុងនៅពេលដែលបញ្ជូនទៅព្រះរាជអាជ្ញា ។ វាជាមូលហេតុដែលធ្វើឲ្យការសម្រេចការចោទប្រកាន់របស់ព្រះរាជអាជ្ញា ធ្វើឡើងដោយភាពមិនត្រឹមត្រូវ ឬប្រាសចាកពីគោលការណ៍ដែលច្បាប់បានកំណត់ ។ ម្យ៉ាងទៀតក្នុងនាមជាម្ចាស់បណ្តឹងអាជ្ញាដែលការពារផលប្រយោជន៍ទូទៅដល់សង្គម ព្រះរាជអាជ្ញាត្រូវតែគោរពជាដាច់ខាត តាមបទបញ្ញត្តិទាំងឡាយដែលកំណត់អំពីការធ្វើចំណាត់ការទៅលើសំណុំរឿង ដើម្បីរៀបចំជាបណ្តឹងនិងមានភាពត្រឹមត្រូវផងដែរ ប៉ុន្តែព្រះរាជអាជ្ញាខ្លះនូវតែមានភាពមិនច្បាស់លាស់ ចំពោះការអនុវត្តនីតិវិធីដោយពិចារណាមិនបានគ្រប់ជ្រុងជ្រោយ ឬប្រព្រឹត្តខុសក្រមសីលធម៌វិជ្ជាជីវៈដែលធ្វើឲ្យខ្លួនចោទប្រកាន់ខុសពីការពិត ឬអនុវត្តខុសពីនីតិវិធីដែលបានកំណត់ ។ ម្យ៉ាងវិញទៀតយើងសង្កេតឃើញថាប្រជាពលរដ្ឋមួយចំនួន ដែលជាបុគ្គលពាក់ព័ន្ធនឹងដំណើរការនៃបណ្តឹង មិនបានយល់ដឹងពីច្បាប់ និងនីតិវិធី ជាហេតុបណ្តាលឲ្យពួកគាត់ប្រព្រឹត្តទង្វើផ្សេងៗ ដែលនាំឲ្យរំខានដល់ដំណើរការដោះស្រាយ និងធ្វើឲ្យនីតិវិធីមានភាពយឺតយ៉ាវ ។

ហេតុដូច្នេះហើយដើម្បីឲ្យការអនុវត្តច្បាប់នៅក្នុងប្រព័ន្ធយុត្តាធិការនៃប្រទេសកម្ពុជា ប្រព្រឹត្តទៅបានរលូន និងប្រកបដោយភាពយុត្តិធម៌ រាជរដ្ឋាភិបាល និងថ្នាក់ដឹកនាំនៅក្នុងស្ថាប័នតុលាការទាំងអស់ គប្បីចាត់វិធានការយ៉ាងម៉ឺងម៉ាត់ទៅលើមន្ត្រីអសកម្មទាំងឡាយ ឲ្យខិតខំពង្រឹងខ្លួនឯងគោរពទៅតាមគោលការណ៍ និងបទបញ្ញត្តិទាំងឡាយ ព្រមទាំងប្រកាន់យកភាពត្រឹមត្រូវ និងយុត្តិធម៌ដើម្បីបម្រើផលប្រយោជន៍ ជូនប្រជាពលរដ្ឋ និងសង្គមជាតិទាំងមូល ។ លើសពីនេះទៅទៀតរដ្ឋាភិបាលជានិច្ចកាលគប្បី បង្កើតឲ្យមាននូវការចុះផ្សព្វផ្សាយ បណ្តុះបណ្តាល អប់រំប្រជាពលរដ្ឋតាមរយៈសិក្ខាសាលានានានៅតាមស្ថាប័នផ្សេងៗ អំពីច្បាប់ និងនីតិវិធីនៅក្នុងប្រព័ន្ធ

តុលាការនេះ ដើម្បីឲ្យពួកគាត់បានយល់ដឹង និងជួយសម្រួលដល់ដំណើរការដោះស្រាយឲ្យមានប្រសិទ្ធិភាពកាន់តែខ្ពស់បន្ថែមទៀត ។

# គន្លិនខ្មេល

# គន្ថនិទ្ទេស

## I. ច្បាប់

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣

២. ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រ កម្ពុជា ឆ្នាំ២០០៩

៣. ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រ កម្ពុជា ឆ្នាំ២០០៧

## II. សៀវភៅមេរៀន

១. សៀវភៅមេរៀន នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្ត្រ **ហ៊ី សោភា** ។

២. សៀវភៅមេរៀន នីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយ**រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ** ឆ្នាំ២០០៧ ។

៣. សៀវភៅមេរៀន នីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយ លោកស្រី **ឌី លីឡា** និង លោក **ខាន់ សុខា** ។

៤. សៀវភៅមេរៀន ស្តីពីនីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្ត្រាចារ្យ **វុណ ពណ្ណារិទ្ធ** និង លោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ឆ្នាំ២០១២។

៥. សៀវភៅមេរៀន ស្តីពីនីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយ លោក **អៀង សំណាង** អនុបណ្ឌិតជំនាញ នីតិឯកជន បោះពុម្ពលើកទី១ ឆ្នាំ២០១៥ ។

## III. ការចុះស្រាវជ្រាវឯកសារ

បានចុះស្រាវជ្រាវនៅ អយ្យការនៃសាលាដំបូងរាជធានីភ្នំពេញ ដោយបានទទួលការណែនាំ ដោយលោកព្រះរាជអាជ្ញារង អមសាលាដំបូងរាជធានីភ្នំពេញ។

## IV. ឯកសារផ្សេងៗ

១. វចនានុក្រម សម្តេចព្រះ**សង្ឃរាជ ជួន ណាត** ។

២. សន្ទានុក្រមពាក្យច្បាប់ ដកស្រង់ពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិជាធរមាន ពី ឆ្នាំ ១៩៩៤ ដល់ឆ្នាំ ២០១២ ។

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១.**

- ពាក្យបណ្តឹង តាមរយៈអង្គភាពនគរបាលយុត្តិធម៌ ប្តឹងទៅកាន់តុលាការ ។

**ឧបសម្ព័ន្ធទី២.**

- ពាក្យបណ្តឹងដោយផ្ទាល់ ប្តឹងទៅកាន់តុលាការ ។

**ឧបសម្ព័ន្ធទី៣.**

- ទម្រង់នៃដីកាតម្កល់រឿងទុកឥតចាត់ការ ។

**ឧបសម្ព័ន្ធទី៤ និង ទី៥.**

- ឧបសម្ព័ន្ធទី៤ ៖ ទម្រង់ទូទៅ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ។
- ឧបសម្ព័ន្ធទី៥ ៖ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ជាក់ស្តែងដែលចេញដោយព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ ។

**ឧបសម្ព័ន្ធទី៦ និងទី៧.**

- ឧបសម្ព័ន្ធទី៦ ៖ ទម្រង់ទូទៅ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ។
- ឧបសម្ព័ន្ធទី៧ ៖ ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ជាក់ស្តែងដែលចេញដោយព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ ។

**ឧបសម្ព័ន្ធទី៨ និងទី៩.**

- ឧបសម្ព័ន្ធទី៨ ៖ ទម្រង់ទូទៅ នៃកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ។
- ឧបសម្ព័ន្ធទី៩ ៖ កំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ជាក់ស្តែងដែលចេញដោយ ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ ។

**ឧបសម្ព័ន្ធទី១០.**

- ទម្រង់ពាក្យបណ្តឹងឧទ្ធរណ៍ ។

**ឧបសម្ព័ន្ធទី១១.**

- ទម្រង់ពាក្យបណ្តឹងសាទុក្ខ ។

**ឧបសម្ព័ន្ធទី១២.**

- សារណាដើមបណ្តឹងសាទុក្ខ ។

**ឧបសម្ព័ន្ធទី១**.

## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## <u>ពាក្យបណ្តឹង</u>

ក្រុមហ៊ុន BEAUTIFUL WINDOW ENTERPRISE (CAMBODIA) Co., Ltd. ជាសហគ្រាសឯកបុគ្គល ទទួលខុសត្រូវមានកម្រិត ដែលបានចុះបញ្ជី នៅក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា មានលេខរៀងចុះបញ្ជី Inv. ០១០៥ E/២០១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៣ មានទីស្នាក់ការចុះបញ្ជីនៅ ភូមិ ព្រៃធំ សង្កាត់ ព្រៃអង្គុញ ក្រុង បាវិត ខេត្ត ស្វាយរៀង តំណាងដោយលោក LIN, YU-CHIN កាន់លិខិតឆ្លងដែនលេខ 303377070 ចុះថ្ងៃទី 07 ខែកក្កដា ឆ្នាំ ២០១១ ។

## សូមគោរពជូន

## ឯកឧត្តមស្នងការនៃស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង

**កម្មវត្ថុ៖** សុំប្តឹងពីឈ្មោះ៖

១. .... .. ភេទ ..ប្រុស. អាយុ ..២២.. ឆ្នាំ ជាតិ....ខ្មែរ...មុខរបរ....កម្មករ... មានទីលំនៅ..ភូមិក្បាលថ្នល់ ឃុំកណ្តៀងរាយ ស្រុកស្វាយទាប ខេត្តស្វាយរៀង។

២. .. .. ភេទ ..ស្រី.. អាយុ ..២៧.. ឆ្នាំ ជាតិ.ខ្មែរ..មុខរបរ..កម្មករ..មានទីលំនៅ...ភូមិសាលារៀន ឃុំបាសាក់ ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង។

៣. .. .. ភេទ .ប្រុស.. អាយុ ..២៤.. ឆ្នាំ ជាតិ...ខ្មែរ..មុខរបរ..កម្មករ.មានទីលំនៅ..ភូមិស្វាយតាយាន ឃុំស្វាយតាយាន ស្រុកកំពងរោទ៍ ខេត្តស្វារៀង។

៤. ... . ភេទ .ប្រុស. អាយុ ..២៥.. ឆ្នាំ ជាតិ.ខ្មែរ..បុខរបរ..កម្មករ.មានទីលំនៅ.ភូមិបន្ទាយ ឃុំ កណ្តៀងរាយ ស្រុកស្វាយទាប ខេត្តស្វាយរៀង។

៥. .         ភេទ ..ប្រុស.. អាយុ ..២៤.. ឆ្នាំ ជាតិ..ខ្មែរ.មុខរបរ.កម្មករ.មានទីលំនៅភូមិតា
ប៉ោ ឃុំសំឡី ស្រុកកំពងរោទ៍ ខេត្តស្វាយរៀង។

៦. .         . ភេទ .ប្រុស. អាយុ ..២២. ឆ្នាំ ជាតិ..ខ្មែរ.មុខរបរ.កម្មករ.មានទីលំនៅភូមិគ្រោក ឃុំ
ខ្សែត្រ ស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង។

៧..       . ភេទ .ប្រុស. អាយុ .២៧. ឆ្នាំ ជាតិ.ខ្មែរ..មុខរបរ..កម្មករ.មានទីលំនៅភូមិលៀប ឃុំក
ណ្តៀងរាយ ស្រុក ស្វាយទាប ខេត្តស្វាយរៀង។

៨. .នែម ស៊ីនួន. ភេទ .ប្រុស. អាយុ .២០. ឆ្នាំ ជាតិ.ខ្មែរ.មុខរបរ..កម្មករ..មានទីលំនៅភូមិថ្នល់
កែង ឃុំពពែក ស្រុកស្វាយទាប ខេត្តស្វាយរៀង។

៩. ..         .. ភេទ ..ប្រុស.. អាយុ ..៣២.. ឆ្នាំ ជាតិ..ខ្មែរ..មុខរបរ..កម្មករ..មានទីលំនៅ
ភូមិសំឡីខាងត្បូង ឃុំសំឡី ស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង។

១០. .         .. ភេទ ..ស្រី.. អាយុ ..១៩.. ឆ្នាំ ជាតិ..ខ្មែរ..មុខរបរ..កម្មករ..មានទីលំនៅភូមិព្រៃ
ឆ្កៀត ឃុំសំឡី ស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង។

១១. .         .. ភេទ .ស្រី.. អាយុ ..២៨.. ឆ្នាំ ជាតិ..ខ្មែរ..មុខរបរ..កម្មករ.មានទីលំនៅភូមិតែង
ម៉ៅ ឃុំចន្ទ្រា ស្រុកចន្ទ្រា ខេត្តស្វាយរៀង។

១២. ...         .. ភេទ .ស្រី.. អាយុ ..២៨.. ឆ្នាំ ជាតិខ្មែរ មុខរបរ កម្មករមានទីលំនៅភូមិជប់
ឃុំកណ្តៀងរាយ ស្រុកស្វាយទាប ខេត្តស្វាយរៀង។

១៣. ..សាំ ពិសិត.. ភេទ .ស្រី.. អាយុ ២២ ឆ្នាំ ជាតិ ខ្មែរ មុខរបរ កម្មករមានទីលំនៅភូមិជប់ ឃុំ
កណ្តៀងរាយ ស្រុកស្វាយទាប ខេត្តស្វាយរៀង។

១៤.         ភេទ ស្រី អាយុ ២០ ឆ្នាំ ជាតិ ខ្មែរ មុខរបរ កម្មករមានទីលំនៅភូមិអង្គស្វាយ
ឃុំប្រសូតិ ស្រុកស្វាយទាប ខេត្តស្វាយរៀង។

១៥.         ភេទ ស្រី អាយុ ២៥ ឆ្នាំ ជាតិ ខ្មែរ មុខរបរ កម្មករមានទីលំនៅភូមិព្រៃគ្រុំ
ឃុំញរ ស្រុក កំពង់រោទ៍ ខេត្តស្វារៀង។

១៦. ភេទ ស្រី អាយុ ២៣ ឆ្នាំ ជាតិ ខ្មែរ មុខរបរ កម្មករមានទីលំនៅភូមិ សាមគ្គី សង្កាត់ច្រកម្ទេស ក្រុងបាវិត ខេត្តស្វាយរៀង។

១៧. ភេទ ប្រុស អាយុ ២២ ឆ្នាំ ជាតិ ខ្មែរ មុខរបរ កម្មករមានទីលំនៅភូមិរោទ៍ ឃុំញរ ស្រុក កំពង់រោទ៍ ខេត្តស្វាយរៀង។

១៨. ភេទ ស្រី អាយុ ២៦ ឆ្នាំ ជាតិ ខ្មែរ មុខរបរ កម្មករមានទីលំនៅភូមិត្រពាំងត្រាច ឃុំស្វាយតាយាន ស្រុក កំពង់រោទ៍ ខេត្តស្វាយរៀង។

១៩. ភេទ ប្រុស អាយុ ៣០ ឆ្នាំ ជាតិ ខ្មែរ មុខរបរ កម្មករមានទីលំនៅភូមិបាក់រនាស់ សង្កាត់សង្ឃ័រ ក្រុងស្វាយរៀង ខេត្តស្វាយរៀង។

រួមជាមួយនិងគូកនមួយចំនួនទៀតដែលបានចូលរួមគ្នាប្រព្រឹត្តអំពើរធ្វើអោយខូចខាតដោយចេតនាទ្រព្យសម្បត្តិរបស់រោចក្របីយូធីហ្វិលវីនដូអេនធើប្រាយ(ខេមបូឌា) ប្រព្រឹត្តកាលពីថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០១៥ វេលាម៉ោង៧និង៣០នាទីព្រឹក នៅចំណុចរោងចក្របីយូធីហ្វិលវីនដូអេនធើប្រាយ(ខេមបូឌា) តំបន់សេដ្ឋកិច្ចពិសេសសាន់តុង ស្ថិក្នុងភូមិជ្រៃធំ សង្កាត់ព្រៃអង្គុញ ក្រុងបាវិត ខេត្តស្វាយរៀង។

តបតាមកម្មវត្ថុខាងលើខ្ញុំបាទសូមជម្រាបជូនឯកឧត្តមស្នងការមេត្តាជូនជ្រាបថា:

កាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ២០១៥ កម្មករ កម្មការនី រោងចក្របីយូធីហ្វិលវីនដូអេនធើប្រាយ(ខេមបូឌា)ប្រមាណ១០០នាក់ បាននាំគ្នាធ្វើកូដកម្មមិនចូលធ្វើការងារដោយទាមទារនូវលក្ខ័ណការងារមួយចំនួនជាមួយភាគីក្រុមហ៊ុន នៅពេលកាដោះស្រាយមិនទាន់ឈានដល់កាព្រមព្រៀងគ្នានិងកំពុងបន្តដោះស្រាយនោះ ស្រាប់តែនៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ វេលាម៉ោង៧និង៣០នាទីព្រឹក ក្រុមកម្មករ កម្មការនីដែលមានឈ្មោះដូចខាងលើ(ជាមេក្លោង)រួមជាមួយនិងគូកនមួយចំនួនទៀត បានរួមគ្នាធ្វើសកម្មភាពពីការធ្វើកូដកម្មរដោយអហិង្សាទៅជាការប្រើហិង្សាដោយបាននាំគ្នាយកដុំថ្មនិងដំបងវាយគប់បំផ្លាញអាគាររោងចក្របណ្តាលអោយបែកបាក់ខូចខាតបង្អួចទូកញ្ចក់ចំនួន៥អាគារស្មើរ៦០ផ្ទាំង អាគារ

ប៉ុស្ត៍សន្តិសុខនិងកាមេរ៉ាសុវត្ថិភាពចំនួន២ផងដែរ សរុបការខូចខាតគិតជាទឹកប្រាក់ចំនួនប្រមាណ៥៥២២០ដុល្លា(ប្រាំម៉ឺនប្រាំពាន់ពីររយម្ភៃដុល្លា)។

ចំពោះទង្វើនិងសកម្មភាពរបស់ជនជាមេក្លោងនិងក្រុមកម្មករដែលបានធ្វើកូដកម្មនិងវាយបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ក្រុមហ៊ុននេះ បានធ្វើអោយមានការខាតបង់និងប៉ះពាល់ដល់ផលប្រយោជន៍របស់ក្រុមហ៊ុនយ៉ាងធ្ងន់ធ្ងរ។

## <u>សំណូមពរនៃពាក្យបណ្តឹង</u>

-ប្តឹងសូមផ្តន្ទាទោសជនបង្ករអោយមានបទល្មើសតាមច្បាប់។

-ផ្តឹងសុំសំណងជួសជុលការខូចខាតជាទឹកប្រាក់ចំនួន៥៥២២០ដុល្លា។

អាស្រ័យហេតុនេះសូមឯកឧត្តមស្នងការមេត្តាជួយចាត់វិធានការតាមផ្លូវច្បាប់ដោយក្តីអនុគ្រោះ។

សូមឯកឧត្តមមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ធ្វើនៅថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០១៥

នាយកក្រុមហ៊ុន

LIN YUCHIN(លីន អិជីន)

**ឧបសម្ព័ន្ធទី២.**

ក្រសួងពន្ធដារ
៥០០
រៀល
TIMBRE FISCAL

ក្រសួងពន្ធដារ
១០០០
រៀល
TIMBRE FISCAL

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ពាក្យបណ្តឹង**

នាងខ្ញុំឈ្មោះ អាយុ ៣៨ឆ្នាំ ជាតិខ្មែរ ទីលំនៅភូមិទួលអង្គប់ ឃុំសំបូរ ស្រុកស្វាយ ទាប ខេត្តស្វាយរៀង ។ លេខទូរស័ព្ទ 097. 2829858

សូមគោរពចូលមក
លោកព្រះរាជអាជ្ញាអមសាលាដំបូងខេត្តស្វាយរៀង

អយ្យការខេត្តស្វាយរៀង
មកដល់ថ្ងៃទី 30-08-2013
លេខ 410 ម៉ោង 3 [illegible]

**សូមមានជ្រាប ។**

[illegible]នាងខ្ញុំកើតទុក្ខមិនសុខចិត្តនិងឈ្មោះ អាយុ ៤២ឆ្នាំ ភេទប្រុស ជាតិខ្មែរ មុខរបរបំរើការងារកងរាជអាវុធហត្ថខេត្តស្វាយរៀង ទីលំនៅភូមិកណ្តាល សង្កាត់ចេក ក្រុងស្វាយរៀង ខេត្តស្វាយរៀង ពីបទហឹង្សាដោយចេតនា នឹង លួចមានសាហាយស្មន់ និងឈ្មោះ ភេទស្រី នៅភូមិរោងបន្លែ សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀង ពីបទហឹង្សាដោយចេតនា ។

**ដំណើររឿងមានដូចតទៅ**

កាលពីថ្ងៃទី ២៨-០៨-២០១៣ វេលាម៉ោង ២១ និង ៣០នាទីយប់ ប្តីនាងខ្ញុំបានទៅដឹករូបនាងខ្ញុំ និងកូនស្រីពីផ្ទះពូ ទៅផ្ទះម្តាយក្មេកដើម្បីសំរាកនៅទីនោះយប់ ទៅដល់ប្រហែលកន្លះម៉ោងស្រាប់ តែលឺសំឡេងទូរស័ព្ទប្តីរបស់នាងខ្ញុំរោទិ៍ គាត់បានលើកនិយាយរួចគាត់បានប្រាប់ខ្ញុំថា មេទូរស័ព្ទឱ្យមកកន្លែង ទៅបានមួយស្របក់នាងខ្ញុំក៏បានទៅរកដល់កន្លែងអង្គភាពកងរាជអាវុធហត្ថខេត្តស្វាយរៀង ប៉ុន្តែមិនឃើញ មានគេប្រាប់ថា លោក មិននៅកន្លែងធ្វើការទេ នៅផ្ទះស្រីខាងក្រោយកន្លែងធ្វើការ ពេលនោះនាងខ្ញុំក៏បានសុំអ៊ំស្រីម្ចាស់ផ្ទះជួបឈ្មោះ

គាត់ក៏បានឱ្យខ្ញុំចូលទៅចាំខាងមុខបន្ទប់ គាត់បានគោះទ្វាររួចបើកទ្វារ នាងខ្ញុំក៏បានឃើញប្តីរបស់នាងខ្ញុំអោបគ្នាជាមួយស្រីឈ្មោះ ហើយខ្ញុំក៏ហៅឱ្យចេញមកនិយាយគ្នា ស្រាប់តែស្រីឈ្មោះ នោះលោតមកវាយនាងខ្ញុំពេលឃើញដូច្នេះហើយឈ្មោះ ដែលជាប្តីរបស់ខ្ញុំបានមកវាយខ្ញុំជាច្រើនដៃ ចំក្បាល និង មុខបណ្តាលឱ្យហូរឈាមជោកជាំ ហើយបានបោចសក់ អូសទាញនាងខ្ញុំចេញពីក្នុងផ្ទះវាយរហូតមកដល់ខាងមុខបន្ទាយកងរាជអាវុធហត្ថខេត្តស្វាយរៀង ទើបមានបងប្អូនជិតខាងមកជួយអន្តរាគមន៍ទើបឈ្មោះ ក៏បានទៅបាត់ទៅ។

**សំណូមពរនៃបណ្តឹង**

១-ប្តឹងសុំអោយសមត្ថកិច្ចចាប់ជនល្មើសផ្តន្ទាទោសតាមច្បាប់ ។

២-ប្តឹងសុំទាមទារសំណងជម្ងឺចិត្តជាប្រាក់ចំនួន ១៥.០០០.០០០ រៀល។

អាស្រ័យហេតុនេះ សូមលោកព្រះរាជអាជ្ញាអមសាលាដំបូងខេត្តស្វាយរៀង មេត្តាទទួល និង ដោះស្រាយពាក្យបណ្តឹងរបស់នាងខ្ញុំតាមច្បាប់ដោយក្តីអនុគ្រោះ ។

ស្វាយរៀង.ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៣

**ស្នាមមេដៃស្តាំអ្នកប្តឹង**

# ឧបសម្ព័ន្ធទី៣

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម

សាលាដំបូង ...............

លេខ : ............... អ.យ

## ដីកាតម្កល់រឿងទុកឥតចាត់ការ

យើង ............... តំណាងអយ្យការ អមសាលាដំបូង ...............

-បានឃើញសំណុំរឿងលេខ ............... ចុះថ្ងៃទី ......... ខែ ......... ឆ្នាំ ......... របស់អយ្យការអមសាលាដំបូង ............... និងសំណុំលិខិតភ្ជាប់មកជាមួយព្រមទាំងភស្តុតាងនានា ។

ក្រោយពីបានពិនិត្យឯកសារខាងលើ

យល់ឃើញថា :

១. អវត្តមានបទល្មើស

១.១. ☐ អវត្តមានបទល្មើស

២. ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

២.១. ☐ ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

៣. មូលហេតុគតិយុត្ត

៣.១. ☐ ការដកពាក្យបណ្តឹង

៣.២. ☐ ការលើកលែងទោសជាទូទៅ

៣.៣. ☐ មរណភាពជនល្មើស

៣.៤. ☐ ផុតអាជ្ញាយុកាល

៣.៥. ☐ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ

៣.៦. ☐ អាជ្ញាអស់ជំនុំ

៣.៧. ☐ ការសម្របសម្រួលជាមួយរដ្ឋ

៣.៨. ☐ ការបង់ប្រាក់ពិន័យសរុប ឬ ប្រាក់ពិន័យសម្របសម្រួល

៣.៩. ☐ អភ័យឯកសិទ្ធិ

៣.១០. ☐ អនិយ័តភាពនៃនីតិវិធី

៣.១១. ☐ ការរួចផុតពីការទទួលខុសត្រូវរបស់ជនល្មើស[1]

៤. ការចោទប្រកាន់មិនផ្តល់ផលប្រយោជន៍

៤.១. ☐ ការស្វែងរកមិនបានផល

៤.២. ☐ ការបោះបង់ពាក្យបណ្តឹងរបស់ដើមបណ្តឹង[2]

៤.៣. ☐ ស្ថានភាពវិបល្លាសស្មារតីដែលបន្ថយនូវការដឹងខុសត្រូវ

---

[1] [illegible]

[2] [illegible]

៤.៤. ☐ ការខកខានរបស់ដើមបណ្តឹង

៤.៥. ☐ អាកប្បកិរិយារបស់ជនរងគ្រោះ

៤.៦. ☐ ជនរងគ្រោះមិនចាប់អារម្មណ៍នឹងបទល្មើស

៤.៧. ☐ និយ័តកម្មដោយឯកឯង[៣]

៤.៨. ☐ ព្យសនកម្ម ឬ ការរំខានតិចតួចបង្កដោយបទល្មើស

៥. នីតិវិធីជាជម្រើសអនុវត្តដោយព្រះរាជអាជ្ញា

៥.១. ☐ ការជួសជុលការខូចខាតដោយ / ដល់អនីតិជន

៥.២. ☐ សន្ទានកម្ម[៤]

៥.៣. ☐ អធិបញ្ញាផ្តល់ការព្យាបាល

៥.៤. ☐ ជនរងគ្រោះ / ដើមបណ្តឹងបោះបង់បណ្តឹងតាមការស្នើសុំរបស់ព្រះរាជអាជ្ញា

៥.៥. ☐ និយ័តកម្មតាមសំណើរបស់ព្រះរាជអាជ្ញា

៥.៦. ☐ ការរំលឹកពីអត្ថបទច្បាប់ / ការព្រមាន[៥]

៥.៧. ☐ ការកំណត់ទិសដៅចំពោះចេតនាសម្ព័ន្ធនៃសុខភាពនៃសង្គម ឬ វិជ្ជាជីវៈ

៥.៨. ☐ ការសម្រុះសម្រួលព្រហ្មទណ្ឌ[៦]

៦. នីតិវិធីជាជម្រើសអនុវត្តដោយអាជ្ញាធរផ្សេងៗទៀត

៦.១. ☐ ការចោទប្រកាន់ ឬ ទណ្ឌកម្មផ្សេងទៀតមិនមែនព្រហ្មទណ្ឌ

៧. ជនល្មើសមិនត្រូវបានស្គាល់

៧.១. ☐ ជនល្មើសមិនត្រូវបានស្គាល់

៨. ជំនួយការអប់រំ

៨.១. ☐ ការផ្តល់ជំនួយការអប់រំជំនួសការចោទប្រកាន់

ការសង្កេតផ្សេងៗ :

......................................................................................................................................................

......................................................................................................................................................

......................................................................................................................................................

......................................................................................................................................................

......................................................................................................................................................

......................................................................................................................................................

......................................................................................................................................................

......................................................................................................................................................

......................................................................................................................................................

......................................................................................................................................................

......................................................................................................................................................

......................................................................................................................................................

---

[៣] សកម្មភាពដែលជនល្មើសបានបញ្ឈប់បទល្មើស និងស្តារស្ថានភាពឡើងវិញ

[៤] ករណីចែងដោយច្បាប់

[៥] ព្រះរាជអាជ្ញាចាប់ផ្តើមនីតិវិធីដែលជាបទល្មើសតាមកំណត់ច្បាប់ និងធ្វើការព្រមានឱ្យឈប់ប្រព្រឹត្ត

[៦] ករណីចែងដោយច្បាប់

ធ្វើនៅ........................., ថ្ងៃទី ....... ខែ ......... ឆ្នាំ២០.....

តំណាងអយ្យការ

**ឧបសម្ព័ន្ធទី៤**

***គំរូដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ*** (វាយឡើងវិញ)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម

សាលាដំបូងរាជធានីភ្នំពេញ

# ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

សំណុំរឿងព្រហ្មទណ្ឌលេខ......

ចុះថ្ងៃទី.......ខែ........ឆ្នាំ២០០...

លេខ.........................អ.យ.ខ[71]

យើង ............................................តំណាងអយ្យការអមសាលាដំបូងក្រុងភ្នំពេញ។

បានឃើញសំណុំរឿងលេខ ................................ ចុះថ្ងៃទី..........ខែ.......ឆ្នាំ.......................

របស់[72] ......................................................................................................។

**ក្រោយពីបានពិនិត្យឯកសារខាងលើ បានយល់ឃើញថាមានតម្រុយសន្មតបានថា:**

នាមត្រកូល..............................នាមខ្លួន................................ហៅ..................................

ភេទ...........អាយុ...........ឆ្នាំ............សញ្ជាតិ................របររកស៊ី......................................

ទីកន្លែងកំណើត.....................................................ឃុំ-សង្កាត់....................................

ស្រុក-ខណ្ឌ........................................ខេត្ត-ក្រុង...........................................................

ទីលំនៅបច្ចុប្បន្ន....................................ឃុំ-សង្កាត់...................................................

ស្រុក-ខណ្ឌ........................................ខេត្ត-ក្រុង...........................................................

ទោសពីមុន.............ឪពុកឈ្មោះ.........................“រ.ស” ម្ដាយឈ្មោះ.........................“រ.ស”

ប្តី ឬប្រពន្ធឈ្មោះ.......................................... “រ.ស” មានកូន...........................ឬនៅលីវ

[71] លេខដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

[72] លេខសំណុំរឿងរបស់នគរបាលយុត្តិធម៌

អនីតិជន ☐ ឬនីតិជន ☐ ។

**បានប្រព្រឹត្តអំពើដូចតទៅ**[73]**:** ...........................................................................................

...........................................................................................................................

...........................................................................................................................

...........................................................................................................................

...........................................................................................................................

...........................................................................................................................

...........................................................................................................................

...........................................................................................................................

...........................................................................................................................

.........................................................................................................................។

អំពើខាងលើជាបទល្មើស ......................................ប្រព្រឹត្តទៅ.............................
................................................ កាលពីថ្ងៃទី............ខែ..........ឆ្នាំ........... តាមត្រា...........
នៃច្បាប់ .............................................................................................................។

បានឃើញមាត្រា៩៤ និងមាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

## សម្រេច

បើកការស៊ើបសួរលើអង្គហេតុខាងលើនិង:

☐ ដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យ[74] : .......................................................

...........................................................................................................................

.........................................................................................................................។

☐ ដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[75] : ...............................

...........................................................................................................................

...........................................................................................................................

[73] សេចក្តីសង្ខេបអង្គហេតុ

[74] ឈ្មោះជនត្រូវចោទ

[75] កាតាព្វកិច្ចណាមួយដែលបានចែងនៅក្នុងមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

☐ ដាក់ឲ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្ន[76] : ...................................

.......................................................................................................................................

.......................................................................................................................................។

ធ្វើនៅអយ្យការ, ថ្ងៃទី ........ ខែ ......... ឆ្នាំ២០០ ......

**តំណាងអយ្យការ**

[76] មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្នដែលបានចែងនៅក្នុងមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

## ឧបសម្ព័ន្ធទី៥



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអមសាលាដំបូង**
**រាជធានីភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌលេខៈ ៨៦៧
ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០១៧
លេខ:............................អ.យ.រ

## ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

យើង ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៨៦៧ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០១៧ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ពាក្យបណ្ដឹងផ្ទាល់ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០១៧ របស់ដើមបណ្ដឹងឈ្មោះ ភេទ ប្រុស អាយុ ៣៦ឆ្នាំ បានប្ដឹងចោទប្រកាន់លើឈ្មោះ ភេទ ប្រុស និងឈ្មោះ ភេទ ស្រី អាយុ ៥៧ឆ្នាំ ពីបទ រំលោភលើទំនុកចិត្ត។

### ក្រោយពីបានពិនិត្យឯកសារខាងលើ

**ឃើញថា មានតម្រុយសន្មតបានថា៖**

-នាមត្រកូល-នាមខ្លួន ភេទ ស្រី អាយុ ៥៧ឆ្នាំ (០២-៧-១៩៥៩) ជនជាតិ ខ្មែរ កើតនៅសង្កាត់លេខ ៣ ក្រុងភ្នំពេញ សាសនា ព្រះពុទ្ធ ទីលំនៅបច្ចុប្បន្នផ្ទះលេខ ២៧៩ង ផ្លូវ លំ ក្រុម ២ ភូមិ ស្លែងរលើង សង្កាត់ ទឹកថ្លា ខណ្ឌ សែនសុខ រាជធានីភ្នំពេញ មុខរបរ មន្ត្រីសុខាភិបាលនៅមន្ទីរពេទ្យកុមារជាតិ ប្ដីឈ្មោះ (លែងលះ) "រ" មានកូន ០៤នាក់ ឪពុកឈ្មោះ "ស" ម្ដាយឈ្មោះ "រ" ទោសពីមុន-គ្មាន ជា-នីតិជន។ (ក្រៅឃុំ)

**បានប្រព្រឹត្តអំពើដូចតទៅ[២]៖**

កាលពីអំឡុងខែ កញ្ញា ឆ្នាំ២០១៦ ឈ្មោះ បានផ្ញើរប្រាក់ចំនួន០២ពាន់ដុល្លារ ឲ្យទៅមិត្តភក្តិឈ្មោះ ដែលរស់នៅប្រទេសជប៉ុនដើម្បីទិញឥវ៉ាន់មកឲ្យខ្លួនរួមមានៈ កៅអីម៉ាស្សា០១គ្រឿង, កៅអីសម្រាប់យោលទារក០១គ្រឿង, ពោងសម្រាប់ក្មេងហែលទឹក០១, ឡាំងទឹក Sauce, អាហារកញ្ចប់, ឱសថបុរាណ, ម្ហូបកូនក្មេង, រថយន្តម៉ាកនីសាន់០១គ្រឿង ព្រមទាំងសំភារៈប្រើប្រាស់មួយចំនួនទៀត។ បន្ទាប់ពីឈ្មោះ បានប្រគល់ប្រាក់ឲ្យទៅឈ្មោះ រួចមកឈ្មោះ បានប្រាប់ទៅឈ្មោះ វិញថា ឥវ៉ាន់ទាំងអស់ខាងលើនេះនឹងរៀបចំផ្ញើរមកឲ្យ តាមរយៈឈ្មោះ និងម្ដាយឈ្មោះ ហើយនៅពេលដែលអ្នកទាំងពីរបានទទួលឥវ៉ាន់ទាំងអស់ខាងលើនេះ ហើយ ឈ្មោះ និងឈ្មោះ នឹងទាក់ទងមកឈ្មោះ ដើម្បីទៅទទួលឥវ៉ាន់ទាំង

---

[២] សេចក្ដីសង្ខេបអង្គហេតុ

នោះ។ ក្រោយមកនៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ២០១៦ ឈ្មោះ បានទាក់ទងទៅឈ្មោះ ដើម្បីសួរនាំអំពីឥវ៉ាន់របស់ខ្លួនដែលបានផ្ញើរមកពីប្រទេសជប៉ុន ពេលនោះស្រាប់តែឈ្មោះ បានប្រាប់មកឈ្មោះ វិញថា ឥវ៉ាន់ទាំងអស់ខាងលើនោះខ្លួន បានលក់អស់ទៅហើយ ដោយសារទាក់ទងទៅម្ចាស់ឥវ៉ាន់ពុំបាន។

អំពើខាងលើជាបទល្មើស *រំលោភលើទំនុកចិត្ត* ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីអំឡុងខែ កញ្ញា ឆ្នាំ២០១៦ បទល្មើសដែលមានបញ្ញត្តិអោយផ្តន្ទាទោសតាមមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

បានឃើញ មាត្រា ៤៤ និងមាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧។

**<u>ហេតុដូច្នេះសម្រេច</u>**

បើកការស៊ើបសួរលើអង្គហេតុខាងលើ និងស្នើសុំ៖

☑ ដាក់អោយស្ថិតនៅក្រោមការពិនិត្យ[៣]៖

-ឈ្មោះ ភេទ ស្រី អាយុ ៥៧ឆ្នាំ (ក្រៅឃុំ)

ពីបទ *រំលោភលើទំនុកចិត្ត* ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីអំឡុងខែ កញ្ញា ឆ្នាំ២០១៦ តាមមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

☐ដាក់អោយស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[៤]៖..........................................។

☐ដាក់អោយស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្ន[៥]៖...................................................។

រាជធានីភ្នំពេញ, ថ្ងៃទី..........ខែ............ឆ្នាំ២០១៧

**ជ.ព្រះរាជអាជ្ញា**

---

[៣] ឈ្មោះជនត្រូវចោទ

[៤] កាតព្វកិច្ចណាមួយដែលបានចែងនៅក្នុងមាត្រា ២២៣

[៥] មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្នដែលបានចែងនៅក្នុងមាត្រា ២០៥

## ឧបសម្ព័ន្ធទី៦

**<u>គំរូដីកាកោះហៅបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់</u>** (វាយឡើងវិញ)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម

សាលាដំបូងរាជធានីភ្នំពេញ

# <u>ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់</u>

សំណុំរឿងព្រហ្មទណ្ឌលេខ......

ចុះថ្ងៃទី.......ខែ........ឆ្នាំ២០០...

យើង ...................................... តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។ បញ្ជាឲ្យចូលទៅបង្ហាញខ្លួននៅសវនាការ:

នាមត្រកូល.............................នាមខ្លួន................................ហៅ................................

ភេទ..........អាយុ..........ឆ្នាំ...........សញ្ជាតិ.................របររកស៊ី.......................................

ទីកន្លែងកំណើត.......................................................ឃុំ-សង្កាត់..................................

ស្រុក-ខណ្ឌ.......................................ខេត្ត-ក្រុង...........................................................

ទីលំនៅបច្ចុប្បន្ន...................................ឃុំ-សង្កាត់........................................................

ស្រុក-ខណ្ឌ.......................................ខេត្ត-ក្រុង...........................................................

ទោសពីមុន............ឪពុកឈ្មោះ........................"រ.ស" ម្ដាយឈ្មោះ....................... "រ.ស"

ប្ដី ឬប្រពន្ធឈ្មោះ............................................ "រ.ស" មានកូន..........................ឬនៅលីវ

អនីតិជន ☐ ឬនីតិជន ☐ ។

អ្នកត្រូវបានចោទប្រកាន់ពីអង្គហេតុ[77]៖..................................................................................

........................................................................................................................................

........................................................................................................................................

[77] សេចក្ដីសង្ខេបអង្គហេតុដែលរៀបរាប់អំពីធាតុសត្យានុម័ត និងអត្តនោម័ត

...........................................................................................................................................

...........................................................................................................................................

...........................................................................................................................................

.......................................................................................................................................។

ជាបទល្មើស...........................................................................................................

ប្រព្រឹត្តនៅ..................................................................................................................................

កាលពីថ្ងៃ.......ខែ.......ឆ្នាំ...........ដែលមានចែងក្នុងមាត្រា................................នៃច្បាប់...............

....................................................................................................................................................។

សវនាការនេះប្រព្រឹត្តទៅនាថ្ងៃទី.........ខែ..........ឆ្នាំ...........វេលាម៉ោង...............................

នៅ..........................................................................................................................................។

សាមីខ្លួនអាចពឹងមេធាវីឲ្យអមខ្លួនបាន ។

សាមីខ្លួនត្រូវចូលបង្ហាញខ្លួនឲ្យទាន់ពេលវេលា និងយកលិខិតផ្សេងៗដែលទាក់ទងនឹងជីវភាពសាមីខ្លួន ឬដំណើររឿងខាងលើមកជាមួយផង ប្រសិនបើមាន។

ធ្វើនៅអយ្យការ, ថ្ងៃទី.........ខែ.......ឆ្នាំ២០០....

**តំណាងអយ្យការ**

**ឧបសម្ព័ន្ធទី៧**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអមសាលាដំបូង
រាជធានីភ្នំពេញ

**ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់**

លេខ:......................អ.យ.រ

យើង ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ២០៨៣ ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ២០១៧ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់ឃើញថា៖** កាលពីថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ២០១៧ វេលាម៉ោង ២៣ និង៤២នាទី គណៈកម្មការចម្រុះបានចុះត្រួតពិនិត្យជាតិស្រវឹង នៅចំណុចគោលដៅត្រួតពិនិត្យខាងត្បូងផ្សារអូឬស្សី លើផ្លូវលេខ ១៨២ សង្កាត់ ផ្សារអូឬស្សី១ ខណ្ឌ ៧មករា រាជធានីភ្នំពេញ បានឃាត់ម៉ូតូ០១គ្រឿងម៉ាក HONDA XR250 ពណ៌ក្រហម ពាក់ផ្លាកលេខ ភ្នំពេញ 1BL-7727 បើកបរដោយឈ្មោះ ភេទ ប្រុស អាយុ ៣២ឆ្នាំ។ បន្ទាប់ពីធ្វើតេស្តជាតិអាល់កុលលើឈ្មោះ រួចមកឃើញថា មានអាត្រាជាតិអាល់កុល 0,83mg/L។

-បានឃើញ របាយការណ៍សំយោគលេខ ១៣៨/១៧ ល.ស ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ២០១៧ របស់ការិយាល័យនគរបាលចរាចរណ៍ផ្លូវគោក នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានធ្វើការសន្និដ្ឋានថា: អ្នកបើកម៉ូតូស្ថិតក្នុងភាពស្រវឹងមានអាត្រាជាតិអាល់កុល 0,83mg/L ល្មើសនឹងច្បាប់ចរាចរណ៍ផ្លូវគោក (ជំពូកទី ១០ ទោសបញ្ញត្តិមាត្រា ៧៧)។

-បានឃើញ ចម្លើយរបស់ជនសង្ស័យឈ្មោះ ភេទ ប្រុស អាយុ ៣២ឆ្នាំ បានឆ្លើយនៅសមត្ថកិច្ចថា: មុនពេលកើតហេតុវេលាម៉ោង ១៩ និង៣០នាទី ខ្លួនបានហូបស្រាបៀរ ABC ចំនួន ០៣កំប៉ុង នៅក្នុងផ្ទះជួលបុរីចំការដូង ក្រោយមកខ្លួនបានចេញទៅហូបបបរសនៅផ្សារអូឬស្សី រួចហើយបានចេញមកវិញដោយធ្វើដំណើរតាមផ្លូវហ្សាដឺហ្គោល ក្នុងទិសដៅពីលិចទៅកើត លុះមកដល់ផ្លូវខាងត្បូងផ្សារអូឬស្សី ក៏បានជួបជាមួយសមត្ថកិច្ចកំពុងត្រួតពិនិត្យជាតិស្រវឹង ក៏ឃាត់រូបខ្លួនដើម្បីធ្វើតេស្តរកជាតិអាល់កុល ពេលនោះរកឃើញថាមានអាត្រាជាតិអាល់កុល 0,83mg/L បន្ទាប់មកប៉ូលីសបានបញ្ជូនរូបខ្លួនទៅការិយាល័យនគរបាលចរាចរណ៍ផ្លូវគោករាជធានីភ្នំពេញ តែម្តង។

-បានឃើញ ឯកសារមួយចំនួនដែលពាក់ព័ន្ធនៅក្នុងសំណុំរឿង។

-យល់ឃើញថា: ផ្អែកតាមរបាយការណ៍សំយោគរបស់សមត្ថកិច្ច, ចម្លើយសារភាពរបស់ជនត្រូវចោទ និងភស្តុតាងនានាដែលប្រមូលបាន គឺមានភាពស៊ីសង្វាក់គ្នាដែលអាចបញ្ជាក់បានថា: ពិតជាមានអំពើ បើកបរយានយន្តនៅពេលដែលខ្លួនស្ថិតក្នុងស្ថានភាពស្រវឹង ប្រព្រឹត្តនៅចំណុចខាងត្បូងផ្សារអូរឬស្សី លើផ្លូវលេខ ១៨២ សង្កាត់ ផ្សារអូឬស្សី១ ខណ្ឌ ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៨ ខែ

កុម្ភៈ ឆ្នាំ២០១៧ ដែលប្រព្រឹត្តដោយជនសង្ស័យឈ្មោះ  ភេទ ប្រុស អាយុ ៣២ឆ្នាំ ប្រាកដមែន។

-អំពើរបស់ជនសង្ស័យឈ្មោះ  ភេទ ប្រុស អាយុ ៣២ឆ្នាំ បានធ្វើឲ្យប៉ះពាល់សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ ដែលច្បាប់បានការពារហើយតម្រូវឲ្យផ្តន្ទាទោស។

-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ដើម្បីចោទប្រកាន់លើឈ្មោះ  ភេទ ប្រុស អាយុ ៣២ឆ្នាំ ពីបទ បើកបរយានយន្តនៅពេលដែលខ្លួនស្ថិតក្នុងស្ថានភាពស្រវឹង ប្រព្រឹត្តនៅចំណុចខាងត្បូងផ្សារអូរឫស្សី លើផ្លូវលេខ ១៨២ សង្កាត់ ផ្សារអូរឫស្សី១ ខណ្ឌ ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ២០១៧ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៧៧ នៃច្បាប់ស្តីពី ចរាចរណ៍ផ្លូវគោក។

## <u>ហេតុដូច្នេះសម្រេច</u>

-នាម-គោត្តនាមៈ  ភេទ ប្រុស អាយុ ៣២ឆ្នាំ (១២-០៣-១៩៨៥) ជនជាតិ ខ្មែរ កើតនៅភូមិ ទ្រាស ឃុំ ទ្រាស ស្រុក ថ្មពួក ខេត្ត បាត់ដំបង សាសនា ព្រះពុទ្ធ ទីលំនៅបច្ចុប្បន្ន ផ្ទះជួលបុរីចំការដូង មុខរបរ បុគ្គលិកក្រុមហ៊ុន ឪពុកឈ្មោះ  "រ" ម្តាយឈ្មោះ  "រ" ជានីតិជន។ (ក្រៅឃុំ)

-ត្រូវចោទពីបទ *បើកបរយានយន្តនៅពេលដែលខ្លួនស្ថិតក្នុងស្ថានភាពស្រវឹង* ប្រព្រឹត្តនៅចំណុចខាងត្បូងផ្សារអូរឫស្សី លើផ្លូវលេខ ១៨២ សង្កាត់ ផ្សារអូរឫស្សី១ ខណ្ឌ ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ២០១៧ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៧៧ នៃច្បាប់ស្តីពី ចរាចរណ៍ផ្លូវគោក។

-បញ្ជូនជនជាប់ចោទដូចមានឈ្មោះខាងលើ សំណុំរឿងព្រហ្មទណ្ឌលេខ ២០៨៣ ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ២០១៧ និងវត្ថុតាង ព្រមទាំងបញ្ជីរាយនាមជនដែលទាក់ទិនក្នុងសំណុំរឿងនេះ ទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីជំនុំជម្រះតាមច្បាប់។

រាជធានីភ្នំពេញ, ថ្ងៃទី............ខែ............ឆ្នាំ២០១៧

**ជ.ព្រះរាជអាជ្ញា**

**ឧបសម្ព័ន្ធទី៨**

**<u>គំរូកំណត់ហេតុស្ដីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម</u>** (វាយឡើងវិញ)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# <u>កំណត់ហេតុស្ដីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម</u>

អយ្យការអម

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌលេខ.........

ចុះថ្ងៃទី......ខែ.......ឆ្នាំ២០០........

ឆ្នាំពីរពាន់................ខែ.................ថ្ងៃទី..................វេលាម៉ោង....................................។

យើង........................................................តំណាងអយ្យការអមសាលាដំបូងក្រុងភ្នំពេញ

បានឃើញសំណុំរឿងលេខ[78]........................ចុះថ្ងៃទី.............ខែ................ឆ្នាំ................

របស់.................................................................។

បុគ្គលដែលនៅចំពោះមុខយើង បានផ្ដល់ព័ត៌មានអំពីអត្តសញ្ញាណដូចខាងក្រោម:

នាមត្រកូល..............................នាមខ្លួន.................................ហៅ .................................

ភេទ...........អាយុ...........ឆ្នាំ.............សញ្ជាតិ.................របររកស៊ី.......................................

ទីកន្លែងកំណើត........................................................ឃុំ-សង្កាត់ ...................................

ស្រុក-ខណ្ឌ.......................................ខេត្ត-ក្រុង ...........................................................

ទីលំនៅបច្ចុប្បន្ន...................................ឃុំ-សង្កាត់ ........................................................

ស្រុក-ខណ្ឌ.........................................ខេត្ត-ក្រុង.............................................................

ទោសពីមុន.............ឪពុកឈ្មោះ........................ "រ.ស" ម្ដាយឈ្មោះ..........................រ.ស"

ប្ដី ឬប្រពន្ធឈ្មោះ............................................ "រ.ស" មានកូន..........................ឬនៅលីវ

អនីតិជន ☐ ឬនីតិជន ☐ ។

---

[78] លេខសំណុំរឿងរបស់អង្គភាពនគរបាលយុត្តិធម៌

**យើងប្រាប់បុគ្គលនេះនូវអង្គហេតុដែលខ្លួនត្រូវចោទប្រកាន់មានដូចតទៅ...........................**

.....................................................................................................................................................

.....................................................................................................................................................

.....................................................................................................................................................

.....................................................................................................................................................

.....................................................................................................................................................

.....................................................................................................................................................

.....................................................................................................................................................

.....................................................................................................................................................

.....................................................................................................................................................

.....................................................................................................................................................

............................................................................................................. ។

អង្គហេតុនេះជាបទល្មើស .......................................................................................

ប្រព្រឹត្តនៅ.....................................................................................................................................

កាលពីថ្ងៃទី............ខែ.........ឆ្នាំ២០០.....ដែលមានចែងផ្តន្ទាទោសតាមាត្រា........................

នៃច្បាប់...........................................................................................................................។

យើងបានទទួលចម្លើយពីជនជាប់ចោទនេះដូចតទៅ:

.....................................................................................................................................................

.....................................................................................................................................................

.....................................................................................................................................................

.....................................................................................................................................................

យើងបានប្រាប់ដល់ជននេះថា: ខ្លួមានសិទ្ធិសុំពឹងមេធាវី តាមការជ្រើសរើសរបស់ខ្លួន ឬស្នើសុំឲ្យមានការចាត់តាំងមេធាវីដោយអនុលោមតាមបញ្ញត្តិច្បាប់។

**ជននេះបានឆ្លើយថា:**

- ☐ ខ្ញុំជ្រើសរើស លោក/លោកស្រីមេធាវី......................................................។
- ☐ ខ្ញុំសូមស្នើសុំឲ្យមានការចាត់តាំងមេធាវីស្របតាមបញ្ញត្តិច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។
- ☐ ខ្ញុំមិនត្រូវការមេធាវីទេក្នុងពេលនេះ។

**យើងបានបញ្ជាក់ថា:**

- ☐ លោក/លោកស្រីមេធាវី...........................................អាចពិនិត្យសំណុំរឿង និងទាក់ទងជាមួយជនជាប់ចោទ។
- ☐ យោងតាមសំណើសុំឲ្យមានការចាត់តាំងមេធាវី ស្របតាមបញ្ញត្តិច្បាប់ស្តីពីលក្ខន្តិកៈមេធាវីតំណាង គណៈមេធាវីត្រូវបានជូនដំណឹងភ្លាម។
- ☐ លោក/លោកស្រីមេធាវី ...........................................................អវត្តមាន។

បានឃើញមាត្រា ៩៧ មាត្រា ៩៨ និងមាត្រា ៣០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

## សម្រេច

បញ្ជូនជនជាប់ចោទឈ្មោះ...........................................ទៅតុលាការដើម្បីធ្វើការជំនុំជម្រះតាមនីតិវិធីនៃការបង្ហាញខ្លួនភ្លាម ចំពោះអង្គហេតុ និងបទល្មើសដូចខាងលើ។

ក្រោយពីបានអាន ជនជាប់ចោទចុះហត្ថលេខាជាមួយយើង។

**ជនជាប់ចោទ** **តំណាងអយ្យការ**

# ឧបសម្ព័ន្ធទី៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអមសាលាដំបូង
រាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌលេខ:៣៤៩៤
ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៦
លេខ:..............................អ.យ.រ

## កំណត់ហេតុស្ដីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម

**ឆ្នាំពីរពាន់ដប់ប្រាំមួយ ខែ កក្កដា ថ្ងៃទី ម្ភៃពីរ វេលាម៉ោង ដប់ប្រាំ និងសាមសិបនាទី។**

យើង ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ របាយការណ៍លេខ ២១៥/១៦ របក ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ២០១៦ របស់អធិការដ្ឋាននគរបាលខណ្ឌសែនសុខ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ។

**បុគ្គលដែលនៅចំពោះមុខយើង បានផ្ដល់នូវពត៌មានអំពីអត្តសញ្ញាណដូចខាងក្រោម៖**

នាម-គោត្តនាមៈ ហៅ ភេទ ប្រុស អាយុ ២៦ឆ្នាំ (០៥-០២-១៩៩០) ជនជាតិ ខ្មែរ-ឥស្លាម កើតនៅសង្កាត់ ច្រាំងចំរេះទី១ ខណ្ឌ ឫស្សីកែវ ក្រុងភ្នំពេញ សាសនា ឥស្លាម ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ២២៩ ផ្លូវលេខ ៥ សង្កាត់ ច្រាំងចំរេះទី២ ខណ្ឌ ឫស្សីកែវ រាជធានីភ្នំពេញ មុខរបរ លក់ហ្គាស់ នៅលីវ ឪពុកឈ្មោះ "ស" ម្ដាយឈ្មោះ "រ" ទោសពីមុន-គ្មាន ជា-នីតិជន។

**យើងប្រាប់ដល់បុគ្គលនេះ នូវអង្គហេតុដែលខ្លួនត្រូវបានចោទប្រកាន់មានដូចតទៅ៖**

-កាលពីថ្ងៃទី ២១ កក្កដា ឆ្នាំ២០១៦ វេលាម៉ោងប្រហែល ០៩ និង០០នាទី មានករណីលួច នៅចំណុច ក្នុងហាងយីហោ យូឡោមី ផ្លូវ ២០១១ ភូមិ គោកឃ្លាង សង្កាត់ ភ្នំពេញថ្មី ខណ្ឌ សែនសុខ រាជធានីភ្នំពេញ ដែលបង្កដោយជនសង្ស័យម្នាក់ឈ្មោះ ហៅ ភេទ ប្រុស អាយុ ២៦ឆ្នាំ បានធ្វើសកម្មភាពលួចធុងហ្គាសពីទីតាំងខាងលើ ដែលពេលកំពុងធ្វើសកម្មភាពនោះ ម្ចាស់ហាងបានឃើញទាន់ ស្រែកថា "ចោរ"ៗ ហើយបុគ្គលិកក្នុងហាងក៏បាននាំគ្នារត់ដេញចាប់ជនសង្ស័យបាន ប្រគល់ឲ្យសមត្ថកិច្ចប៉ុស្ដិ៍នគរបាលភ្នំពេញថ្មីតែម្ដង។

**អង្គហេតុនេះជាបទល្មើស៖** លួច ប្រព្រឹត្តនៅចំណុចក្នុងហាងយីហោ យូឡោមី ផ្លូវ ២០១១ ភូមិ គោកឃ្លាង សង្កាត់ ភ្នំពេញថ្មី ខណ្ឌ សែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

**យើងបានទទួលចម្លើយដូចតទៅ៖**

-ឈ្មោះ ភេទ ប្រុស អាយុ ៤៣ឆ្នាំ ជាដើមបណ្ដឹងបានឆ្លើយនៅមន្ត្រីនគរបាលយុត្តិធម៌ថា៖ នៅថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ២០០១៦ វេលាម៉ោងប្រហែល ០៩ និង០០នាទី មុនពេលកើតហេតុ ខ្លួន

បានជិះរថយន្តចេញពីផ្ទះ ភូមិ ក្រាំងអង្រ្កង សង្កាត់ ក្រាំងធ្នង់ ទៅមើលហាងយីហោ យូឡោមី ភូមិ គោកឃ្លាំង សង្កាត់ ភ្នំពេញថ្មី ពេលដល់មុខហាងរបស់ខ្លួន ស្រាប់តែឃើញមនុស្សប្រុសម្នាក់កំពុងទាញធុងហ្គាសចេញពីក្នុងហាងក្បែររបងផ្នែកខាងស្តាំ ភ្លាមនោះខ្លួនបានបើកទ្វាររថយន្តចេញទៅ ហើយស្រែកថា "ចោរ"ៗ ពេលនោះបុគ្គលិកនៅហាងរបស់ខ្លួនបានចេញមកចាប់មនុស្សប្រុសនោះបាន នាំយកមកប្រគល់ឲ្យសមត្ថកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលភ្នំពេញថ្មី និងបានដាក់ពាក្យបណ្តឹងចោទប្រកាន់លើមនុស្សប្រុសនោះតែម្តង។

-ឈ្មោះ                    ភេទ ប្រុស អាយុ ១៦ឆ្នាំ ជាសាក្សីបានឆ្លើយនៅមន្ត្រីនគរបាលយុត្តិធម៌ថា៖ នៅថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ២០១៦ វេលាម៉ោងប្រហែល ០៩ និង០០នាទី មុនពេលកើតហេតុ ខ្លួនកំពុងនៅក្នុងហាង យីហោ យូឡោមី នៅភូមិ គោកឃ្លាង សង្កាត់ភ្នំពេញថ្មី ស្រាប់តែលឺសំលេងស្រែកថា "ចោរ"ៗ ភ្លាមនោះ ខ្លួន និងបុគ្គលិកដែលដេកនៅក្នុងហាងបាននាំគ្នាចេញមក្រៅហាង រួចនាំគ្នាដេញចាប់មនុស្សប្រុសនោះបាននាំយកមកប្រគល់ឲ្យសមត្ថកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលភ្នំពេញថ្មីតែម្តង។

-ឈ្មោះ            ហៅ                    ភេទ ប្រុស អាយុ ២៦ឆ្នាំ ជាជនសង្ស័យបានឆ្លើយនៅសមត្ថកិច្ចថា: នៅថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ២០១៦ វេលាម៉ោងប្រហែល ០៩ និង០០នាទី មុនពេលកើតហេតុ ខ្លួនបានជិះម៉ូតូមួយគ្រឿងម៉ាក សេ១២៥ ពណ៌ខ្មៅ ស៊េរីឆ្នាំ២០១៥ ចេញពីផ្ទះ (សង្កាត់ច្រាំងចំរេះ២) មកផ្ទះមិត្តភក្តិនៅភូមិច្រេស សង្កាត់ភ្នំពេញថ្មី ដោយជិះតាមផ្លូវលេខ ២០១១ ពីទិសខាងកើតទៅលិច មកដល់មុខហាងយីហោ យូឡោមី ភូមិគោកឃ្លាង សង្កាត់ភ្នំពេញថ្មី ឃើញមានសភាពស្ងាត់ខ្លួនបានឈប់ម៉ូតូនៅចំហៀងហាងផ្នែកខាងស្តាំ ហើយដើរចូលទៅក្នុងហាងតាមប្រឡោះប្រហោងរបងផ្នែកខាងស្តាំ រួចលួចយកធុងហ្គាសបានសម្រេច ដើរចេញមកវិញតាមទ្វារមុខ ស្រាប់តែម្ចាស់ហាងឃើញទាន់ស្រែកថា "ចោរ"ៗ ភ្លាមនោះ បុគ្គលិកនៅក្នុងហាងបាននាំគ្នារត់ដេញចាប់រូបខ្លួនបាន នាំយកមកប្រគល់ឲ្យសមត្ថកិច្ចប៉ុស្តិ៍នគរបាលភ្នំពេញថ្មីតែម្តង។

-នៅអយ្យការជនសង្ស័យបានឆ្លើយបដិសេធថា: មុនពេលកើតហេតុ ប្រហែលបួនខែមុន ខ្លួនបានយកធុងហ្គាស់ចំនួន ០៤ធុង (០១ធុងទម្ងន់៤៨គីឡូ) ទៅដាក់នៅហាង យូឡោមី ផ្លូវ ឧកញ៉ាទ្រីហេង តាមការកុម្មង់ របស់ម្ចាស់ហាង ហើយពេលដាក់នោះ ម្ចាស់ហាងពុះទាន់ទូទាត់ប្រាក់ឲ្យខ្លួនភ្លាមៗទេ និងពុំព្រមចុះហត្ថលេខាទទួលធុងហ្គាសពីខ្លួនឡើយ ពេលនោះដោយសារខ្លួនចង់ផ្គាប់ចិត្តភ្ញៀវ ខ្លួនក៏ធ្វើតាមគាត់ដោយមិនធ្វើការទូទាត់ប្រាក់ភ្លាមៗឡើយ។ ក្រោយមកនៅពេលខ្លួនទៅទារប្រាក់ថ្លៃហ្គាស់សរុបចំនួន ១៤០ ដុល្លា (០១ធុងតំលៃ៣៥ដុល្លារ) ពីម្ចាស់ហាងយូឡោមីនោះ ម្ចាស់ហាងចេះតែបង្ហាញសកម្មភាពវល់នេះវល់នោះ និងបានឲ្យខ្លួនត្រឡប់ទៅវិញសិន ចាំមកថ្ងៃក្រោយទៀត ហើយខ្លួនបានព្យាយាមជួបគាត់ច្រើនលើកច្រើនសារ តែគាត់នៅតែធ្វើមិនដឹង ទោះបីខ្លួនទាក់ទងគាត់តាមទូរស័ព្ទ ក៏គាត់ហាក់មិនអើពើជាមួយខ្លួនដែរ ខ្លួនក៏បានប្រាប់គាត់ថា ខ្លួនត្រូវយកធុងហ្គាស់របស់ខ្លួនទៅវិញហើយ ព្រោះខ្លួនពុំមានប្រាក់សងថ្លៃទិញហ្គាសពីគេទេ។ នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០១៦ វេលាម៉ោងប្រហែលប្រាំបួនព្រឹក រូបខ្លួនបានចេញពីផ្ទះគោលបំណងទៅហាងយូឡោមី ដើម្បីយកធុងហ្គាសរបស់ខ្លួនមកវិញ លុះពេលទៅដល់ ពុំឃើញមានអ្នកនៅក្នុងហាងទេ ពេលនោះដោយសារខ្លួនមានការប្រញាប់ មិនចង់រំខានដល់បុគ្គលិកក្នុងហាងផង និងខ្លួនក៏ធ្លាប់ចេញចូលហាងនោះផង ខ្លួនក៏បានចូលទៅក្នុងហាងនោះផង ខ្លួនក៏បានចូលទៅក្នុងហាងយូឡោមី តាមរបងចំហៀង យកធុងហ្គាសមួយចេញមកក្រៅ ភ្លាមនោះស្រាប់តែម្ចាស់ហាងស្រែកហៅបុគ្គលិកឲ្យមកព្រួតវាយ

ខ្លួនបណ្តាលឲ្យបែកក្បាល រួចទើបប្រគល់ខ្លួនឲ្យសមត្ថកិច្ច។ ខ្លួនសុំជម្រាបជូនថា ខ្លួនពុំមានបំណងលួចទ្រព្យសម្បត្តិរបស់អ្នកដទៃទេ ចំណែកធុងហ្គាសដែលខ្លួនយកទៅធ្វើជាប្រយោជន៍របស់គាត់ ព្រោះខ្លួនទើបតែលឺដំណឹងថា ម្ចាស់ហាងយូឡោមី បានតែបំបាត់យកហ្គាសរបស់ហាងផ្សេងៗ ០៤ហាងមកហើយ ហេតុនេះហើយទើបខ្លួនយកធុងហ្គាសរបស់ខ្លួនមកវិញ ដើម្បីដោះស្រាយជីវភាពប្រចាំថ្ងៃ។ ខ្លួនសំណូមពរដល់លោកព្រះរាជអាជ្ញារង មេត្តាអនុញ្ញាតឲ្យខ្លួនត្រឡប់ទៅផ្ទះវិញផង ព្រោះខ្លួនពុំបានប្រព្រឹត្តអំពើខុសច្បាប់នោះទេ ហើយខ្លួនក៏ត្រូវទៅមើលម្តាយចាស់ជរាពិការជើងនៅផ្ទះ បើគ្មានរូបខ្លួនទេ គ្មានអ្នកណាមើលថែគាត់ និងរកប្រាក់ផ្គត់ផ្គង់ផ្ទះទេ។

**យើងបានប្រាប់ដល់ជននេះថាៈ** ខ្លួនមានសិទ្ធសុំពឹងមេធាវី តាមការជ្រើសរើសរបស់ខ្លួន ឬស្នើសុំអោយមានការចាត់តាំងមេធាវីដោយអនុលោមតាមបញ្ញត្តិច្បាប់ ។

**ជននេះបានឆ្លើយថាៈ**

☐ខ្ញុំជ្រើសលោក/លោកស្រីមេធាវី..............................................................។

☐ខ្ញុំសូមស្នើសុំអោយមានការចាត់តាំងមេធាវីស្របតាមបញ្ញាត្តិច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។

☐ខ្ញុំមិនត្រូវការមេធាវីទេក្នុងពេលនេះ។

**យើងបានបញ្ជាក់ថាៈ**

☐លោក/លោកស្រីមេធាវី.........................................................អាចពិនិត្យសំណុំរឿង និងទាក់ទងជាមួយជនជាប់ចោទ ។

☐យោងលើសំណើសុំអោយមានការចាត់តាំងមេធាវីស្របតាមបញ្ញត្តិច្បាប់ស្តីពីលក្ខន្តិកៈមេធាវី តំណាងគណៈមេធាវីត្រូវបានជូនដំណឹងភ្លាម ។

☐លោក/លោកស្រីមេធាវី..................................................................អវត្តមាន ។

**បានឃើញមាត្រា ៤៧,មាត្រា ៤៨ និងមាត្រា ៣០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ**

**<u>សម្រេច</u>**

បញ្ជូនជនជាប់ចោទឈ្មោះ ហៅ ភេទ ប្រុស អាយុ ២៦ឆ្នាំ ទៅតុលាការដើម្បីធ្វើការជំនុំជំម្រះតាមនីតិវិធីនៃការបង្ហាញខ្លួនភ្លាមចំពោះអង្គហេតុ និងបទល្មើសដូចខាងលើ ។

**ក្រោយពីបានអាន ជនជាប់ចោទបានផ្តិតមេដៃជាមួយយើង ។**

**ជនជាប់ចោទ** **ជ.ព្រះរាជអាជ្ញា**

**ឧបសម្ព័ន្ធទី១០**

**<u>គំរូពាក្យបណ្តឹងសាទុក្ខឧទ្ធរណ៍</u>** (វាយឡើងវិញ)

# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

## <u>ពាក្យបណ្តឹងឧទ្ធរណ៍</u>

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ ...................... អាយុ ....... ជនជាតិ ............ ទីលំនៅផ្ទះលេខ ......... ផ្លូវលេខ .......... ឃុំ/សង្កាត់ .................. ស្រុក/ខណ្ឌ .........................ខេត្តក្រុង..........................។

## <u>សូមគោរពជូន</u>

.....................................................

សូមទានជ្រាប។

**កម្មវត្ថុ:** ប្តឹងលើសាលក្រមរដ្ឋប្បវេណីលេខ ........... ចុះថ្ងៃទី ................ របស់សាលាដំបូង .......... ទាំងមូល ។

**យោង:** - សំណុំរឿងរដ្ឋប្បវេណីលេខ...........ចុះថ្ងៃទី................របស់សាលាដំបូង .................. ។

- សាលក្រមរដ្ឋប្បវេណីលេខ...........ចុះថ្ងៃទី.................របស់សាលាដំបូង .................. ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូចជម្រាបជូន ................ មេត្តាជ្រាបថា: កាលពីថ្ងៃទី .................... សាលាដំបូង ...................... បានទាញហេតុផលផ្ទាល់មាត់លើសំណុំរឿងរដ្ឋប្បវេណីលេខ ............... ចុះថ្ងៃទី ......................ហើយបានវិនិច្ឆ័យសេចក្តីក្នុងសាលក្រមរដ្ឋប្បវេណីលេខ...............ចុះថ្ងៃទី ................. ដែលប៉ះពាល់ដល់ផលប្រយោជន៍ខ្លាំងដល់រូបខ្ញុំបាទ/នាងខ្ញុំ ហើយខ្ញុំពុំសុខចិត្តនឹងសេខក្តីសម្រេចនេះទេ ។ ហេតុនេះខ្ញុំសូមប្តឹង ឧទ្ធរណ៍លើសាលក្រមរដ្ឋប្បវេណីលេខ................ ចុះថ្ងៃទី ............... របស់សាលាដំបូងទាំងមូល ។

អាស្រ័យហេតុនេះ ខ្ញុំបាទ/នាងខ្ញុំសូម ...................... មេត្តាទទួលនូវពាក្យបណ្តឹងឧទ្ធរណ៍របស់ ខ្ញុំបាទ/នាងខ្ញុំ ដើម្បីចាត់ការតាមនីតិវិធីនៃច្បាប់ដោយអនុគ្រោះ ។

សូម ...................... មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ ។

......................, ថ្ងៃទី ....... ខែ .......... ឆ្នាំ..........

ស្នាមមេដៃ

**ឧបសម្ព័ន្ធទី១១**

**គំរូពាក្យបណ្ដឹងសាទុក្ខ** (វាយឡើងវិញ)

# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យបណ្ដឹងសាទុក្ខ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ ....................... អាយុ ....... ជនជាតិ ............. ទីលំនៅផ្ទះលេខ .......... ផ្លូវលេខ .......... ឃុំ/សង្កាត់ .................. ស្រុក/ខណ្ឌ ............................ខេត្ត/ក្រុង.......................។

**សូមគោរពជូន**

**ឯកឧត្តមប្រធាន សាលាឧទ្ធរណ៍**

សូមទានជ្រាប។

**កម្មវត្ថុ:** សំណើសុំប្ដឹងលើសាលដីការដ្ឋប្បវេណីលេខ ............ ចុះថ្ងៃទី ................ របស់សាលាឧទ្ធរណ៍លើសេចក្ដីសម្រេចទាំងមូល ។

**យោង:** - សំណុំរឿងរដ្ឋប្បវេណីលេខ ............ ចុះថ្ងៃទី ................. របស់សាលាឧទ្ធរណ៍ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូចជម្រាបជូន ................ មេត្តាជ្រាបថា: កាលពីថ្ងៃទី ..................... សាលាឧទ្ធរណ៍បានបញ្ចប់ការទាញហេតុផលផ្ទាល់មាត់នៅថ្ងៃទី........... លើសំណុំរឿងរដ្ឋប្បវេណីលេខ ............... ចុះថ្ងៃទី ........................ហើយបានប្រកាសសាលដីការដ្ឋប្បវេណីលេខ...............ចុះថ្ងៃទី ................. ដែលប៉ះពាល់ដល់ផលប្រយោជន៍ខ្លាំងដល់រូបខ្ញុំបាទ/នាងខ្ញុំ ហើយខ្ញុំពុំសុខចិត្តនឹងសេខក្ដីសម្រេចនេះទេ ។ ហេតុនេះខ្ញុំសូមប្ដឹង សាទុក្ខលើសាលដីការដ្ឋប្បវេណីលេខ................ ចុះថ្ងៃទី ................ ក្នុងការវិនិច្ឆ័យសេចក្ដីសម្រេចទាំងមូលទាំង។

អាស្រ័យហេតុនេះ ខ្ញុំបាទ/នាងខ្ញុំសូម ....................... មេត្តាទទួលនូវពាក្យបណ្ដឹងសាទុក្ខរបស់ ខ្ញុំបាទ/នាងខ្ញុំ ដើម្បីចាត់ការតាមនីតិវិធីនៃច្បាប់ដោយអនុគ្រោះ ។

សូម ....................... មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ ។

........................, ថ្ងៃទី ....... ខែ .......... ឆ្នាំ..........

ស្នាមមេដៃ

# ឧបសម្ព័ន្ធទី១២

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រូបមន្តទី ៥១

## សារណាដើមបណ្តឹងសាទុក្ខ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ..................................ជាដើមបណ្តឹងសាទុក្ខ ក្នុងសំណុំរឿងព្រហ្មទណ្ឌ លេខ...............ចុះថ្ងៃទី..........ខែ...........ឆ្នាំ.................របស់តុលាការកំពូល។

**សូមគោរពជូន**

**ឯកឧត្តម ប្រធានតុលាការកំពូល**

កម្មវត្ថុ: សុំជូនសារណាខ្ញុំបាទ/នាងខ្ញុំជាដើមបណ្តឹងសាទុក្ខ។

យោង:សំណុំរឿងព្រហ្មទណ្ឌរបស់តុលាការកំពូលលេខ............ចុះថ្ងៃទី..........................................។

- មាត្រា ៤១៩, ៤២៦ និងមាត្រា ៤២៧ ក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី១០/០៨/២០០៧
- យោងលិខិតពឹងពាក់មេធាវីចុះថ្ងៃទី.........ខែ..............ឆ្នាំ..................
- លិខិតបង្គាប់ឲ្យធ្វើសារណាលេខ..............ចុះថ្ងៃទី.........ខែ..............ឆ្នាំ..............។

សេចក្តីដូចបានជម្រាបតាមកម្មវត្ថុ និងយោងខាងលើនេះខ្ញុំបាទ/នាង ខ្ញុំជាដើមបណ្តឹងសាទុក្ខសុំអនុញ្ញាតិជូនសារណាមានខ្លឹមសារដូចតទៅ:

១.អង្គហេតុ

២.អង្គច្បាប់ និងការចោទប្រកាន់

៣.ភស្តុតាងដាក់បន្ទុក

៤.ភស្តុតាងដោះបន្ទុក

៥.ចំណាត់ការនីតិវិធីកន្លងមក/សាលក្រមសាលាដំបូង/សាលក្រមសាលាឧទ្ធរណ៍

៦.ការប្តឹងសាទុក្ខពីសាលដីកា

៧.ចំណុចខ្លឹមសារប្តឹងសាទុក្ខពីសាលដីកា

៨.ខ្លឹមសារសំអាងនៃបណ្តឹងសាទុក្ខ

៩.អង្គច្បាប់សំអាង

១០.សំណូមពរ

ធ្វើនៅ.........................ថ្ងៃទី.........ខែ...........ឆ្នាំ..............

---

អាសយដ្ឋានផ្ទះលេខ...........ផ្លូវ.................ភូមិ....................ឃុំ/សង្កាត់......................ស្រុក/ខណ្ឌ..................ខេត្ត/រាជធានី..............

បានពិនិត្យដោយមេធាវី ម្ចាស់បណ្តឹងសាទុក្ខ